ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



- ◆ ១៧ មេសា : ថ្ងៃជម្លៀសប្រជាជនដោយបង្ខំ
- ◆ ការចងចាំនៃការជម្លៀសប្រជាជនដោយបង្ខំ

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ១៧៤ ខែមិថុនា ឆ្នាំ២០១៤

# ស្វែងរកការពិត

លេខ១៧៤ ខែមិថុនា ឆ្នាំ២០១៤

## ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា

◆ ១៧ មេសា ៖ ថ្ងៃជម្លៀសប្រជាជនដោយបង្ខំ.................................១

**ផ្នែកឯកសារ**

◆ លួង ថាវរៈ ៖ និស្សិតពេទ្យមកពីប្រទេសចិន....................................៤

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ គេរង់ណែលឃុំស្រយ៉ង់ ៖ សង្គ្រាមស៊ីវិល ....................................១៣

◆ ពិធីបើកសម្ពោធពិព័រណ៍ស្តីពី "ការជម្លៀសប្រជាជន........................២៦

◆ ការជម្លៀសប្រជាជនដោយបង្ខំ .................................................៣៧

**ផ្នែកច្បាប់**

◆ សំណុំរឿង០០៣ និង ០០៤ ៖ និយមន័យ ...............................៤៦

◆ ការចងចាំនៃការជម្លៀសដោយបង្ខំ ..............................................៥១

**វេទិកាពិភាក្សាសាធារណៈ**

◆ ការស្លាប់ក្នុងចលនា ៖ ការជម្លៀសដោយបង្ខំ ................................៥៣

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ ជីវិតក្នុងព្យុះមរណា ...................................................................៥៥



សិស្សចូលទស្សនាពិព័រណ៍ស្តីពីការជម្លៀសដោយបង្ខំ



**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ

ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន

លេខ០២៩១ពម.៩៩

ចុះថ្ងៃទី២ ខែសីហាឆ្នាំ១៩៩៩

រូបថតឯកសារៈមជ្ឈមណ្ឌលឯកសារកម្ពុជា

និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**ស្នាដៃលេខនេះ ៖** ស៊ឹរ សារីណា, លី សុខឃាង, សេង គន្ធី, ឆាយ ដារីន, ដាង ច័ន្ទនិមល, ហ៊ុយ សម្ផស្ស, ហាថសុន ម៉ាកវេន, ផាត កុសល, វ៉េនឌលដីហ្វាលកូ, ជេមស៍ អេ ថាយន័រ, សៀវ សុផុន **អ្នកនិពន្ធនិងស្រាវជ្រាវ ៖** ទាវ សារៈមុនិន្ទ, ស៊ិន សុធីតា **អ្នកបកប្រែ ៖** ភួង ច័ន្ទប្រណិត **និពន្ធនាយករងទី១ ៖** ឆាំង យុ និង ញាណ សុជាតិ **ជំនួយការនិពន្ធនាយក ៖** សោម ប៊ុនថន **ក្រាហ្វិកកុំព្យូទ័រ ៖** សោម ប៊ុនថន **គ្រប់គ្រងការចែកផ្សាយ ៖** ឆេង វ៉េង Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org

# ១៧ មេសា ៖ ថ្ងៃជម្លៀសប្រជាជនដោយបង្ខំ

ក្រុមគ្រួសាររបស់ខ្ញុំត្រូវបានបង្ខំឲ្យជម្លៀសចេញពីផ្ទះនៅទីក្រុងភ្នំពេញ ទៅស្រុកកំណើតនៅឯខេត្តព្រៃវែងដែលជាខេត្តមួយនៅភាគអាគ្នេយ៍នៃប្រទេសកម្ពុជា ។ ស្ថិតនៅក្នុងស្ថានភាពភ័យខ្លាច និងច្របូកច្របល់ គ្រួសាររបស់ខ្ញុំបានធ្វើដំណើរជាមួយនឹងអ្នកជម្លៀសផ្សេងទៀត ឆ្លងកាត់មហាវិថីព្រះមុនីវង្ស ឆ្ពោះទៅផ្លូវជាតិលេខ១ ដើម្បីទៅដល់គោលដៅរបស់ខ្លួន ។ ក្រុមគ្រួសាររបស់ខ្ញុំត្រូវធ្វើដំណើរដោយថ្មើរជើង ដោយមានចងភ្ជាប់របស់របរមួយចំនួនជាមួយនឹងម៉ូតូ ។ នៅពេលយប់ យើងត្រូវសម្រាកនៅតាមផ្លូវនៅកន្លែងដែលយើងដើរទៅដល់ ។ ម្តាយរបស់ខ្ញុំបានរំឭកថា នៅល្ងាចមួយ គ្រួសាររបស់ខ្ញុំបានដេកលើសាកសពប្រជាជនដទៃទៀត



ស៊ីវ សាវីណា ពន្យល់អ្នកចូលរួម ស្តីពីព្រឹត្តិការណ៍នៃការជម្លៀសដោយបង្ខំ

ដែលត្រូវបានសម្លាប់នៅក្នុងអំឡុងពេលធ្វើបដិវត្តន៍ ដោយពុំបានដឹងខ្លួនសោះ ។

ក្រុមគ្រួសាររបស់ខ្ញុំមិនបានធ្វើដំណើរទៅដល់ខេត្តព្រៃវែងនោះទេ ហើយបានប្តូរទិសដៅទៅខេត្តកំពង់ចាមដែលសាច់ញាតិម្តាយរបស់ខ្ញុំរស់នៅវិញ ។ ក្រុមគ្រួសាររបស់ខ្ញុំរស់នៅខេត្តកំពង់ចាមរហូតរបបខ្មែរក្រហមត្រូវបានដួលរលំ ។ ក្នុងនាមជា “ប្រជាជនថ្មី” ឬ “ប្រជាជន ១៧មេសា” ក្រុមគ្រួសាររបស់ខ្ញុំតម្រូវឲ្យរស់នៅលាយឡំជាមួយ “ប្រជាជនមូលដ្ឋាន” ដែលខ្មែរក្រហមចាត់ទុកជាប្រជាជនដែលអាចជឿទុកចិត្តបាន ។ ក្រោយមក ក្រុមគ្រួសាររបស់ខ្ញុំត្រូវបានជម្លៀសទៅរស់នៅក្នុងសហករណ៍មួយដែលជាកន្លែងធ្វើការងាររួម និងហូបបាយរួម ។ ក្រុមគ្រួសាររបស់ខ្ញុំត្រូវបានចាត់ចែងឲ្យធ្វើស្រែ និងប្រមូលជ័រកៅស៊ូ ។ ឪពុកម្តាយរបស់ខ្ញុំត្រូវបានបំបែកឲ្យរស់នៅកងផ្សេងគ្នា ។ ចំណែកឯបងប្រុសរបស់ខ្ញុំចំនួនពីរនាក់ ម្នាក់អាយុ៨ឆ្នាំ និងម្នាក់ទៀតអាយុ៧ឆ្នាំ តម្រូវឲ្យរស់នៅក្នុងកងកុមារ ។ ដោយសារឪពុករបស់ខ្ញុំជាអ្នកទីក្រុង និងជាគ្រូបង្រៀននៅសង្គមចាស់ ជីវិតរបស់ឪពុកខ្ញុំជួបការលំបាក ។ គាត់មិនសូវដឹងពីរបៀបធ្វើស្រែនោះទេ ។ ឪពុករបស់ខ្ញុំបានរួចជីវិតដោយសារតែការជួយការពារពីសំណាក់ក្រុមគ្រួសាររបស់ម្តាយខ្ញុំដែលជា “ប្រជាជនមូលដ្ឋាន” ។ ជាសំណាងអាក្រក់ សមាជិកដទៃទៀតនៅក្នុងក្រុមគ្រួសារខ្ញុំដែលបានជម្លៀសទៅភូមិភាគនិរតីនៅក្នុងខេត្តកំពត បានស្លាប់បាត់បង់ជីវិត ដោយសារតែស្ថានភាពរស់នៅលំបាក និងការសម្លាប់ ។ រយៈពេលជាង៣០ឆ្នាំបានកន្លងផុតទៅ ឪពុករបស់ខ្ញុំនៅតែរក្សាភាពស្ងៀមស្ងាត់ ចំពោះរឿងរ៉ាវដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម ។ បើទោះបីជាឪពុករបស់ខ្ញុំមិនបាននិយាយប្រាប់ខ្ញុំ អំពីជីវិតរបស់គាត់នៅក្នុងរបបខ្មែរក្រហមក៏ដោយ ក៏អំពើហិង្សា និងរឿងរ៉ាវ ដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម បានជះឥទ្ធិពលទៅលើគ្រួសាររបស់ខ្ញុំ និង

សង្គមកម្ពុជា ។

ទិដ្ឋភាពរបស់ប្រទេសកម្ពុជា បានបញ្ឆាក់នូវអំពើហិង្សា ដែលធ្លាប់កើតឡើង ។ ប្រទេសកម្ពុជាបានជួបប្រទះនូវសង្រ្គាមស៊ីវិលអស់រយៈពេលជិត៥ឆ្នាំ ចាប់ពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥ ។ បន្ទាប់មក កម្ពុជាបានធ្លាក់ចូលទៅក្នុងកណ្តាប់ដៃបដិវត្តន៍ខ្មែរក្រហម ដែលកាន់កាប់ប្រទេសកម្ពុជា ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៧ ខែ មករា ឆ្នាំ១៩៧៩ ។ កម្ពុជាប្រជាធិបតេយ្យ គឺជាឈ្មោះផ្លូវការរបស់ខ្មែរក្រហម ។ ខ្មែរក្រហមបានបង្កើតគោលនយោបាយ និងការអនុវត្តថ្មីៗ ដែលបង្កប់ទៅដោយភាពហិង្សា ។ ប្រជាជនក្នុងទីក្រុងជាច្រើនត្រូវបានជម្លៀសចេញពីទីក្រុងភ្នំពេញ និងទីរួមខេត្តនានាទៅតាមសហករណ៍នៅតាមទីជនបទ ។

នៅមុនពេលដែលខ្មែរក្រហមកាន់កាប់ទីក្រុងភ្នំពេញ ចំនួនប្រជាជននៅទីក្រុងបានកើនឡើងដល់ជាច្រើនលាននាក់ក្នុងរយៈពេលតែ៥ឆ្នាំប៉ុណ្ណោះ ។ ការកើនឡើងនៃចំនួនប្រជាជននៅទីក្រុងភ្នំពេញ ដោយសារតែជនភៀសខ្លួនពីខេត្តដាច់ស្រយាលមករស់នៅទីក្រុង ដើម្បីគេចផុតពីជម្លោះប្រដាប់អាវុធ ការទម្លាក់គ្រាប់បែក និងការកេណ្ឌទ័ពរបស់ខ្មែរក្រហម ។ នៅពេលដែលខ្មែរក្រហមឡើងកាន់កាប់អំណាច ខ្មែរក្រហមបានជម្លៀសប្រជាជនទីក្រុងទាំងអស់ឲ្យត្រឡប់ទៅស្រុកកំណើតវិញ ។ ប្រជាជនត្រូវបានជម្លៀសទៅកាន់តំបន់ផ្សេងៗជាមួយភាពច្របូកច្របល់ និងភាពភ័យខ្លាចក្រោមការឃ្លាំមើលរបស់យោធាខ្មែរក្រហម ។

ការជម្លៀសប្រជាជនចេញពីទីក្រុង បានបង្ហាញពីសោកនាដកម្មដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជា ។ ខ្មែរក្រហមបានបង្ខំប្រជាជនទីក្រុងឲ្យធ្វើការជាទម្ងន់នៅតាមទីជនបទ រស់នៅក្នុងសហករណ៍រួម និងត្រូវបានចាត់ចែងឲ្យធ្វើការនៅក្នុងគម្រោងកសិកម្ម និងប្រព័ន្ធធារាសាស្រ្តដ៏ធំ ។ ដើម្បីគ្រប់គ្រងប្រជាជន និងការផលិតរបស់ខ្លួន ខ្មែរក្រហមបានបង្កើតមន្ទីរសន្តិសុខ និងជំរំការងារពាសពេញប្រទេស ។ មន្ទីរពេទ្យ សាលារៀន វត្តអារាម និងវិហារសាសនា ត្រូវបានបិទ និងប្រែក្លាយទៅជាឃ្លាំង ឬគុក ។ ការប្រណិប័តន៍សាសនា និងប្រាក់កាសត្រូវបានហាមឃាត់ ។ មិន



ជនជាតិចាម នៅខេត្តបាត់ដំបង ចូលរួមទស្សនាពិព័រណ៍នៃការជម្លៀសដោយបង្ខំ ក្នុងរបបខ្មែរក្រហម

តែប៉ុណ្ណោះ ខ្មែរក្រហមមិនអនុញ្ញាតឲ្យប្រតិបត្តិវប្បធម៌របស់របបមុនក៏ដូចជា ជីវិតគ្រួសារ និងការនិយាយភាសា ។ ការប៉ុនប៉ងរបស់ខ្មែរក្រហមក្នុងការកសាងប្រទេសឡើងវិញ ដោយឈរលើមនោគមវិជ្ជារបស់ខ្លួន បានបង្កជាអំពើហិង្សា និងភាពភ័យខ្លាច ។ ជាលទ្ធផល សោកនាដកម្មទាំងនោះបានដក់ជាប់នៅក្នុងសង្គមកម្ពុជាអស់ជាច្រើនទសវត្សរ៍ ។

នៅក្នុងរបបខ្មែរក្រហម ប្រជាជនកម្ពុជាត្រូវបានផ្លាស់ប្តូរទីលំនៅជាបន្តបន្ទាប់ ពីកន្លែងមួយទៅកន្លែងមួយទៀត ដូចជាពីខេត្តកំពង់ចាម តាកែវ កណ្តាល និងព្រៃវែង ទៅខេត្តពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ និងខេត្តផ្សេងៗទៀត ។ ជាការសន្និដ្ឋានខ្មែរក្រហមជម្លៀសប្រជាជនពីទិសអាគ្នេយ៍ ទៅទិសពាយ័ព្យនៃប្រទេសកម្ពុជា ។ ប្រជាជនតម្រូវឲ្យធ្វើដំណើរដោយថ្មើរជើង ឬតាមទូក រថយន្តដឹកទំនិញ រថភ្លើង និងរទេះគោជាដើម ។ ប្រជាជនដែលត្រូវខ្មែរក្រហមជម្លៀស ជួបប្រទះនូវភាពភ័យខ្លាច ភាពច្របូកច្របល់ និងការប៉ះទង្គិចផ្នែកផ្លូវចិត្ត ដោយសារតែទទួលរងនូវភាពស្រេកឃ្លាន ការបំបែកចេញពីគ្រួសារ និងការបង្ខំឲ្យធ្វើដំណើរដោយមិនដឹងពីគោលដៅច្បាស់លាស់ ។ ជាពិសេស គឺការជម្លៀសតាមរថភ្លើង ។ ប្រជាជននៅលើទូរថភ្លើងពុំមានអាហារសម្រាប់បរិភោគនោះទេ មិនតែប៉ុណ្ណោះអ្នកដំណើរនៅលើទូរថភ្លើងត្រូវបំបែកចេញពីក្រុមគ្រួសារនៅពេលដែលរថភ្លើងឈប់នៅតាមស្ថានីយមួយៗ ។ ភាពឈឺចាប់នៃការបាត់បង់ និងការរងរបួសផ្នែកផ្លូវចិត្តរបស់ប្រជាពលរដ្ឋកម្ពុជា បានបង្ហាញពីការប្រព្រឹត្តដោយហិង្សារបស់ខ្មែរក្រហម ។

ការតាំងពិព័រណ៍អចិន្ត្រៃយ៍ស្តីអំពីការជម្លៀសដោយបង្ខំ ដែលស្ថិតក្រោមកិច្ចសហប្រតិបត្តិការរវាងមជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយនឹងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ បានឆ្លុះបញ្ចាំងពីរឿងរ៉ាវរបស់ជនរងគ្រោះដែលនៅរស់រានមានជីវិតអំពីការជម្លៀស និងស្ថានភាពរស់នៅដ៏លំបាកនៅក្នុងរបបខ្មែរក្រហម ក៏ដូចជា ការចងចាំរបស់អតីតយោធាខ្មែរក្រហម ដែលបានចូលរួមក្នុងការជម្លៀសប្រជាជន ។ តាមរយៈរូបថត រឿងរ៉ាវរបស់អ្នកដែលនៅរស់រានមានជីវិត ផែនទី និងរឿងរ៉ាវរបស់ជនរងគ្រោះដែលមាននៅក្នុងពិព័រណ៍អចិន្ត្រៃយ៍ស្តីអំពីការជម្លៀសដោយបង្ខំនឹងនាំមកនូវការចងចាំ ការទទួលស្គាល់ និងការគោរពដល់ជនរងគ្រោះដែលធ្លាប់ទទួលរងទុក្ខវេទនាក្នុងរបបខ្មែរក្រហម ។ កម្មវិធីអប់រំដែលរួមបញ្ចូលជាមួយនឹងការតាំងពិព័រណ៍ នឹងចាប់ផ្តើមឡើងនៅសារមន្ទីរខេត្តបាត់ដំបង បន្ទាយមានជ័យ កំពង់ធំ ស្វាយរៀង និងខេត្តតាកែវ ។ កម្មវិធីអប់រំនេះ នឹងជួយជំរុញឲ្យមានការពិភាក្សារវាងប្រជាជនដែលនៅរស់រានមានជីវិតពីរបបខ្មែរក្រហម និងក្មេងជំនាន់ក្រោយ អំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងកេរដំណែលដែលខ្មែរក្រហមបានបន្សល់ទុក ។ ការអប់រំនេះ នឹងធ្វើឡើងនៅតាមទីសាធារណៈ ទីឯកជន សារមន្ទីរខេត្ត សាលារៀន ផ្ទះ និងទីតាំងជាក់លាក់មួយចំនួន ដែលខ្មែរក្រហមធ្លាប់បានប្រព្រឹត្តអំពើហិង្សាប្រឆាំងនឹងប្រជាជនរបស់ខ្លួន ។ យើងសង្ឃឹមថា ពិព័រណ៍អចិន្ត្រៃយ៍ស្តីអំពីការជម្លៀសដោយបង្ខំ នឹងធ្វើឲ្យអ្នកទស្សនាបានឃើញនូវការឈឺចាប់ និងការភ័យខ្លាចដែលមានវត្តមានក្នុងរបបខ្មែរក្រហម ។

ក្នុងនាមជាក្មេងជំនាន់ក្រោយ ដែលកើតក្រោយរបបដ៏គួរឲ្យតក់ស្លុត រូបភាពនៃការជម្លៀស និងស្ថានភាពរស់នៅជាប្រចាំថ្ងៃរបស់គ្រួសារខ្ញុំនៅក្នុងរបបខ្មែរក្រហម បានត្រឹមតែស្ថិតនៅក្នុងការស្រមើស្រមៃរបស់ខ្ញុំតែប៉ុណ្ណោះ ។ ឪពុករបស់ខ្ញុំមិនដែលទម្លាយរឿងរ៉ាវទាំងនោះឲ្យខ្ញុំបានដឹងនោះទេ ។ ភាពស្ងៀមស្ងាត់របស់ឪពុកខ្ញុំ មិនបានពន្យល់ខ្ញុំឲ្យបានដឹងអំពីរឿងរ៉ាវដែលគាត់ធ្លាប់ឆ្លងកាត់នោះឡើយ ។ ប៉ុន្តែភាពស្ងៀមស្ងាត់របស់ឪពុកខ្ញុំ អាចបង្ហាញឲ្យខ្ញុំដឹងអំពីទំហំនៃការឈឺចាប់របស់គាត់នៅក្នុងរបបខ្មែរក្រហម ។ ខ្ញុំមានក្តីសង្ឃឹមថា រូបថត និងរឿងរ៉ាវដែលមានក្នុងពិព័រណ៍ នឹងជំរុញឲ្យប្រជាជនកម្ពុជា ចេះចែករំលែកនូវការចងចាំ និងរៀនសូត្របន្ថែមទៀតអំពីប្រវត្តិសាស្ត្រខ្មែរក្រហម ។ រឿងរ៉ាវរបស់មនុស្សម្នាក់ៗ គឺជាផ្នែកតូចមួយនៃរឿងរ៉ាវដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជានៅក្នុងរបបខ្មែរក្រហម ។ ការប្រមូលផ្តុំរឿងរ៉ាវរបស់ប្រជាជនម្នាក់ៗអាចធ្វើឲ្យយើងបានយល់ដឹងបន្ថែមអំពីព្រឹត្តិការណ៍ដែលបានកើតឡើងមកលើគ្រួសាររបស់យើង និងគ្រួសារដទៃទៀតនៅទូទាំងប្រទេសកម្ពុជា ។ ផលប៉ះពាល់នៃអំពើហិង្សាដែលបានកើតឡើងត្រូវបានដឹងឮដោយអ្នកនៅជុំវិញខ្លួន និងជួយជំរុញឲ្យមានការជួសជុលឡើងវិញនូវភាពថ្លៃថ្នូរជាមនុស្សដល់ជនដែលនៅរស់រានមានជីវិតពីអំពើប្រល័យពូជសាសន៍ ។ **ស៊ុំ សាទីណា**

# លួង ថាវរៈ : និស្សិតពេទ្យមកពីប្រទេសចិន

***ដកស្រង់ចេញពីឯកសារចម្លើយសារភាព***

លួង ថាវរៈ ជានិស្សិតរៀននៅប្រទេសបារាំង ក្រោយមកក៏ចូលរណសិរ្សរួបរួមជាតិកម្ពុជា និងបានចូលរៀនបន្តផ្នែកពេទ្យនៅក្រុងកង់តុង ប្រទេសចិន ។ ថាវរៈ បានត្រឡប់មកប្រទេសកម្ពុជា វិញនៅថ្ងៃទី២៧ ខែតុលា ឆ្នាំ១៩៧៥ ។ មួយខែក្រោយមក ថាវរៈ ត្រូវអង្គការចាប់ខ្លួន បញ្ជូនមកមន្ទីស-២១ ។ ថាវរៈ ត្រូវបានវាយសួរចម្លើយដោយឈ្មោះ ជា កាក់ និងសរុបចម្លើយដោយឈ្មោះ ភាព ។ នៅក្នុងឯកសារចម្លើយសារភាពរបស់ ថាវរៈ កម្រាស់២៦ទំព័រ ថាវរៈ បានរៀបរាប់ថាៈ

ខ្ញុំឈ្មោះ លួង ថាវរៈ ជាអតីតពេទ្យឆ្នាំទី២ ប្រទេសចិន បច្ចុប្បន្នមាននាទីជាយុទ្ធជនកងចល័ត មន្ទីរក-១៥ បឹងត្របែក ។

ខ្ញុំកើតនៅសង្កាត់លេខ១ ក្រុងភ្នំពេញ ។ ពេលអាយុ៥ឆ្នាំ ខ្ញុំបានចូលរៀននៅក្នុងវត្តកោះ ។ ដល់អាយុ៦ឆ្នាំ ខ្ញុំបានចូលរៀននៅសាលាគរុកោសល្យ រហូតដល់ឆ្នាំ១៩៦៧ ទើបបានចូលរៀននៅវិទ្យាល័យស៊ីសុវត្ថិ ។ ដល់ឆ្នាំ១៩៦៨ សិស្សរួមថ្នាក់ខ្ញុំឈ្មោះ វ៉ាស្នា (បច្ចុប្បន្ននៅប្រទេសបារាំង) និងសិស្សម្នាក់ទៀតឈ្មោះ ប្រីយ៉ា សោភ័ន បានទាក់ទងខ្ញុំ ដោយ វ៉ាស្នា ខស្សាហ៍នាំខ្ញុំទៅលេងឪពុករបស់ខ្លួន ជាទាហានពាក់ស័ក្តិ៤ ឈ្មោះ សុខ ប្រកប ។ រាល់ៗដងអ្នកទាំងនោះ តែងតែអប់រំខ្ញុំពីរឿង សេ.អ៊ី.អា ពិសេស



មន្ទីរសន្តិសុខស-២១ ឬ សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង

មនោគមវិជ្ជាលោកសេរី ហើយឲ្យស្អប់កុម្មុយនីស្ត ។ តាមរយៈកូន សុខ ប្រកប បានបញ្ចុកបញ្ឆ្យិខ្ញុំ និង ប្រីយ៉ា សោភ័ន ឲ្យដើរលេង សប្បាយពាលា មើលកុន សេ.អ៊ី.អា រហូតដល់ខ្ញុំចូលចិត្ត ។

ក្រោយមក សុខ ប្រកប បានណែនាំខ្ញុំ និង ប្រីយ៉ា សោភ័ន ឲ្យស្គាល់ ថាច់ ជា ជាចាងហ្វាងវិទ្យាល័យស៊ីសុវត្ថិ ។ ថាច់ ជា បាន អប់រំខ្ញុំទាំងបីនាក់ឲ្យរៀនយកការណ៍ពីសកម្មភាពសិស្សនៅក្នុង សាលារៀន ។

នៅខែកញ្ញា ឆ្នាំ១៩៦៨ សុខ ប្រកប បានបញ្ចូលខ្ញុំទាំងបីឲ្យ ចូលក្នុងខ្សែភ្នាក់ងារ សេ.អ៊ី.អា របស់ ថាច់ ជា ដោយមានរៀបចំ ពិធីគោរពទង់ សេ.អ៊ី.អា និងចាត់តាំងឲ្យ វ៉ាស្នា ទទួលខុសត្រូវលើ ពួកខ្ញុំ ។ បន្ទាប់មក សុខ ប្រកប និង ថាច់ ជា បានដាក់ផែនការបីឲ្យ ធ្វើគឺៈ

◆ ឲ្យតាមដានពីសកម្មភាពសិស្ស និងគ្រូនៅក្នុង និងក្រៅ សាលា

◆ ឲ្យធ្វើសកម្មភាពនយោបាយប្រឆាំងកុម្មុយនីស្ត ។

◆ កសាងកម្លាំង

ថាច់ ជា បានណែនាំខ្ញុំទាំងបីឲ្យស្គាល់ខ្សែដើម្បីទាក់ទងបន្ត ទៀត មានឈ្មោះ រស់ វ៉ាន់ថា នាទីជាអគ្គានុរក្សទី១ វិទ្យាល័យ ស៊ីសុវត្ថិ, ឈ្មោះ ងិន ចាន់ សារូ នាទីជាអគ្គានុរក្សទី២ វិទ្យាល័យ ស៊ីសុវត្ថិ ។

ក្នុងការតាមដានសកម្មភាពសិស្ស និងគ្រូ ខ្ញុំមានភារកិច្ចតាម ដាន និងឃ្លាំមើលសិស្សណាដែលបោះត្រាក់ក្នុង និងក្រៅសាលា និងបង្កប់ខ្លួនក្នុងចំណោមសិស្សណាដែលនៅជុំៗគ្នាដើម្បីយក ការណ៍ពីសកម្មភាពរបស់អ្នកទាំងនោះ ។ ខ្ញុំធ្វើការតាមដាន ទល់នឹង ឆ្នាំ១៩៦៩ ដោយគ្មានបានលទ្ធផល ។

បន្ទាប់មក ខ្ញុំបានទាក់ទងដើរលេងជាមួយសិស្សបីនាក់ដែល ចូលចិត្តសប្បាយពាលា ហើយបន្តិចម្តងៗ ខ្ញុំក៏អប់រំពីសកម្មភាព សេ.អ៊ី.អា រហូតដល់បញ្ចូលអ្នកទាំងបីក្នុងភ្នាក់ងារ សេ.អ៊ី.អា មាន ឈ្មោះ បូ ផល, ស៊ុន ដេ និង ឆេង សួ សិស្សវិទ្យាល័យស៊ីសុវត្ថិ ។ ខ្ញុំបានរួមសកម្មភាពជាមួយអ្នកទាំងនេះ ក្នុងការតាមដានសកម្ម ភាពសិស្ស និងគ្រូអស់មួយរយៈតែពុំបានលទ្ធផល ។ ក្រោយខ្ញុំ ក៏ដាច់ការទាក់ទងនឹងអ្នកទាំងនេះ ព្រោះអ្នកទាំងនោះត្រូវទទួល ភារកិច្ចថ្មី ។

នៅឆ្នាំ១៩៦៩ តាមរយៈ រស់ វ៉ាន់ថា បានឲ្យពួកខ្ញុំទាក់ទង នឹងឈ្មោះ អែម សំបូរ ជាសាស្ត្រាចារ្យវិទ្យាល័យស៊ីសុវត្ថិ ដើម្បីទទួលផែនការពីគ្រូនោះ ។ អែម សំបូរ បានណែនាំខ្ញុំឲ្យស្គាល់ ខ្សែថ្មីដើម្បីទាក់ទងឈ្មោះ ទុំ, ថាច និង គ្រឹក សិស្សនៅវិទ្យាល័យ ស៊ីសុវត្ថិ ដើម្បីតាមដានគ្រូឈ្មោះ ជួប ប៊ុននី ជាសាស្ត្រាចារ្យថ្នាក់ ទី៧ វិទ្យាល័យស៊ីសុវត្ថិ តែពេលនោះគាត់ក៏បាត់ខ្លួនទៅ ។ ក្នុង សកម្មភាព តាមដានសិស្ស ខ្ញុំបានរាយការណ៍ឲ្យចាប់ឈ្មោះ តារា ជាសិស្សវិទ្យាល័យស៊ីសុវត្ថិពីរឿងលួចបោះត្រាក់ក្នុងសាលា ។

ខ្ញុំបន្តទាក់ទងសិស្សពីរនាក់ដែលជាសិស្សពាលានៅក្នុង សាលា ដែលចូលចិត្តមនោគមវិជ្ជាលោកសេរី ។ តាមរយៈនេះ ខ្ញុំអប់រំអ្នកទាំងពីរឲ្យតាមដាន និងរាយការណ៍ពីសកម្មភាពសិស្ស និងគ្រូដែលនិយមខាងចម្រើន (លោកសេរី) ។ ក្រោយមក ខ្ញុំក៏ បញ្ចូលអ្នកទាំងនោះជាភ្នាក់ងារ សេ.អ៊ី.អា ដែលមានឈ្មោះ ធី វ៉ាក់ និង វ៉ារ៉ូ សិស្សវិទ្យាល័យស៊ីសុវត្ថិ ។

ខ្ញុំរួមជាមួយ ធី វ៉ាក់ និង វ៉ារ៉ូ និងសិស្សដែលជាខ្សែរបស់ អែម សំបូរ មានឈ្មោះ ទុំ, ថាច និង គ្រឹក បន្តធ្វើសកម្មភាពតាមដាន សិស្ស និងគ្រូជាបន្តរហូតដល់ឆ្នាំ១៩៧០ ។ រស់ វ៉ាន់ថា បានឲ្យខ្សែ របស់ខ្ញុំទាក់ទងនឹងខ្សែរបស់គាត់ថ្មីមួយទៀត ឈ្មោះ វ៉ាម៉ុន, វ៉ាឌី, កៅ, លន់ និង មាន ជាសិស្សវិទ្យាល័យយុគន្ធរ ។

ខ្ញុំរួមធ្វើសកម្មភាពតាមដានសកម្មភាពសិស្ស និងគ្រូបន្ត ទៀត និងបានរាយការណ៍ឲ្យចាប់សិស្សឈ្មោះ កន្ធា និង វដ្ឋា ជាសិស្សវិទ្យាល័យយុគន្ធរ ពីបញ្ហាលួចឃោសនាបម្រើសកម្មភាព ខ្មែរក្រហម ។ ខ្ញុំបានរួមសកម្មភាពជាមួយអ្នកទាំងនោះអប់រំសិស្ស ដែលមានធាតុប្រតិកិរិយាឲ្យចូលបម្រើក្នុងសកម្មភាព សេ.អ៊ី.អា មានឈ្មោះ ម៉ៅ និង សំដែង នៅវិទ្យាល័យយុគន្ធរ ហើយបាន បញ្ចូលឲ្យរួមធ្វើសកម្មភាពជាមួយគ្នា ។

នៅឆ្នាំ១៩៧១ ខ្ញុំបានទៅទាក់ទងជាមួយសិស្សបឹងត្របែក ឈ្មោះ ឆេង អៀង, ឡា ឌ័រ, ដូរ ណើ និង សុខុម ដើម្បីតាមដានគ្រូ ឈ្មោះ បួ ប៊ុន និង អ៊ុក ម៉ូរី ជាសាស្ត្រាចារ្យវិទ្យាល័យបឹងត្របែក ។ យើងបានតាមដានឃើញគ្រូទាំងនេះ មានសកម្មភាពបំផុសបំផុល សិស្សឲ្យធ្វើសកម្មភាពប្រឆាំងនឹងរដ្ឋាភិបាល លន់ នល់ រួចហើយ

ក៏រាយការណ៍ឲ្យប៉ូលិសចាប់គ្រូនេះបាត់ទៅ ។

មកដល់ចុងឆ្នាំ១៩៧១ រស់ វ៉ាន់ថា បានឲ្យខ្សែខ្ញុំតាមដានរកសកម្មភាពសិស្សដែលខ្លាំងជាងគេក្នុងសាលាស៊ីសុវត្ថិ ។ ខ្ញុំបានរាយការណ៍ឲ្យចាប់ឈ្មោះ សុខា, វឌ្ឍនា និង សុជាតិ ព្រោះសិស្សទាំងនេះមានសកម្មភាពប្រឆាំងរដ្ឋាភិបាល លន់ នល់ និងមានគ្រាក់នៅក្នុងខ្លួនដើម្បីអំពាវនាវឲ្យសិស្ស និស្សិត ងើបឡើងតស៊ូ និងរត់ចូលក្នុងតំបន់រំដោះ ។

នៅក្នុងរយៈពេលនោះ រស់ វ៉ាន់ថា បានបញ្ចូលភ្នាក់ងារ សេ.អ៊ី.អា ពីរនាក់ទៀតមកក្នុងខ្សែរបស់ខ្ញុំ មានឈ្មោះ កុសល និង ប៊ុន សុង ជាសិស្សវិទ្យាល័យស៊ីសុវត្ថិ ។ រស់ វ៉ាន់ថា បន្ថែមថា សិស្សពីរនាក់នេះមក ព្រោះពេលនោះ សកម្មភាពសិស្ស និងគ្រូផុសផុលខ្លាំងប្រឆាំងនឹងរដ្ឋាភិបាល ។ នៅពេលនោះ សកម្មភាពឃោសនារបស់ខ្ញុំលែងមានប្រសិទ្ធភាពហើយ ។ ដូច្នេះខ្សែរបស់ខ្ញុំមានភារកិច្ចត្រឹមតែតាមដានរកអ្នកដឹកនាំបំផុសចលនាសិស្សប៉ុណ្ណោះ តែមិនបានទទួលលទ្ធផល ។

នៅឆ្នាំ១៩៧២ វាស្នា ត្រូវចេញពីខ្សែរបស់ខ្ញុំទៅប្រទេសបារាំង ដើម្បីទៅធ្វើសកម្មភាពនិស្សិតឯបរទេស ។ នៅឆ្នាំ១៩៧៣ ប្រីយ៉ា សោភ័ន ក៏ត្រូវទៅប្រទេសបារាំងទៀត ។ បន្ទាប់មក រស់ វ៉ាន់ថា បាននាំខ្ញុំទៅទាក់ទងឲ្យស្គាល់ឈ្មោះ ឃី យូ ធ្វើការនៅក្រសួងប្រៃសណីយ៍ ។ ក្នុងការណែនាំនេះ វ៉ាន់ថា គ្រាន់តែនាំខ្ញុំឲ្យស្គាល់ ឃី យូ មុននឹងឈ្មោះនេះទៅប្រទេសបារាំង ។

ដល់ខែមិថុនា ឆ្នាំ១៩៧៣ រស់ វ៉ាន់ថា បានបញ្ជូនខ្ញុំទៅប្រទេសបារាំង ដោយឲ្យទទួលផែនការ និងការគ្រប់គ្រងពី ឃី យូ ។ ពេលនោះ ខ្ញុំបានជួបខ្សែចាស់របស់ខ្ញុំវិញ គឺ វាស្នា និង ប្រីយ៉ា សោភ័ន ។ បន្ទាប់មក ឃី យូ បានណែនាំខ្ញុំឲ្យស្គាល់ឈ្មោះ ណុំ នាង និស្សិតអក្សរសាស្ត្រ, ផ្លូន និស្សិតឱសថសាស្ត្រ និង វុន និស្សិតវិទ្យាសាស្ត្រ នៅប្រទេសបារាំង ដើម្បីធ្វើសកម្មភាពនយោបាយប្រឆាំងនឹងចលនាបដិវត្តន៍ក្នុងប្រទេស បំភ័យមហាជនឲ្យខ្លាចពីចលនាបដិវត្តន៍កុំឲ្យចូលរួមក្នុងចលនានេះ ។

នៅខែសីហា ឆ្នាំ១៩៧៣ ខ្ញុំបានចូលរៀនថ្នាក់ទីបញ្ចប់នៅសាលាបារាំង ខ្ញុំក៏ឈប់នៅជាមួយ ឃីយូ ដោយខ្ញុំទៅនៅក្នុងសាលាមួយឯក្រៅក្រុងវិញ ។ ពេលនោះ ឃីយូ បានឲ្យខ្ញុំចូលបង្កប់ខ្លួនក្នុងជួរណសិស្សប្រចាំប្រទេសបារាំង តាមរយៈខ្សែបង្កប់របស់គាត់មានឈ្មោះដូចជា ៈ

១) ហ៊ិន សៀ និស្សិតអក្សរសាស្ត្រ (បច្ចុប្បន្ន ចូលមកប្រទេស)

២) កែវ ណូរិន និស្សិតគណិតសាស្ត្រ (បច្ចុប្បន្ន នៅប្រទេសបារាំង)

៣) កេ គីមសែ និស្សិតគណិតសាស្ត្រ (បច្ចុប្បន្ន ចូលមកប្រទេស)

៤) ប៉ិ ប៊ុនតុង និស្សិតអក្សរសាស្ត្រ (បច្ចុប្បន្ន នាទីជាយុទ្ធជនមន្ទីរក-១៥)

៥) ឡូច គីមបែន និស្សិតខាងម៉ាស៊ីន (បច្ចុប្បន្ន ចូលមកប្រទេស)

៦) គីគីមលាននិស្សិតឱសថសាស្ត្រ (បច្ចុប្បន្ននៅប្រទេសបារាំង)

៧) កង ធានី និស្សិតគណិតសាស្ត្រ (បច្ចុប្បន្ន នៅក្នុងប្រទេស)

៨) គ្រាន់ អ៊ីវតឹក និស្សិតខាងសំណង់ (បច្ចុប្បន្ន នៅក្នុងប្រទេស)

៩) កង អ៊ីឡាវ៉ាន់ និស្សិតវិទ្យាសាស្ត្រ (បច្ចុប្បន្ន នៅក្នុងប្រទេស)

១០) លាន សេរីវុធ និស្សិតអក្សរសាស្ត្រ (បច្ចុប្បន្នអង្គការចាប់)

១១) ម៉ែន សេរីឫទ្ធី និស្សិតពេទ្យ (បច្ចុប្បន្នអង្គការចាប់)

១២) ម៉ែន សេរីសិទ្ធី និស្សិតខាងគ្រឿងម៉ាស៊ីន (បច្ចុប្បន្នអង្គការចាប់)

១៣) ជា ប៊ុនចេង និស្សិតអក្សរសាស្ត្រ (បច្ចុប្បន្ន នាទីជាយុទ្ធជនមន្ទីរក-១៥)

១៤) តាន់ កុកម៉េង និស្សិតគណិតសាស្ត្រ (បច្ចុប្បន្ន នាទីជាយុទ្ធជនមន្ទីរក-១៥)

១៥) តាន់ កុកអេង និស្សិតអក្សរសាស្ត្រ (បច្ចុប្បន្ន នាទីជាយុទ្ធជនមន្ទីរក-១៥)

១៦) ថោង ស៊ីវ៉ាម៉ុន និស្សិតពេទ្យ (បច្ចុប្បន្ន នាទីជា

យុទ្ធជនមន្ទីរក-១៥)

ឃីយូ បានឲ្យខ្ញុំស្គាល់ឈ្មោះទាំងនេះ ដើម្បីងាយស្រួលទាក់ទងក្នុងការធ្វើសកម្មភាពយកការណ៍ពីគ្រប់សកម្មភាពដែលមាននៅពេលប្រជុំយកការណ៍ពីមហាជនថ្មី-ចាស់ ដែលចូលមកក្នុងជួរណសិរ្ស ដើម្បីរាយការណ៍ពីសកម្មភាពរបស់អ្នកទាំងនោះ ។

នៅខែឆ្នាំដដែល ឃីយូ បាននាំខ្ញុំឲ្យជួប ស៊ីសុវត្ថិ អ៊ីសារ៉ូ ជាចាងហ្វាងផ្ទះខ្មែរប្រចាំប្រទេសបារាំង (បច្ចុប្បន្ន នៅប្រទេសបារាំង) ។ ពេលនោះ អ៊ីសារ៉ូ បានណែនាំខ្ញុំឲ្យមកបន្តប់ខ្លួននៅប្រទេសចិនទៀត ហើយបានណែនាំខ្ញុំឲ្យស្គាល់ឈ្មោះ អ៊ុំ ម៉ាណូរិន (នាទីជាមេប៉ូលិស បច្ចុប្បន្ន នៅប្រទេសបារាំង), នុត ឈឿម ជាចាងហ្វាងកាសែតសុជីវធម៌ (បច្ចុប្បន្ន នៅប្រទេសបារាំង) និង អ៊ុំ ប៉េងចេង នាទីក្តាប់មិនបាន (បច្ចុប្បន្ន នៅប្រទេសបារាំង) ដើម្បីទាក់ទងអ្នកទាំងនោះ ពេលទៅនៅប្រទេសចិនដើម្បីធ្វើចលនាប្រឆាំងចលនាបដិវត្តន៍ ។

នៅចុងឆ្នាំ១៩៧៣ ខ្ញុំចេញមកប្រទេសចិនជាមួយខ្មែរបន្តប់មួយចំនួន មានឈ្មោះ គី គីលាន, ឡូច គីមបែន, ថោង ស៊ីវ៉ាម៉ុន, ម៉ែន សេរីឫទ្ធិ និង ម៉ែន សេរីសិទ្ធិ ។ ឃីយូ បានឲ្យខ្ញុំទៅទាក់ទងនឹងឈ្មោះ ប៉ែន សំផន ដែលធ្វើការនៅក្រសួងឃោសនាការនៃរណសិរ្សរួបរួមជាតិកម្ពុជា ប្រចាំក្រុងប៉េកាំង (បច្ចុប្បន្ន នៅក្នុងប្រទេស) ដើម្បីទទួលការណែនាំ និងសកម្មភាពដែលត្រូវធ្វើ ។

ពេលនោះ ប៉ែន សំផន ឲ្យខ្ញុំទៅទាក់ទងនឹង អ៊ុំ ម៉ាណូរិន, នុត ឈឿម, អ៊ុំ ប៉េងចេង ដែលរស់នៅជាមួយសម្តេច សីហនុ ដើម្បីយកព័ត៌មានពីសកម្មភាពក្នុងប្រទេសកាលពេលសម្តេច សីហនុ ចូលមកក្នុងប្រទេសតាមរយៈអ្នកទាំងនោះ ប៉ុន្តែមិនបានលទ្ធផល ។ ប៉ែន សំផន បានណែនាំខ្ញុំឲ្យស្គាល់ខ្មែរដែលរស់នៅមជ្ឈដ្ឋានជាមួយគាត់ មានឈ្មោះ ៖

◆ យ៉ាវ ធ្វើការនៅក្រសួងការបរទេសរណសិរ្សរួបរួមជាតិកម្ពុជា នៅប៉េកាំង (បច្ចុប្បន្នចូលប្រទេស)

◆ អួង ខន ធ្វើការនៅក្រសួងឃោសនាការរណសិរ្សរួបរួម



រណ្តៅសាកសពដែលត្រូវបានគាស់ ក្រោយរបបខ្មែរក្រហមដួលរលំ ឆ្នាំ១៩៧៩

ជាតិកម្ពុជា នៅប៉េកាំង (បច្ចុប្បន្ន អន្តការចាប់)

ខ្ញុំទាក់ទងអ្នកទាំងពីរនេះ រួមជាមួយនិស្សិតបន្តប់ដែលមកជាមួយខ្ញុំ ធ្វើសកម្មភាពនៅក្នុងចំណោមមហាជនខ្មែរដែលនៅក្រុងប៉េកាំងខាងនយោបាយមិនឲ្យមានជំនឿលើជ័យជម្នះរបស់បដិវត្តន៍កម្ពុជាលើចក្រពត្តិអាមេរិក ឲ្យរកការចរចាដើម្បីសន្តិភាព និងបំភ័យអ្នកទាំងនោះឲ្យខ្លាចពីការវិលចូលមកក្នុងប្រទេស ។

ខ្ញុំរួមធ្វើសកម្មភាពនេះបានត្រឹមខែកញ្ញា ឆ្នាំ១៩៧៤ ក៏ត្រូវគណៈកម្មាធិការសាលាចិន បញ្ជូនខ្ញុំឲ្យទៅរៀនបច្ចេកទេសពេទ្យចិន ឯក្រុងកង់តុង ជាមួយនិស្សិតចិន ។ ពីត្រឹមនោះមក ខ្ញុំក៏ដាច់ការទាក់ទងរហូតដល់ខែតុលា ឆ្នាំ១៩៧៥ ពេលអង្គការប្រមូលនិស្សិតទាំងអស់ដែលនៅប្រទេសចិនឲ្យចូលប្រទេសវិញ ។ អ្នកដែលចូលមកក្នុងប្រទេសជាមួយខ្ញុំពេលនោះ មានឈ្មោះ ៖ ថោង ស៊ីវ៉ាម៉ុន (បច្ចុប្បន្ន យុទ្ធជនមន្ទីរក-១៥), លាន សេរីវុធ (បច្ចុប្បន្ន យុទ្ធជនមន្ទីរក-១៥ អង្គការចាប់), ម៉ែន សេរីឬទ្ធី (បច្ចុប្បន្ន យុទ្ធជនមន្ទីរក-១៥ អង្គការចាប់), ម៉ែន សេរីសិទ្ធី (បច្ចុប្បន្ន យុទ្ធជនមន្ទីរក-១៥ អង្គការចាប់) ។

ខ្ញុំមកដល់ភ្នំពេញនៅថ្ងៃទី២៧ ខែតុលា ឆ្នាំ១៩៧៥ ដោយអង្គការឲ្យនៅក្រសួងមហាផ្ទៃ ។ ខ្ញុំនៅទីនោះបានពីរថ្ងៃ អង្គការក៏ដកមកនៅវិមានឯករាជ្យវិញដើម្បីបើកវគ្គអប់រំ មុនពេលចុះទៅរៀនសូត្រពីប្រជាជនមូលដ្ឋាន ។ អង្គការបើកវគ្គអប់រំចំនួនប្រាំពីរថ្ងៃ ។ រយៈពេលនោះ លាន សេរីវុធ បាននាំខ្ញុំឲ្យស្គាល់ឈ្មោះ ស្វាយ បូរ៉ាមី និស្សិតពេទ្យប្រទេសចិន (បច្ចុប្បន្ន នាទីជានារីពេទ្យមន្ទីរក-១៥), អ៊ីង សាន និស្សិតពេទ្យ ប្រទេសចិន (បច្ចុប្បន្ន នាទីជានារីពេទ្យមន្ទីរក-១៥) ។ ខ្ញុំគ្រាន់តែបានស្គាល់ប៉ុណ្ណោះ ពុំបានធ្វើសកម្មភាពទេ ព្រោះអង្គការបានឲ្យយើងទាំងអស់ជានិស្សិតចុះទៅរៀនសូត្រឯមូលដ្ឋាន ស្រុកស្ទឹងត្រង់ នៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ១៩៧៥ ។ អង្គការបំបែកយើងទាំងអស់ឲ្យចុះទៅគ្រប់ឃុំ នៃស្រុកស្ទឹងត្រង់ ។

ខ្ញុំត្រូវបានអង្គការឲ្យទៅនៅភូមិដីដុះ ឃុំពាមកោះស្នា ហើយបានរស់នៅជាយុទ្ធជនសហករណ៍ដីដុះនេះ នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៧៥ ។ ពេលរស់នៅក្នុងសហករណ៍នេះ ខ្ញុំតែងស្រាវជ្រាវមើលពីប្រជាជនថ្មី ក្រែងបានជួបប្រទះនឹងខ្មែរចាស់របស់ខ្ញុំ តែពុំបានប្រទះទេ ។ រហូតដល់ខែកុម្ភៈ ឆ្នាំ១៩៧៦ គណៈភូមិបានឲ្យខ្ញុំទៅលើកទំនប់ក្នុងភូមិ ពេលនោះខ្ញុំបានទាក់ទងស្គាល់ឈ្មោះ លាភ ជាប្រជាជនថ្មី និងជាអតីតនិស្សិតមហាវិទ្យាល័យច្បាប់ នាទីជាយុទ្ធជនកងទីពីរនៃសហករណ៍ដីដុះ ។ ក្នុងការទាក់ទងនេះ បានធ្វើឲ្យខ្ញុំស្គាល់ពីប្រវត្តិរបស់ លាភ ដែលធ្លាប់បានទាក់ទងនឹងខ្មែរចាស់របស់ខ្ញុំ ដែលជាសិស្សវិទ្យាល័យបឹងត្របែក ។ លាភ ក៏បានបញ្ចុះបញ្ចូលខ្ញុំឲ្យធ្វើសកម្មភាពបំផ្លាញសហករណ៍ជាមួយខ្មែររបស់គាត់ ដែលគាត់នឹងប្រាប់នៅពេលណាខ្ញុំបានរួមធ្វើសកម្មភាពជាមួយគាត់សិន ។ មួយរយៈនោះ ខ្ញុំបានធ្វើសកម្មភាពបំផ្លាញសហករណ៍មានដូចជា ៖

◆ លួចបំផ្លាញចបនៅក្នុងកង ដោយយកទៅបោះចូលនៅក្នុងព្រែក

◆ លួចបណ្តាច់ខ្សែគោ ឲ្យគោស៊ីដំណាំក្នុងភូមិ មានដូចជាពោតដំឡូង

◆ លួចដកដើមកប្បាស

ពេលគណៈសហករណ៍បញ្ចូលខ្ញុំទៅក្នុងកងភ្ជួរ ខ្ញុំក៏បានធ្វើសកម្មភាពភ្ជួរឲ្យមុតជើងគោ ប្រើការលែងកើត ដោយយកលេសថា មិនចេះភ្ជួរ និងបំផ្លាញដោយភ្ជួរបំបាក់នង្គ័ល ។

បន្ទាប់មក លាភ បានឲ្យខ្ញុំស្គាល់ឈ្មោះ យុន ជាប្រជាជនថ្មី អតីតនិស្សិតឱសថសាស្ត្រ ជាយុទ្ធជនកងទីបួន សហករណ៍ដីដុះ ។ លាភ ណែនាំឲ្យខ្ញុំស្គាល់ឈ្មោះ យុន នេះដើម្បីរួមធ្វើសកម្មភាពបំផ្លាញ ហើយខ្ញុំរួមជាមួយឈ្មោះ យុន បានបំផ្លាញ ៖

◆ ស្រូវមួយដឹក ដោយយកទៅចាក់ចោលក្នុងព្រែក ហើយយកលេសថា ភ្លូករទេះធ្លាក់ក្នុងព្រែក ។

◆ លួចកាប់ជើងគោ

◆ លួចពន្លិចទូកសហករណ៍នៅក្នុងទឹកទន្លេ

ក្រោយមក លាភ ក៏ណែនាំខ្ញុំឲ្យស្គាល់ឈ្មោះ ៖

◆ លី យាង ជាប្រជាជនថ្មី និងជាយុទ្ធជនរកខុសសម្រាប់ការដ្ឋានបាយ ក្នុងភូមិដីដុះ

◆ រឿន ជាប្រជាជនថ្មី នាទីជាអ្នកបើកបរឡាំប្រឺតា ជាយុទ្ធជនកងចល័តក្នុងភូមិដីដុះ

◆ សុខ ជាប្រជាជនចាស់ នាទីជាសមាជិកពាណិជ្ជកម្ម

សហករណ៍ដីដុះ

លាភ ណែនាំខ្ញុំឲ្យស្គាល់ឈ្មោះអ្នកទាំងនេះ ដើម្បីទាក់ទងគ្នាធ្វើសកម្មភាពក្នុងភូមិ ហើយពេលនោះ ខ្ញុំក៏បានទទួលផែនការពីឈ្មោះ សុខ បន្ថែមទៀតគឺៈ

ទី១) បំផ្លាញសម្បត្តិសមូហភាពនៅក្នុងសហករណ៍

ទី២) ធ្វើសកម្មភាពនយោបាយប្រឆាំងរបបសមូហភាព

ខ្ញុំជាមួយ លី យាង បានលួចដុតគុម្ពឫស្សីក្នុងភូមិចំនួន៤គុម្ព ហើយបានរួមសកម្មភាពអុជអាលប្រជាជនឲ្យមិនពេញចិត្តនឹងរបបហូបចុកសមូហភាព ដូចជា ហូបបាយរួមមិនឆ្អាញ់ ដូចហូបបាយឯកជន ។

ក្នុងការទាក់ទងនឹងឈ្មោះ រឿន វិញ យើងបានរួមសកម្មភាពលួចដកកូនថ្នាំដែលទើបដាំអស់ចំនួនប្រហែលជា៤០អា លួចដកដើមពោតអស់ចំនួនប្រហែលកន្លះហិកតា ។ ខ្ញុំបានវាយរបបសមូហភាពខាងនយោបាយទៀត ដូចជាថា គោដាក់រួមឡើងស្គមមិនដូចគោកាលនៅឯកជន ។

ខ្ញុំធ្វើសកម្មភាពនេះ រហូតដល់ឈ្មោះ សុខ បានហៅខ្ញុំឲ្យទៅធ្វើការក្នុងពាណិជ្ជកម្មសហករណ៍ដីដុះដើម្បីជួយកត់ត្រាបញ្ជី ។ ពេលនោះខ្ញុំជាមួយឈ្មោះ សុខ បានធ្វើសកម្មភាពបំផ្លាញនៅក្នុងមន្ទីរពាណិជ្ជកម្ម ដោយលួចធ្វើឲ្យប្រេះបាតពាងប្រហុកដើម្បីបង្ហូរទឹកប្រហុកចោលអស់ចំនួនបីពាង ។ ឈ្មោះ សុខ បានណែនាំខ្ញុំឲ្យកត់បញ្ជីបន្ទំចំនួនអង្ករចេញ និងចូល បានចំនួនបីបាវដោយ សុខ បានប្រាប់ខ្ញុំថា នឹងលួចបញ្ចេញអង្ករនេះទៅឲ្យខ្មែរស ដែលកំពុងធ្វើសកម្មភាពចោរព្រៃនៅម្តុំអូរទឹកក្រហម រួចហើយបានលួចបញ្ចេញអង្ករនេះតាមរយៈឈ្មោះ វ៉ា ជាប្រជាជនភូមិដីដុះ នាទីជាកងដឹកជញ្ជូននៃសហករណ៍ដីដុះ ។

បន្ទាប់មក សុខ បាននាំខ្ញុំទៅជួបឈ្មោះ វ៉ាន នាទីជាប្រធានឃុំពាមកោះស្នា ។ វ៉ាន បានអប់រំខ្ញុំ ឲ្យបន្តធ្វើសកម្មភាពដដែល ហើយបញ្ចូលខ្ញុំឲ្យទៅនៅក្នុងកងភ្ជួរ ដោយឲ្យទាក់ទងនឹងឈ្មោះ ចយ ជាប្រជាជនភូមិដីដុះ អតីតសិស្សវិទ្យាល័យកំពង់ចាម មាននាទីជាប្រធានកងភ្ជួរក្នុងសហករណ៍ដីដុះ ។ ខ្ញុំបានធ្វើសកម្មភាពបំផ្លាញជាមួយ ចយ បំផ្លាញនង្គ័ល ដោយធ្វើជាភ្ជួរបុកបង្គោលឲ្យបាក់, បំផ្លាញ ដោយលួចបំបាក់ធ្មេញរនាស់ និងលួចបោះចបចោលនៅក្នុងប្រឡាយ ។

ខ្ញុំធ្វើសកម្មភាពនៅក្នុងកងភ្ជួរនេះបានមួយរយៈ ក៏ត្រូវអង្គការដកពីមូលដ្ឋានឲ្យមកភ្នំពេញវិញ ។ អង្គការបានឲ្យខ្ញុំទៅនៅ (មន្ទីរក-១៥ បឹងត្របែក) ក្រសួងការបរទេស ។ ពេលនោះ ខ្ញុំបានជួបខ្មែរនិស្សិតចាស់ដែលធ្លាប់ធ្វើសកម្មភាពជាមួយគ្នាឯក្រៅប្រទេស ។ យើងទាក់ទងគ្នាតាមរយៈការលួចប្រជុំ ដែលរួមមានឈ្មោះ នុត ប៊ុនសុង ជាអ្នកណែនាំ ចំណែកអ្នកចូលរួមមានឈ្មោះ ១) លាន សេរីវុធ, ២) ម៉ែន សេរីសិទ្ធិ, ៣) ថោង ស៊ីវ៉ាម៉ុន, ៤) ម៉ែន សេរីឬទ្ធិ, ៥) ជា ប៊ុនចេង និង ៦) អ៊ុំ សិទ្ធិ ដោយលើកផែនការបំផ្លាញឧបករណ៍ប្រើប្រាស់នៅក្នុងមន្ទីរ និងបានធ្វើសកម្មភាពនយោបាយប្រឆាំងរបបសមូហភាព ។

ខ្ញុំបានធ្វើការទាក់ទងឈ្មោះ លាន សេរីវុធ, ម៉ែន សេរីសិទ្ធិ, អ៊ុំ សិទ្ធិ ដែលទាំងអស់គ្នាជាយុទ្ធជនកងចល័តមន្ទីរក-១៥ មានភារកិច្ចរុះរើផ្ទះ និងបោសសម្អាតប្លង់ដី និងបានធ្វើសកម្មភាពបំផ្លាញឧបករណ៍នៅក្នុងមន្ទីរ មានបំផ្លាញដែកស្បែង ពូថៅ និងរណា ។ ក្រោយពីនោះ យើងបំផ្លាញសម្ភារជ័យភ័ណ្ឌរបស់អង្គការមាន ទូ តុ ពេលរុះរើផ្ទះ ដោយរុញទម្លាក់ ឬដុតចោល ។ គាត់បំផ្លាញក្តារជញ្ជាំងផ្ទះឲ្យបែកប្រើការមិនកើត ។ ខ្ញុំបានលួចធ្វើសកម្មភាពបំផ្លាញដើមឈើនៅក្នុងមន្ទីរ ដូចជា កាប់ដើមត្របែកចោល កាប់កូនដើមស្វាយ ។

ខ្ញុំបានរួមសកម្មភាពជាមួយ ថោង ស៊ីវ៉ាម៉ុន ក្នុងការលួចបំផ្លាញគ្រឿងម៉ាស៊ីនក្រឡឹង, គ្រឿងម៉ាស៊ីនស្មានៅក្នុងមន្ទីរសិប្បកម្មដោយលួចដោះខ្សែឲ្យខូចប្រើការលែងកើត ។

ពេលបង្កបង្កើនផល ឬដាំដំណាំក្នុងមន្ទីរខ្ញុំបានលួចបំផ្លាញចប ដោយលួចបោះចោលក្នុងប្រឡាយ បំផ្លាញដើមប៉េងប៉ោះ ដោយលួចកាត់ឫសកែវចោលរួចទើបដាំ លួចកាត់ដើមឃ្លោកដែលទើបដាំចោល និង លួចដកដើមត្រប់ ។

ខ្ញុំបានរួមសកម្មភាពជាមួយ ជា ប៊ុនចេង, ម៉ែន សេរីឬទ្ធិ និងអេង ធ្វើសកម្មភាពនយោបាយ ដោយអុជអាលមហាជនឲ្យថ្នាំងថ្នាក់នឹងរបបសមូហភាព ដូចជា អុជអាលពីរឿងហូបចុកមិនឆ្អាញ់ ហូបមិនឆ្អែត និងចាក់ចុចមហាជនឲ្យធ្វើការល្ហមៗ ហើយប្រយ័ត្នឈឺ ។

ក្រោយមកឈ្មោះ នុត ប៊ុនសុង បានណែនាំយើងខ្ញុំម្តងទៀតតាមផែនការ ៈ

ទី១) បំផ្លាញទ្រព្យសម្បត្តិសមូហភាព

ទី២) អុជអាលមហាជន ដើម្បីវាយប្រហារការចាត់តាំងរបស់អង្គការ

ទី៣) កសាងកម្លាំង

ខ្ញុំបានធ្វើសកម្មភាពបំផ្លាញជាមួយ តាំង កុកម៉េង ក្នុងការបំផ្លាញដំណាំ ដូចជា លួចកាត់កូនដើមននោង បំផ្លាញដើមល្ហុងដោយលួចកាត់ឫសកែវមុននឹងដាំ និងលួចវាយបំបែកពាងទឹកនោម ចំនួនប្រាំពាង ។

ខ្ញុំជាមួយឈ្មោះ លាន សេរីវុធ បានធ្វើសកម្មភាពទាក់ទងចាក់ចុចឈ្មោះ ផេង នាទីជាយុទ្ធជនកងចល័តមន្ទីរក-១៥ ឈ្មោះ ចាន់ បូផល ដែលជាយុទ្ធជននៅក្នុងមន្ទីរសិប្បកម្មមន្ទីរក-១៥ ដោយកសាងឈ្មោះទាំងពីរនាក់នេះ ឲ្យធ្វើសកម្មភាពជាមួយ ពីព្រោះអ្នកទាំងពីរតែងថ្នាំងថ្នាក់នឹងរបបហូបចុកសមូហភាព ហើយសេរីក្នុងការនិយាយស្តី និងឲ្យរួមសកម្មភាពវាយប្រហារគណៈកម្មាធិការមន្ទីរ ។ ពេលនោះ ខ្ញុំរួមជាមួយឈ្មោះ ផេង បានលួចបណ្តាច់ខ្សែភ្លើងដើម្បីបង្អាក់ការងារពេលយប់ ។

ក្រោយមក ឈ្មោះ នុត ប៊ុនសុង បានណែនាំឲ្យស្គាល់ឈ្មោះ រឿន និងឈ្មោះ វ៉ន ដែលជាខ្សែចាស់របស់គាត់កាលនៅបរទេស ដែលមាននាទីជាយុទ្ធជនមន្ទីរក-១៥ ឲ្យយើងរួមសកម្មភាពជាមួយគ្នាក្នុងការចាក់ចុចមហាជនឲ្យថ្នាំងថ្នាក់ ហើយវាយប្រហារប្រធានគណៈកម្មាធិការមន្ទីរ ។ ពេលនោះ យើងធ្វើសកម្មភាពចាក់ចុចចចិកចចុកពេញទាំងមន្ទីរ ហើយពេលនោះមហាជនបានវាយប្រហារប្រធានមន្ទីរនៅរាល់ពេលប្រជុំ រហូតដល់អង្គការសម្រេចដកគណៈកម្មាធិការចាស់ចេញ ហើយរៀបចំចាត់តាំងគណៈកម្មាធិការថ្មី ។ ក្នុងការវាយប្រហារគណៈកម្មាធិការចាស់នេះ គឺយើងមានទិសដៅឲ្យឈ្មោះ នុត ប៊ុនសុង ឡើងធ្វើជាប្រធានគណៈកម្មាធិការមន្ទីរ ដើម្បីជាបង្អែកក្នុងការធ្វើសកម្មភាពប្រឆាំងនឹងរបបសមូហភាព ។ ប៉ុន្តែផែនការនេះមិនបានសម្រេច យើងក៏បន្តវាយប្រហារការចាត់តាំងរបស់អង្គការវិញ ដោយបង្កទំនាស់នៅក្នុងមន្ទីរ គឺធ្វើយ៉ាងណាឲ្យប៉ះពាល់ដល់ចលនាបីទៅប្រាំមួយគោនរបស់អង្គការ ។ ខ្ញុំធ្វើការវាយប្រហារការចាត់តាំងនេះ ថាបក្សពួកនិយមចាក់ចុច អុជអាលមហាជនឲ្យចូលរួមធ្វើសកម្មភាពប្រឆាំងនឹងការចាត់តាំងនេះ ។ ខ្ញុំបានធ្វើសកម្មភាពបំផ្លាញសម្ភារក្នុងមន្ទីរ មាន ចប ពូថៅ ញញួរ និងបន្តបំផ្លាញដំណាំដាំដុះនៅក្នុងមន្ទីរ ។

ខ្ញុំបានលួចបំផ្លាញម៉ាស៊ីនភ្លើងនៅក្នុងមន្ទីរសិប្បកម្ម ដោយលួចដោះខ្មៅឲ្យប្រើការលែងកើត ។ ខ្ញុំបានធ្វើសកម្មភាព ចាក់ចុចអុជអាលមហាជននៅក្នុងមន្ទីរ ដោយវាយប្រហារគណៈកម្មាធិការក្រុម ក្រោមការចាត់តាំងថ្មីរបស់អង្គការថា ជាពួកឱកាសនិយមជាពួកសម្ញុំសុខ គឺធ្វើយ៉ាងណាបង្កទំនាស់នៅក្នុងមន្ទីរ ។ ខ្ញុំបានធ្វើសកម្មភាពយ៉ាងនេះរហូតដល់ថ្ងៃ១២ ខែវិច្ឆិកា ឆ្នាំ១៩៧៧ ក៏ត្រូវអង្គការចាប់ ។

**សោម ប៊ុនថន**


## រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាន និងកំពុងសរសេរអត្ថបទឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម ៖

ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥

ទូរស័ព្ទលេខៈ (៨៥៥) (១៦) ៨៧៦ ៦៩២

ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨

Email: truthsocheat@dccam.org

Home page: www.dccam.org

# ថ្នាក់រៀននៅទួលស្លែង

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតថ្នាក់រៀនសាធារណៈមួយនៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ។ ថ្នាក់រៀននេះត្រូវបានបង្កើតឡើងក្នុងខែវិច្ឆិកា ឆ្នាំ២០១១ ដោយមានកិច្ចសហការរវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។ សារមន្ទីរទួលស្លែងគឺជាអតីតសាលារៀនដ៏ទំនើបមួយដែលបានសង់ឡើងជាលើកដំបូងនៅក្នុងឆ្នាំ១៩៦២ ។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខ្មែរក្រហមបានប្រែក្លាយសាលារៀននេះទៅជាគុកដ៏សម្ងាត់បំផុតមួយក្នុងចំណោមគុកចំនួន១៩៦ទូទាំងប្រទេស ។ អ្នកទោសភាគច្រើនដែលត្រូវបញ្ជូនទៅទួលស្លែងគឺជាកម្មាភិបាលខ្មែរក្រហមដែលត្រូវបានចោទប្រកាន់ពីបទប្រព្រឹត្តអំពើក្បត់ជាតិដូចជា ការសហការជាមួយរដ្ឋាភិបាលបរទេស ឬធ្វើជាអ្នកស៊ើបការណ៍ឲ្យសេ.អ៊ី.អា ឬ កា.ហ្សេ.បេ ជាដើម ។



ចាប់តាំងពីការប្រែក្លាយពីកន្លែងរៀនសូត្រមួយទៅជាកន្លែងដ៏គួរឲ្យរន្ធត់ និងមហន្តរាយមួយ ទួលស្លែងមិនដែលទទួលបានមុខងាររបស់ខ្លួនដូចកាលពីដើមវិញឡើយ ។ ទោះជាយ៉ាងនេះក្តី នៅពេលអនាគត ដើម្បីទាមទារមកវិញនូវកេរដំណែលអប់រំដែលមានលក្ខណៈវិជ្ជមានរបស់ទួលស្លែង និងដើម្បីបន្ថែមសមាសភាពអប់រំមួយទៅក្នុងសារមន្ទីរនេះ ថ្នាក់រៀននេះ ត្រូវបានបង្កើតឡើងដើម្បីផ្តល់ការបង្រៀន និងការពិភាក្សាដោយឥតគិតថ្លៃអំពីប្រវត្តិសាស្ត្ររបបខ្មែរក្រហម និងប្រធានបទដែលជាប់ទាក់ទងដូចជា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ថ្នាក់រៀននេះ ក៏ជាវេទិកាសាធារណៈមួយសម្រាប់ឲ្យអ្នកមកទស្សនា និងអ្នកដែលនៅរស់រានមានជីវិតចែករំលែកព័ត៌មានគ្នាក្នុងការថែរក្សារយៈកាលនៃប្រវត្តិសាស្ត្រកម្ពុជាដ៏មានសារសំខាន់មួយទុកឲ្យអ្នកជំនាន់ក្រោយបានរៀនសូត្រ ។

បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ដែលមានសញ្ញាបត្រមកពីបរទេស និងបានទទួលវិញ្ញាបនបត្រពីក្រសួងអប់រំ យុវជន និងកីឡា ផ្នែកការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩) ព្រមទាំងមានការចូលរួមពីអ្នកជំនាញជាតិ និងអន្តរជាតិដែលមានជំនាញលើប្រវត្តិសាស្ត្រប្រទេសកម្ពុជា និងអ្នកដែលនៅរស់រានមានជីវិតពីមន្ទីរស-២១ នឹងបង្រៀននៅថ្នាក់រៀននេះ ។ ព័ត៌មានទាក់ទងនឹងថ្នាក់រៀននេះ សូមទាក់ទង ម៉ែន ពិចិត្រ តាមរយៈទូរសព្ទលេខ: ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែល: truthpechet@dccam.org ។

**◆ទីកន្លែង : អាគារ "ក" ជាន់លើ ◆ពេលវេលា : ច័ន្ទ ២-៣រសៀល, ពុធ ៩-១០ព្រឹក, សុក្រ ២-៣រសៀល**

# ការិយាល័យព័ត៌មានសាធារណៈ

“ការិយាល័យព័ត៌មានសាធារណៈ” របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ និងព្រឹត្តិការណ៍វិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម ។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ ។ ប្រភេទឯកសារទីពីគឺជាបទសម្ភាសដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសជាមួយជនរងគ្រោះនិងអតីតកម្មាភិបាលខ្មែរក្រហម ។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម ។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារប្រភេទទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត ។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចអាននឹងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារខ្លះទៀតរួមមាន ៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លង ព័ត៌មានដែលបានមកពីការសម្ភាសជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លិនទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ជា ផល្លា តាមរយៈ ទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែល *truthphalla.c@dccam.org* ។




















# កេរដំណែលឃុំស្រយ៉ង់ : សង្គ្រាមស៊ីវិល ចន្លោះឆ្នាំ (១៩៧៩-១៩៩៨)

### *សេចក្តីផ្តើម*

*ដោយរងការវាយប្រយុទ្ធគ្នាអស់រយៈពេលជិតពីរទសវត្សរ៍ចន្លោះឆ្នាំ (១៩៧៩-១៩៩៨) អ្នកភូមិស្រយ៉ង់ស្ថិតក្នុងជម្ងោះនៃអំពើហិង្សា បានប្រឈមនឹងការរស់រានមានជីវិត ។ ឃុំស្រយ៉ង់ត្រូវបានហែកហួរដោយសារមានការមន្ទិលសង្ស័យជុំវិញនិន្នាការនយោបាយ ដែលថាតើភូមិនោះមាននិន្នាការគាំទ្រសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលទទួលជំនួយពីកងទ័ពវៀតណាម ហើយបានផ្តួលរំលំរបបកម្ពុជាប្រជាធិបតេយ្យចេញពីអំណាចនៅខែមករា ឆ្នាំ១៩៧៩ ឬថាតើអ្នកភូមិទាំងនោះមានចូលដៃជើងជាមួយកងកម្លាំងរបស់របបកម្ពុជាប្រជាធិបតេយ្យ ។ ការប្រទាញប្រទង់គ្នានេះបានបន្ត ដោយសារតែមានការវាយប្រហារពីកងកម្លាំងរបស់សត្រូវ ។ អ្នកភូមិទាំងនោះ បានបញ្ចេញទស្សនៈពាក់ព័ន្ធនៅវេទិកាអប់រំសាធារណៈថ្នាក់មូលដ្ឋាន ដែលរៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជា នៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៤ ។ អ្នកភូមិសិស្សានុសិស្ស គ្រូបង្រៀន និងអាជ្ញាធរនៅក្នុងតំបន់ប្រមាណ ១០០នាក់ បានចូលរួមក្នុងការពិភាក្សា នៅក្នុងវត្តសាវ៉ានរង្សី ឃុំស្រយ៉ង់ ស្រុកគូលែន ខេត្តព្រះវិហារ ។ ឯកសារនេះ សង្ខេបការពិភាក្សាសាធារណៈ និងឆ្លុះបញ្ចាំងពីបទសម្ភាសលើកមុន និងលើក*



*សាលាឆាន់ វត្តសាវ៉ាន់រង្សី ស្ថិតក្នុងភូមិស្រយ៉ង់ ឃុំស្រយ៉ង់ ស្រុកគូលែន ខេត្តព្រះវិហារ*

ក្រោយជាមួយអ្នកចូលរួមគម្រោងវេទិកាអប់រំសាធារណៈថ្នាក់មូលដ្ឋាន ។ ផ្នែកចុងក្រោយ នៃរបាយការណ៍ ពិភាក្សាអំពីទស្សនៈនិងយោបល់ក្នុងការកែលម្អដល់វេទិកាអប់រំសាធារណៈថ្នាក់មូលដ្ឋាន ។

## ឃុំស្រយ៉ង់ និងការប្រទាញប្រទង់

វេទិកាអប់រំសាធារណៈថ្នាក់មូលដ្ឋាន នៅថ្ងៃទី១២ ខែមិថុនា ផ្តោតលើអំឡុងពេលនៃសង្គ្រាមស៊ីវិល ដែលបានបន្ថែមហន្តរាយដល់ជីវិតប្រជាជនកម្ពុជាជាច្រើន ។ កងកម្លាំងបដិបក្ខទាំងពីរបានបើកការវាយប្រហារគ្នាទៅវិញទៅមកដើម្បីត្រួតត្រាលើប្រជាជន ។ ការប្រទាញប្រទង់គ្នានេះ បានធ្វើឲ្យប្រជាជនមានជម្រើសតិចតួចក្រៅពីចងមិត្តភាពជាមួយកងកម្លាំងដែលនឹងមកដល់ ។ នៅក្នុងវេទិកានោះ មនុស្សចាស់ នៅភូមិកោះកែរ និងភូមិស្រយ៉ង់ ឃុំស្រយ៉ង់ បានរៀបរាប់សាច់រឿងនៅក្នុងសម័យខ្មែរក្រហម ។

ឆាយ ហៀង អាយុ៥២ឆ្នាំ រស់នៅឃុំស្រយ៉ង់ ស្រុកគូលែន ខេត្តព្រះវិហារ បានបញ្ជាក់ថា នៅខែមករា ឆ្នាំ១៩៧៩ កងកម្លាំងវៀតណាមបានមកឃុំរបស់គាត់ ។ អស់រយៈពេលជាច្រើនឆ្នាំក្រោយមក មានការប្រយុទ្ធគ្នាតិចតួចបានកើតឡើង ។ ឆាយ ហៀង បានចងចាំថា នៅឆ្នាំ១៩៨៣ ភូមិកោះកែរមិនមានមនុស្សរស់នៅនោះទេ ។ ភ្លាមៗនោះ គាត់បានរត់គេចទៅស្រុកគូលែន និងជំរំជនភៀសខ្លួនរបស់ខ្មែរក្រហមហៅថា “ជំរំ១០០៣” ក្រោមការគ្រប់គ្រងរបស់ ឈិត ជឿន ហៅ តាម៉ុក ។ ខ្មែរក្រហមបានផ្តល់ការការពារដល់អ្នកភូមិចាប់តាំងពីមានការវាយប្រហារពីវៀតណាម ។ ឆាយ ហេង បាននិយាយថា មានប្រជាជនរស់នៅប្រហែល៧០០ ដល់ ៨០០គ្រួសារ ហើយគាត់បានបោះទីតាំងនៅជម្រាលភ្នំ ។ អ្នកភូមិទាំងនោះទទួលបានភួយ និងអង្ករ ។ ទោះបីជាយ៉ាងណាក៏ដោយ ឆាយ ហៀង មិនអាចស្នាក់នៅក្នុងជំរំទេ ។ គាត់បានស្នើសុំការអនុញ្ញាតពីខ្មែរក្រហម ដើម្បីត្រឡប់មកវិញ ប៉ុន្តែវៀតណាមបានរារាំងផែនការនោះ ដោយធ្វើការវាយប្រហារជំរំ ។ ក្រោយមក មាន២០គ្រួសារ បានត្រឡប់មកវិញ ដោយមានការការពារពីយោធាខ្មែរក្រហមចំនួន៨០០នាក់ ។ កងពលធំរបស់វៀតណាម



សាលាឃុំស្រយ៉ង់ ស្ថិតនៅក្នុងស្រុកគូលែន ខេត្តព្រះវិហារ

បានរំដោះយក២០គ្រួសារនោះ ហើយឲ្យរស់នៅទីតាំងថ្មីនៅក្នុងភូមិកោះកែរ រយៈពេលប្រាំមួយខែ ។

តាមចំណាត់ការនេះ វៀតណាមបានចាប់ផ្តើមចាប់ខ្លួនមនុស្សតាមលក្ខណៈជាប្រព័ន្ធ ។ ទី១) វៀតណាមមិនជឿទុកចិត្តលើអ្នកភូមិ ចាប់តាំងពីខ្មែរក្រហមអាចរារាំងកងកម្លាំងវៀតណាមគ្រប់ពេលវេលាទាំងអស់ ។ ទី២) ឆាយ ហៀង បានលើកឡើងថា ស្ត្រីម្នាក់ឈ្មោះ ផន បានរាយការណ៍បំផ្លើស ប្រាប់វៀតណាម នៅពេលដែលគាត់អន់ចិត្តជាមួយនឹងអ្នកដទៃ ។ ការចាប់ខ្លួននេះបានបំភ័យប្រជាជន នៅភូមិកោះកែរ ។ ឆាយ ហៀង បានចងចាំថា ប្រជាជនប្រាំពីរនាក់ត្រូវបានចាប់ខ្លួន និងសួរចម្លើយ ជាមួយនឹងវិធីសាស្ត្រនៃការធ្វើទារុណកម្ម ។ មនុស្សប្រាំពីរនាក់ត្រូវបានវាយធ្វើបាប រហូតដល់អ្នកទាំងនោះ សារភាពថា មានទំនាក់ទំនងជាមួយនឹងខ្មែរក្រហម ។ ម្នាក់ក្នុងចំណោមមនុស្សប្រាំពីរនាក់អាចរត់គេចខ្លួនបាន ប៉ុន្តែវៀតណាមបានព្យាយាមតាមដានម្នាក់នោះ ។ មនុស្សប្រាំមួយនាក់ទៀតត្រូវបានបញ្ជូនទៅកាន់កោះកន្ទុយគោ ជាទីដែលអ្នកទាំងនោះត្រូវបានដាក់គុក ។ អ្នកទោសមួយចំនួនត្រូវបានទុកឲ្យលង់ទឹក នៅពេលដែលទីតាំងគុកត្រូវជន់លិចក្នុងរដូវវស្សា ។

ផេង បឹក ពិការភ្នែកខាងស្តាំដោយសារគ្រាប់មីន និងជាវាគ្មិនម្នាក់ក្នុងចំណោមវាគ្មិន ជាច្រើននៅក្នុងវេទិកា បាននិយាយរៀបរាប់បន្ថែមពីសាច់រឿងទាំងនេះ ។ គាត់បានរៀបរាប់ថា កងទ័ពវៀតណាមបានចាប់ខ្លួនប្តីរបស់គាត់ឈ្មោះ ទឹម ឌឹម ដោយចោទប្រកាន់ពីបទយកការណ៍ឲ្យខ្មែរក្រហម និងបំផ្ទុះគ្រាប់បែកនៅបន្ទាយវៀតណាម ។ ក្រោយមក ទឹម ឌឹម ត្រូវបានរាយការណ៍ថា បានស្លាប់នៅក្នុងគុកនៅឆ្នាំ១៩៨៦ ពីព្រោះគាត់ជាប់ខ្នោះនៅពេលទឹកជន់លិចគុក ។ ផេង បាននិយាយថា ប្តីរបស់គាត់គឺជាជនគ្មានកំហុស ហើយបានចូលក្នុងព្រៃដើម្បីរើសខស ។ គាត់បានប្រាប់អ្នកចូលរួមថា វាជាសំណាងអាក្រក់សម្រាប់គ្រួសាររបស់គាត់ទាំងមូល ។ នៅពេលដែលកូនទាំងពីររបស់គាត់ បានស្លាប់ដោយសារគ្រាប់បែក ភ្នែកស្តាំរបស់គាត់ត្រូវរងគ្រោះដោយសារគ្រាប់បែក ហើយក្រោយមកគាត់ក៏ខ្វាក់ ។ ផេង បានបន្តថា មួយក្នុងចំណោមកូនប្រុសរបស់គាត់ឈ្មោះ ឌឹម ឡឿន បានប្រឈមនឹងការភ័យខ្លាចចំពោះការចាប់ខ្លួន ដោយធ្វើឲ្យគាត់ផាកទៅចូលរួមជាមួយនឹងខ្មែរក្រហម ។

នៅក្នុងបទសម្ភាសវេទិកាលើកក្រោយ ក្រុមការងារគម្រោងវេទិកាអប់រំសាធារណៈថ្នាក់មូលដ្ឋានបានសម្ភាស ឌឹម អាយុ៥៧ឆ្នាំ រស់នៅភូមិកោះកែរ ឃុំស្រយ៉ង់ ។ គាត់បាននិយាយថា គាត់បានធ្វើជាយោធាខ្មែរក្រហមចាប់តាំងពីឆ្នាំ១៩៨៣ បន្ទាប់ពីបានឮការឃោសនាថា វៀតណាមវះពោះញាត់ស្មៅ និងដោយសារតែកំហឹងជុំវិញការស្លាប់របស់ឪពុកគាត់ ។ ឌឹម បាននិយាយថា គាត់បានដឹងរឿងទាំងនេះតាមរយៈអ្នកជាប់គុកម្នាក់ក្នុងចំណោមអ្នកជាប់គុក ដែលអាចរត់គេចខ្លួន និងបានរាយការណ៍ស្តីពីស្ថានភាពដ៏អាក្រក់នៅក្នុងគុក ។

ដោយសារតែស្ថានភាពកាន់តែដុនដាប មនុស្សប្រុសនៅក្នុងភូមិ ហាក់បីដូចជា មិនមានជម្រើសអ្វី ក្រៅពីរត់គេចខ្លួនចូលក្នុងព្រៃ ហើយចូលរួមជាមួយខ្មែរក្រហម ។ ឌឹម បានទុកប្រពន្ធ និងកូនប្រុសអាយុមួយឆ្នាំនៅក្នុងភូមិ ដោយសារមានតែស្ត្រីអាចស្នាក់នៅក្នុងភូមិបាន ។ ដោយសារតែមានវិធានការប្រុងប្រយ័ត្នជាមុន កងកម្លាំងវៀតណាមបានបញ្ជូនស្ត្រីទាំងនោះទៅភូមិព្យរជ្រូក ឃុំគូលែនជើង ស្រុកគូលែន ។ នៅខែមិថុនា ឆ្នាំ១៩៨៦ យោធាខ្មែរក្រហម បានធ្វើការវាយប្រហារជាយុទ្ធសាស្ត្រដើម្បីប្រមូលយកស្ត្រីទាំងនោះ ។ គ្រួសាររបស់ ឌឹម បានសម្រេចចិត្តមិនត្រឡប់មកភូមិ ប៉ុន្តែផ្ទុយទៅវិញបោះទីតាំង នៅតាមបណ្តោយភ្នំដងរែក ។ ឆាយ ហៀង បាននិយាយថា មានការវាយប្រហារគ្នា បានកើតឡើងដែលបង្កអស្ថិរភាពនៅក្នុងភូមិ ។ អ្នកភូមិជាច្រើនបានសម្រេចចិត្តចូលរួមជាមួយខ្មែរក្រហម ប៉ុន្តែអះអាងថា ខ្លួនមិនចង់ចូលរួមជាមួយអ្នកទាំងនោះទេ ។

នៅពេលពិភាក្សានៅក្នុងវេទិកាអប់រំសាធារណៈថ្នាក់មូលដ្ឋាននោះ អ្នកភូមិជាច្រើនបានបញ្ជាក់ថា ខ្លួនមិនអាចវិលត្រឡប់ទៅភូមិកំណើតរបស់ខ្លួន រហូតទាល់តែដើមទសវត្សរ៍៩០ អំឡុងសម័យអ៊ុនតាក់ និងការបញ្ចប់សង្គ្រាមស៊ីវិលចន្លោះពីឆ្នាំ១៩៩៨ ដល់ឆ្នាំ១៩៩៩ ។ ឆាយ ហៀង បាននិយាយថា ក្នុងឆ្នាំ១៩៩៣ គ្រួសាររបស់គាត់បានទទួលស្គាល់ថា កងកម្លាំងរបស់អ៊ុនតាក់ បានទាក់ទងខ្មែរក្រហមធ្វើការចរចា ប៉ុន្តែខ្មែរក្រហមបដិសេធមិនព្រមចរចា ។ ក្នុងឆ្នាំ១៩៩៩ ឆាយ ហៀង ចង់ត្រឡប់មកភូមិកោះកែរ តែត្រូវហាមឃាត់ដោយសារ ទីនោះមានគ្រាប់បែក ។ មួយឆ្នាំក្រោយមក

អ្នកភូមិទាំងនោះបានខិតខំប្រឹងប្រែងដើម្បីដោះមីន ។

ក្នុងឆ្នាំ១៩៩៩ ឌឹម បានត្រឡប់មកភូមិវិញជាមួយនឹងក្តីសង្ឃឹមដែលថា សង្គ្រាមនឹងបញ្ចប់ ។ ឌឹម បានបាត់បង់ជើងស្តាំ និងម្រាមដៃពីរដោយសារតែមីនក្នុងសម័យសង្គ្រាម មិនបានស្តីបន្ទោសនរណាទេ ចំពោះរបួស និងការស្លាប់របស់ឪពុក និងបងប្អូនប្រុសបង្កើតពីនាក់របស់គាត់ ។ គាត់គ្រាន់តែបាននិយាយថា គឺដោយសារតែសង្គ្រាម ។ ឌឹម បានឃើញការចាប់ខ្លួនឪពុករបស់គាត់ដោយផ្ទាល់ ក្នុងឆ្នាំ១៩៨៣ ប៉ុន្តែ គាត់មិនអាចធ្វើអ្វីបាននោះទេ ។ គាត់មិនបានស្តីបន្ទោស ប៉ុល ពត ចំពោះឧក្រិដ្ឋកម្មកាលពីអតីតកាល ប៉ុន្តែផ្ទុយទៅវិញបានស្តីបន្ទោសកម្មាភិបាលខ្មែរក្រហមថ្នាក់ក្រោម ដែលបានប្រព្រឹត្តអំពើយង់ឃ្នង ។

នៅពេលសួរថា តើគាត់សោកស្តាយចំពោះអ្វីកើតឡើងនៅក្នុងសង្គ្រាមស៊ីវិលចន្លោះឆ្នាំ (១៩៧៩ ដល់ ឆ្នាំ១៩៩៨)? គាត់បាននិយាយថា គាត់មិនមានអារម្មណ៍សោកស្តាយចំពោះការចូលបម្រើខាងខ្មែរក្រហមទេ ។ គាត់បានពិពណ៌នាការចូលបម្រើនោះថា ជាទង្វើជាតិនិយម ទន្ទឹមពេលអ្នកដែលស្ថិតក្នុងរបបគ្រប់គ្រងរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជា បានយល់ឃើញដូចគ្នានេះដែរ ។ ទោះបីជា ឌឹម មានការពេញចិត្តជាមួយនឹងការងាររបស់គាត់ក្នុងនាមជាប្រធានភូមិ គាត់បាននិយាយថា គាត់មានការសោកស្តាយចំពោះផលប៉ះពាល់នៃអាណានិគម និងសង្គ្រាមស៊ីវិលមកលើតំបន់ប្រាសាទកោះកែរ ។ ឆាយ ហៀង បាននិយាយថា អតីតប្រធានឃុំកោះកែរ ឈ្មោះ នឹម បានអះអាងថា អំឡុងសម័យអាណានិគមបារាំង រូបចម្លាក់ជាច្រើនត្រូវបានលួចយកចេញពីប្រាសាទ ។ គាត់ជឿថា អ្នកលួចទាំងនោះ គឺជាជនជាតិបារាំងដោយសារនៅសម័យនោះ មានតែបារាំងជាអ្នកគ្រប់គ្រង ។ ឆាយ ហៀង បានប្រាប់អ្នកចូលរួមទាំងអស់គ្នាថា នឹម គឺជាមនុស្សម្នាក់គត់ដែលបានអមដំណើរជនជាតិបារាំង ដែលមកធ្វើទស្សនកិច្ចនៅតាមប្រាសាទ ។ គាត់បានឃើញជនជាតិបារាំងទាំងនោះលួចវត្ថុបុរាណមួយចំនួន ហើយបានដាក់វត្ថុបុរាណទាំងនោះនៅក្នុងឡាន ។ ទោះបីជាយ៉ាងណាក៏ដោយ សង្គ្រាមស៊ីវិលបានជួយជនឆ្លៀតឱកាសធ្វើពាណិជ្ជកម្មលើវត្ថុបុរាណដែលលួចចេញពីប្រាសាទកោះកែរ ។ ឌឹម បានលើកជាយោបល់ថា ការគាស់ និងការលួចវត្ថុបុរាណនៅប្រាសាទកោះកែរ បានកើតឡើងច្រើននៅចន្លោះពីឆ្នាំ១៩៩០ ដល់ ឆ្នាំ១៩៩៣ ។ ឌឹម បានលើកឡើងថា កងកម្លាំងរបស់គាត់ ត្រូវបានណែនាំមិនឲ្យធ្វើពាណិជ្ជកម្មលើរូបចម្លាក់នោះទេ ។ អ្នកដែលបំពានច្បាប់នោះ នឹងត្រូវបាញ់សម្លាប់ចោល ។ ផងមិនមានយោបល់លើការពោលអះអាងនោះទេ ប៉ុន្តែបានឆ្ងល់ថា តើហេតុអ្វីបានរូបចម្លាក់ជាច្រើនបានបាត់ចេញពីប្រាសាទ នៅពេលដែលគាត់ត្រឡប់មកភូមិកំណើតវិញក្នុងឆ្នាំ ១៩៩៩?

## ចំណាប់អារម្មណ៍ចំពោះវេទិកាសាធារណៈ

បន្ទាប់ពីបានឮការពិពណ៌នានោះ អ្នកចូលរួមជាច្រើនមានសេរីភាពក្នុងការបញ្ចេញទស្សនៈផ្សេងៗគ្នា ស្តីពីប្រធានបទក្នុងការពិភាក្សា ដូចជា ការលួច និងការធ្វើពាណិជ្ជកម្មលើវត្ថុបុរាណ ។


ខុន សុណៃ

ខុន សុណៃ អាយុ១៦ឆ្នាំ និងជាសិស្សថ្នាក់ទី៩ នៅវិទ្យាល័យស្រយង់ បាននិយាយថា ខ្លួនមានការសប្បាយរីករាយដែលបានចូលរួមវេទិកានេះ ។ គាត់បានប្រាប់ថា ឪពុករបស់គាត់ខឹងសម្បា គាត់ដោយមិនព្រមជួយក្នុងមុខជំនួញឪពុករបស់គាត់ថ្ងៃនោះ ។ សុណៃ បាននិយាយថា «យើងទាំងអស់គ្នាមានសំណាងដែលបានកើតក្នុងសម័យនេះ ប្រសិនបើប្រៀបធៀបជាមួយគាត់» ។ សុណៃ បានបន្តថា នៅពេលដែលលើកឡើងពីការប្រៀបធៀបនេះ វាជាការលើកទឹកចិត្តឲ្យខ្លួនលែងខ្ជិលច្រអូសទៀត ។ សុណៃ បានឮអ្នកជិតខាងនិយាយអំពីការប្រយុទ្ធគ្នាដោយគ្រាប់កាំភ្លើងឆេះផ្ទះ និងការរត់លាក់ខ្លួននៅក្នុងត្រង់សេ ។ ម្តាយរបស់ សុណៃ បានប្រាប់ថា បងប្រុសធំរបស់ សុណៃ ឈ្មោះ អេង សុគី (បច្ចុប្បន្នអាយុ៥០ឆ្នាំ) បានបាត់ខ្លួននៅក្នុងកងពលធំរបស់ខ្មែរក្រហម ។ សុណៃ បានដឹងអំពីការជំនុំជម្រះមេដឹកនាំខ្មែរក្រហម និងទទួលស្គាល់អំពីសារសំខាន់នោះ ដោយសារខ្មែរក្រហមទាំងនោះបានបំផ្លិចបំផ្លាញសង្គមកម្ពុជា ។ សុណៃ បានស្នើជាយោបល់ថា វេទិកាលើកក្រោយ គួរតែធ្វើឡើងនៅតាមតំបន់ដាច់ស្រយាល ដើម្បីបង្កើនការយល់ដឹងអំពីប្រវត្តិសាស្ត្រ

ប្រទេសកម្ពុជា ។

ហ៊ុយ អាត អាយុ៤៨ឆ្នាំ ស្ថិតនៅក្នុងភូមិស្រយ៉ង់ខាងត្បូង ឃុំស្រយ៉ង់ ខេត្តព្រះវិហារ បាននិយាយថា ជាការប្រសើរ ដែលឲ្យមនុស្សពិភាក្សាអំពីប្រវត្តិសាស្ត្រ ។ ការពន្យល់ និងការនិទានអំពីសាច់រឿងនោះ មានអត្ថប្រយោជន៍ក្នុងការយល់ដឹងអំពីថាតើមនុស្សចាស់ទទួលរងទុក្ខទោសពីរបបខ្មែរក្រហមដោយរបៀបណា ។ ទាក់ទងនឹងសង្គ្រាមស៊ីវិល ហ៊ុយ អាត បានពិពណ៌នាអំពីមូលហេតុ ដែលគាត់មិនអាចទៅរៀននៅសាលាបាន ។ គាត់មានការខកចិត្តចំពោះសង្គ្រាម ដែលបានអូសបន្លាយនៅស្រយ៉ង់ ។ គាត់មានការសោកស្តាយដែលសហគមន៍របស់គាត់ត្រូវរងនឹងគ្រាប់មីន ជំងឺគ្រុនចាញ់ និងការប្រយុទ្ធគ្នារវាងយោធាខ្មែរក្រហម និងកងកម្លាំងរដ្ឋាភិបាល ។ ប្រជាជនរងគ្រោះថ្នាក់ ឬស្លាប់ នៅពេលដែលមានការប្រយុទ្ធគ្នា ។ ប្រជាជនបានរៀបចំបង្វេចរួចរាល់ហើយ ដូច្នេះប្រជាជនទាំងនោះ បានភៀសខ្លួនភ្លាមៗ នៅពេលមានការទទួលដំណឹងពីការវាយប្រហារនោះ ។ បន្ទាប់ពីបញ្ចប់សង្គ្រាម ហ៊ុយ អាត បានត្អូញត្អែរចំពោះបញ្ហារឹបអូសដីធ្លីតាមរយៈក្រុមហ៊ុន ។


ហ៊ុយ អាត

ឌឹម បាន អាយុ៤៦ឆ្នាំ រស់នៅភូមិកោះកែរ ឃុំស្រយ៉ង់ បានបង្ហាញការពេញចិត្តរបស់ខ្លួន កាលដែលសង្គ្រាមបានបញ្ចប់ និងពេញចិត្តវេទិកាសាធារណៈនេះដែលបានផ្តល់ឱកាសល្អ និងបានពន្យល់អំពីសង្គ្រាមដល់សិស្ស ។ អ្នកភូមិនីមួយៗ បានឆ្លងកាត់នូវបទពិសោធនៃការរត់គេចខ្លួន ។ ដោយសារតែសង្គ្រាមរវាង ខ្មែរក្រហម និងកងកម្លាំងវៀតណាម អ្នកភូមិបានត្រាច់ចរពីកន្លែងមួយ ទៅកន្លែងមួយទៀត ។ ឌឹម បាននិយាយថា គាត់មិនអាចត្រឡប់ទៅភូមិកំណើតរបស់គាត់បាននោះទេ បន្ទាប់ពីសង្គ្រាម ។ នៅពេលដែលគាត់ត្រឡប់មកផ្ទះវិញ គាត់មានភាពតក់ស្លុត ដោយសារប្រាសាទកោះកែរ រងការបំផ្លិចបំផ្លាញ ។ ទាក់ទងនឹងការជំនុំជម្រះនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គាត់បានដឹងអំពីព័ត៌មាននេះ តែគាត់មិនអាចតាមដានកិច្ចដំណើរការនោះទាំងមូលនោះទេ ។


ឌឹម បាន

សុត ណាក់ អាយុ៤៣ឆ្នាំ មកពីភូមិស្រយ៉ង់ខាងត្បូង ឃុំស្រយ៉ង់ បាននិយាយថា វេទិកាអប់រំសាធារណៈថ្នាក់មូលដ្ឋានមានសារសំខាន់ ដោយសារវេទិកានោះអនុញ្ញាតឲ្យប្រជាជនពិភាក្សា អំពីបញ្ហាទាក់ទងនឹងខ្មែរក្រហម ។ ការជម្លៀសរបស់ខ្មែរក្រហម និងកងកម្លាំងវៀតណាមបានបង្កទុក្ខលំបាកដល់ប្រជាជន ជាពិសេស អ្នកភូមិកោះកែរ ។ ប្រជាជនបានទទួលរងទុក្ខចំពោះ ការប្រយុទ្ធគ្នាដោយសព្វាវុធ គ្រាប់មីន និងការបាញ់ផ្លោង ។ មនុស្សមួយចំនួនរងគ្រោះថ្នាក់ ឬស្លាប់ ។ សុត ណាក់ បានលើកជាយោបល់ថា ដោយសារខ្មែរក្រហមបានប្រព្រឹត្តទង្វើឃោរឃៅ ខ្មែរក្រហមទាំងនោះសមទទួលការជំនុំជម្រះ ។


សុត ណាក់

ចិន ហឿន អាយុ៤៩ឆ្នាំ មកពីភូមិស្រយ៉ង់ខាងត្បូង ឃុំស្រយ៉ង់ បាននិយាយថា វេទិកានេះមានសារសំខាន់សម្រាប់យុវវ័យ និងសិស្សានុសិស្ស ។ សាច់រឿងអំពីប្រជាជនដែលចាកចេញពីភូមិជាច្រើនឆ្នាំ កើតឡើងដោយសារសង្គ្រាមរវាងខ្មែរក្រហម និងកងកម្លាំងវៀតណាម ។ ប្រជាជនត្រូវតែរត់ទៅក្នុងព្រៃ ។ ប្រជាជនមួយចំនួនបានស្លាប់ដោយសារការផ្ទុះគ្រាប់មីន និងមួយចំនួនទៀតបាន ក្លាយជាជនពិការ និងបាត់បង់ទ្រព្យសម្បត្តិ ។


ចិន ហឿន

ម៉ម ច័ន្ទមារ៉ាឌី អាយុ១៦ឆ្នាំ និងជាសិស្សថ្នាក់ទី៨ នៅ


ម៉ម ច័ន្ទមារ៉ាឌី

អនុវិទ្យាល័យស្រយ៉ង់ បាននិយាយថា ខ្លួនមានចិត្តសប្បាយរីករាយ ដែលបានចូលរួមក្នុងវេទិកាអប់រំសាធារណៈថ្នាក់មូលដ្ឋាន ។ មារ៉ាឌី បាននិយាយថា "ក្នុងនាមជាប្រជាជនកម្ពុជា យើងត្រូវការដឹងអំពីប្រវត្តិសាស្ត្ររបស់យើង ជាពិសេសប្រវត្តិសាស្ត្ររបស់សហគមន៍យើង ។ ប្រទេសរបស់យើងបានធ្លាក់ចូលក្នុងរបបប្រល័យពូជសាសន៍" ។ មារ៉ាឌី បានពន្យល់ថា វាមិនមែនជារឿងល្អ នៅពេលដែលវៀតណាម និងយោធាខ្មែរក្រហម បានវាយប្រហារគ្នាទៅវិញទៅមក ដើម្បីគ្រប់គ្រងប្រជាជន ។ ប្រជាជនបានរងគ្រោះថ្នាក់ នៅពេលដែលមានការប្រយុទ្ធគ្នាដោយសព្វាវុធ ។ មារ៉ាឌី បាននិយាយថា ប្រទេសកម្ពុជា និងប្រទេសវៀតណាម មិនមានទំនាក់ទំនងល្អក្នុងប្រវត្តិសាស្ត្រនោះទេ ។ ប្រទេសវៀតណាម បានរួមចំណែកដល់ការបង្កើតខ្មែរក្រហម ដោយជួយឲ្យខ្មែរក្រហមទទួលបានជ័យជម្នះ រួចបណ្តេញខ្មែរក្រហមចេញពីអំណាច ហើយក្រោយមក ប្រកាសខ្លួនជាអ្នកជួយរំដោះ ។ ក្នុងទិដ្ឋភាពផ្សេង សង្គ្រាមបានបំផ្លិចបំផ្លាញដល់ប្រទេសរបស់យើង ។ រូបចម្លាក់នៅប្រាសាទកោះកែរ ត្រូវបានលួច ក្រៅពីការបំផ្លិចបំផ្លាញដែលបណ្តាលមកពីសង្គ្រាម ។ ទោះបីជាយ៉ាងណាក៏ដោយ មារ៉ាឌី បានសង្កត់ធ្ងន់ថា ការជំនុំជម្រះមេដឹកនាំខ្មែរក្រហមទាំងនោះ គឺជារឿងត្រឹមត្រូវ ។

ហ៊ីង តារា អាយុ១៥ឆ្នាំ ជាសិស្សថ្នាក់ទី៨អនុវិទ្យាល័យស្រយ៉ង់ បាននិយាយថា វេទិកានោះមានសារសំខាន់សម្រាប់សិស្សានុសិស្ស ដើម្បីយល់ដឹងអំពីប្រវត្តិសាស្ត្រ និងហេតុផលនៅពីក្រោយការរងទុក្ខរបស់ប្រទេសកម្ពុជា ។ ប្រជាជនមាននិន្នាការខុសគ្នា ។ អ្នកខ្លះកាន់ខាងរដ្ឋាភិបាល និងអ្នកខ្លះទៀតកាន់ខាងកងកម្លាំងវៀតណាម ឬខ្មែរក្រហម ។ ដោយសារតែសង្គ្រាម សម្បត្តិវប្បធម៌របស់យើងនៅប្រាសាទកោះកែរ ត្រូវបានលួច ហើយត្រូវបានបញ្ជូនទៅកាន់ប្រទេសដទៃជុំវិញពិភពលោក ។

ចំពោះបញ្ហាដទៃ តារា បាននិយាយថា ជួនកាល គាត់តាមដានកិច្ចដំណើរការនីតិវិធីនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ តារា បានចងចាំចំពោះសំណួរអំពីមូលហេតុថាដែលខ្មែរក្រហមសម្លាប់ប្រជាជនខ្លួនឯង ។ ចម្លើយចំពោះសំណួរនោះ បានធ្វើឲ្យ តារា ខកចិត្តយ៉ាងខ្លាំង ដោយសារមេដឹកនាំខ្មែរក្រហម គ្រាន់តែនិយាយថា ជាមាគ៌ាខុសឆ្គងក្នុងការគ្រប់គ្រងប្រទេសកម្ពុជាកាលគ្រានោះ ។

កញ្ញា ជូលី ខនហ្សៀល អ្នកស្ម័គ្រចិត្តផ្នែកច្បាប់មកពីសកលវិទ្យាល័យមីឈីហ្គេន បានចូលរួមជាមួយក្រុមការងារនៃគម្រោងវេទិកាអប់រំសាធារណៈថ្នាក់មូលដ្ឋាន ។ ជូលី បាននិយាយថា ៖

ខ្ញុំមានចំណាប់អារម្មណ៍ចំពោះការរៀបចំ ប្រសិទ្ធភាព និងការងារជាក្រុម ។ សមាជិកនីមួយៗហាក់បីដូចជាដឹងអំពីតួនាទីរបស់ខ្លួនក្នុងដំណើរការនេះ ហើយមានបំណងចង់ជួយក្រុមដោយអស់ពីលទ្ធភាព ។ ការរៀបចំវេទិកា រួមមាន ការសម្ភាសនៅតាមភូមិ ហើយវេទិកានោះបានដំណើរការទៅយ៉ាងរលូន ថ្វីបើមានភ្លៀង និងមានការពន្យារពេល ។ ការគួរឲ្យចាប់អារម្មណ៍នោះ គឺការធ្វើការងាររបស់ក្រុមការងារគម្រោងវេទិកាអប់រំសាធារណៈថ្នាក់មូលដ្ឋាន ។ សមាជិកក្នុងក្រុមទាំងអស់ បានចូលរួមជាមួយប្រជាជនក្នុងសហគមន៍យ៉ាងស្និទ្ធ ដោយអង្គុយជាមួយប្រជាជនក្នុងសហគមន៍ ដូចជាមិត្តភក្តិ និងបង្ហាញអំពីចំណាប់អារម្មណ៍ចំពោះសាច់រឿងរបស់ប្រជាជនទាំងនោះ ដោយបានជួយសម្របសម្រួលឲ្យប្រជាជនទាំងនោះឆ្លុះបញ្ចាំងអំពីសាច់រឿង និងទិដ្ឋភាពស្តីពីប្រវត្តិសាស្ត្រកម្ពុជា ។

នៅពេលរសៀលមុនការបើកវេទិកានោះ ក្រុមការងារនៃគម្រោងនេះ បានធ្វើដំណើរជុំវិញភូមិ សម្ភាសមនុស្សចាស់ ដែលរស់នៅក្នុងសហគមន៍ចាប់តាំងពីទសវត្សរ៍៧០ ដល់ទសវត្សរ៍៩០ ។ ក្រុមការងារនោះបានចងក្រងសាច់រឿងរបស់ប្រជាជននីមួយៗក្នុងសម័យនោះ និងកាលដែលប្រជាជនទាំងនោះត្រូវរងផលប៉ះពាល់ដោយការឈ្លានពាន ។ តាមទស្សនៈរបស់ខ្ញុំ ការធ្វើដំណើរនេះមានសារសំខាន់ចំពោះភាពជោគជ័យនៃវេទិកានេះ ។ ដោយមានការសម្ភាសទាំងនេះ ក្រុមការងារគម្រោងវេទិកាអប់រំសាធារណៈថ្នាក់មូលដ្ឋាន បានរៀនសូត្រអំពីប្រវត្តិសាស្ត្រនៃភូមិស្រយ៉ង់

ហើយក៏អញ្ជើញអ្នកភូមិទាំងនេះមកចែករំលែកសាច់រឿងផ្ទាល់របស់ខ្លួនជាមួយនឹងសិស្សនៅវេទិកាទៀត ។ ទាំងនេះអាចធ្វើឲ្យវេទិកានេះ ផ្តោតលើសហគមន៍ ទន្ទឹមពេលដែលផ្តល់ឱកាសឲ្យសិស្សមើលឃើញរបបនេះ ប៉ះពាល់ដល់ជីវិតរបស់ប្រជាជន ។ ទិដ្ឋភាពនៃវេទិកានេះ មានសារសំខាន់ ដោយសារតែវាបង្ហាញសហគមន៍ពីរបៀបដែលប្រជាជនទាំងអស់អាចរៀនសូត្រពីគ្នាទៅវិញទៅមក និងពីរបៀបដែលប្រជាជនទាំងនោះអាចបន្តការពិភាក្សាដ៏សំខាន់បន្ទាប់ពីវេទិកានេះបានបញ្ចប់ ។

វេទិកានេះ មានការរៀបចំបានយ៉ាងល្អប្រសើរ ដោយចាប់ផ្តើមជាមួយក្រុមធំ ដើម្បីពិភាក្សាអំពីប្រវត្តិសាស្ត្រទូទៅ ហើយក្រោយមក មានការបំបែកជាក្រុមតូចដើម្បីពិភាក្សា ដើម្បីជាគំរូនៃការបង្រៀនល្អ ។ ដោយសារតែត្រូវបានពន្យារពេលវេលា ការពិភាក្សាត្រូវបំព្រួញ ប៉ុន្តែវេទិកានេះ នៅតែមានលក្ខណៈរលូន ។ ខ្ញុំមានការព្រួយបារម្ភចំពោះការពិភាក្សារយៈពេលវែង ដែលអាចធ្វើឲ្យបាត់បង់ការផ្តោតអារម្មណ៍ ។

ការស្នើជាយោបល់មួយចំនួនរបស់ខ្ញុំសម្រាប់ការកែលម្អរួមមានការចាប់ផ្តើមវេទិកា តាមរយៈការស្នើសុំឲ្យអ្នកចូលរួមម្នាក់ៗសរសេរអំពីអ្វីដែលខ្លួនយល់ដឹងអំពីរបបខ្មែរក្រហម និងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា និងសាច់រឿងរបស់ភូមិនេះក្នុងសម័យខ្មែរក្រហម ។ អ្នកចូលរួមមួយចំនួនគួរតែចែករំលែកចំណាប់អារម្មណ៍ជាមួយនឹងក្រុមធំ ។ គំរូនេះ គឺជាកត្តាជំរុញដ៏សំខាន់ដើម្បីធ្វើការពិភាក្សា ដោយសារវាអនុញ្ញាតឲ្យប្រជាជនក្នុងសហគមន៍ចាប់ផ្តើម និងតម្រែតម្រង់ការពិភាក្សា ។ អ្នកសម្របសម្រួលនឹងអាចយល់ដឹងកាន់តែច្បាស់អំពីសហគមន៍នោះក្នុងសម័យខ្មែរក្រហម ហើយអាចបញ្ចូលការពិភាក្សាបន្ថែមទៀត ។ វាមានសារសំខាន់សម្រាប់ប្រជាជន ដើម្បីឆ្លុះបញ្ចាំងអំពីអ្វីដែលខ្លួនដឹង ឬអ្វីដែលខ្លួនមិនបានដឹងអំពីប្រវត្តិសាស្ត្រប្រទេសកម្ពុជា និងប្រៀបធៀបប្រវត្តិសាស្ត្រទៅនឹងអ្វីដែលខ្លួនបានរៀនសូត្រពីវេទិកានេះ ។

នៅពេលបញ្ចប់ការពិភាក្សា ហើយលើកទឹកចិត្តដល់អ្នកសម្របសម្រួលនាំយកក្រុមពិភាក្សានេះមកចែករំលែកជាមួយនឹងក្រុមដទៃទៀតចំពោះអ្វីដែលក្រុមនោះបានរៀនសូត្រ ។ ក្រុមនីមួយៗគួរតែជ្រើសរើសអ្នកតំណាងម្នាក់ ឬពីរនាក់ ដើម្បីធ្វើការសង្ខេបលើការពិភាក្សាជាមួយនឹងក្រុមធំ ។ អ្នកសម្របសម្រួលគួរតែបូកសរុបការពិភាក្សានៅក្នុងវេទិកា ដោយឲ្យអ្នកចូលរួមម្នាក់ៗសរសេរអំពីអ្វីដែលខ្លួនបានរៀនសូត្រពីវេទិកា ។ អ្នកសម្របសម្រួលគួរតែផ្តល់អ្វីមួយដល់ប្រជាជនក្នុងសហគមន៍ស្តីពីការពិភាក្សា ដោយសង្កត់ធ្ងន់លើសារសំខាន់នៃការពិភាក្សាដោយខ្លួនឯង ។ សរុបមកវិញ យើងមានចំណាប់អារម្មណ៍ចំពោះវេទិកា ហើយជឿថា វាជាទិដ្ឋភាពដ៏សំខាន់នៃការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលនឹងថែរក្សាប្រវត្តិសាស្ត្រ និងជំរុញពាក្យស្លោក "មិនកើតឡើងសាជាថ្មីម្តងទៀតទេ" ។

## សេចក្តីសន្និដ្ឋាន

វេទិកាអប់រំសាធារណៈថ្នាក់មូលដ្ឋាននៅថ្ងៃទី១២ ខែមិថុនា ក្នុងឃុំស្រយ៉ង់ បានប្រព្រឹត្តឡើងដោយជោគជ័យ ដោយបង្ហាញអំពីឥទ្ធិពលនៃសង្គ្រាមមកលើជីវិតរបស់មនុស្ស និងបេតិកភណ្ឌវប្បធម៌របស់ប្រទេសកម្ពុជា ។ អ្នកចូលរួមក្នុងវេទិកានោះ បានលើកឡើងថា សុវត្ថិភាពរបស់មនុស្ស ស្ថិតក្រោមការគំរាមកំហែងដោយសារកងកម្លាំងបដិបក្ខទាំងពីរបានព្យាយាមគ្រប់គ្រងប្រជាជន ។ ការវាយប្រហារដោយសព្វាវុធ បានធ្វើឲ្យជីវិតរបស់មនុស្សស្ថិតក្នុងគ្រោះថ្នាក់ ។ ចំនួនអ្នករងគ្រោះថ្នាក់ និងស្លាប់ត្រូវបានរាយការណ៍គ្រប់ពេលវេលា ។ ការកសាងសហគមន៍ជាថ្មី ប្រឈមនឹងការងារគ្រោះថ្នាក់ជាច្រើន ដូចជា គ្រាប់មីន យុទ្ធភណ្ឌមិនទាន់ផ្ទុះនៅគ្រប់ទីកន្លែង ។ ដោយសារ ប្រការនេះបានគំរាមកំហែងដល់ការចិញ្ចឹមជីវិត អ្នកភូមិទាំងនោះមិនមានជម្រើសណាក្រៅពីប្រថុយប្រថាន ជីវិតដោះមីនចេញពីដីកសិកម្មនោះទេ ។ ម្យ៉ាងវិញទៀត ប្រជាជនជឿថា ឥទ្ធិពលនៃសង្គ្រាមស៊ីវិល បានធ្វើឲ្យបេតិកភណ្ឌវប្បធម៌រងការលួច និងការធ្វើពាណិជ្ជកម្មខុសច្បាប់ ក្រៅពីវត្ថុបុរាណទាំងនោះរងការបំផ្លិចបំផ្លាញក្នុងសម័យអាណានិគមបារាំង ។ ការបាត់បង់វត្ថុបុរាណទាំងនោះ គឺជាទុក្ខសោក និងជាការសោកស្តាយសម្រាប់ប្រជាជនកម្ពុជា និងមនុស្សជាតិទាំងអស់ ។ ការយកវត្ថុបុរាណ ត្រឡប់ទៅកន្លែងដើមវិញ គឺជាការស្តារអត្តសញ្ញាណរបស់មនុស្សជាតិ ។

**លី សុខឃាង**

# វេទិកាអប់រំសាធារណៈពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ











# នៅស្រុកគូលែន ខេត្តព្រះវិហារ ក្នុងខែមិថុនា ឆ្នាំ២០១៤











# ពិធីសម្ពោធការតាំងពិព័រណ៍ស្តីពីការជម្លៀសប្រជាជនរ
# ខេត្តបន្ទាយមានជ័យ ពីថ្ងៃទី២៣










# ដោយបង្ខំ ក្នុងរបបខ្មែរក្រហម នៅខេត្តបាត់ដំបង និង ដល់ ២៨ ខែមិថុនា ឆ្នាំ២០១៤












MONGKUL BOREI STATION
DOUNG SEAN, PURSAT PROVINCE


MEMORIAL, BURIAL SITE, AND PRIS
RUSSEI DISTRICT, BATTAMBA




WAT BANTEAY NEANG SECURITY CENTER
PHNOM VILLAGE, BANTEAY NEANG COMMUNE,
MONGKUL BOREI DISTRICT,
BANTEAY MEANCHEY PROVINCE

# ពិធីបើកសម្ពោធពិព័រណ៍ស្តីអំពី «ការជម្លៀសដោយបង្ខំនៅក្នុងរបបខ្មែរក្រហម»

## *សេចក្តីផ្តើម*

*ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងមជ្ឈមណ្ឌលឯកសារកម្ពុជាបានរួមគ្នាបង្កើត និងសម្ពោធ ពិព័រណ៍ពីរអំពីប្រវត្តិសាស្ត្រខ្មែរក្រហម ដែលមានចំណងជើងថា "ការជម្លៀសដោយបង្ខំ : ការជម្លៀសប្រជាជនលើកទី២នៅអំឡុងពេលរបបខ្មែរក្រហម" នៅឯសារមន្ទីរខេត្តបាត់ដំបង និងសារមន្ទីរខេត្តបន្ទាយមានជ័យ នៅថ្ងៃទី២៤ និង២៧ ខែមិថុនា ឆ្នាំ២០១៤ ។ ពិព័រណ៍នេះ គឺជាផ្នែកមួយនៃគម្រោងសំណង ដែលដើមបណ្តឹងរដ្ឋប្បវេណីនៃសំណុំរឿង០០២/០១ របស់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមបានស្នើសុំ ។ សំណុំរឿង០០២/០១ ផ្តោតទៅលើការជម្លៀសប្រជាជនដោយបង្ខំនៅក្នុងរបបខ្មែរក្រហម និងឧក្រិដ្ឋកម្មទាំងឡាយដែលបានកើតឡើងនៅទួលពោធិ៍ជ្រៃ ។ ពិព័រណ៍នេះ ក៏ជាលទ្ធផលនៃកិច្ចសហការរវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្នុងការបង្កើតពិព័រណ៍ស្តីអំពីរបបខ្មែរក្រហមដែលធ្វើឲ្យសមស្របនឹងតំបន់នីមួយៗ ដើម្បីទាក់ទាញអ្នកទស្សនាថ្មីៗ និងបង្កើនតួនាទីស្រាវជ្រាវឯកសារពីសម័យខ្មែរក្រហមរបស់សារមន្ទីរ២៤ខេត្តក្រុង ។*

*ចំនួនប្រជាជនដ៏ច្រើនត្រូវបានជម្លៀសតាមរថភ្លើងឆ្ពងកាត់ទីកន្លែងផ្សេងៗគ្នាក្នុងប្រទេស ។ គ្រួសារត្រូវបែកចេញពីគ្នា និងចាត់ចែងឲ្យធ្វើការនៅតាមការដ្ឋានការងារ និងនៅតាមសហករណ៍*



*ពិធីបើកសម្ពោធពិព័រណ៍ស្តីពីការជម្លៀសដោយបង្ខំក្នុងរបបខ្មែរក្រហម នៅសារមន្ទីរ ខេត្តបាត់ដំបង នៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៤*

ដែលភាពអត់ឃ្លាន ការសម្លាប់ និងការធ្វើការងារជាទម្ងន់កំពុងតែរង់ចាំប្រជាជនទាំងនោះ ។ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងមជ្ឈមណ្ឌលឯកសារកម្ពុជាបានសម្រេចជ្រើសយកពិព័រណ៌តាមរថភ្លើងដែលជាគំនិតសាមញ្ញដើម្បីភ្ជាប់ពិព័រណ៌នៅតាមសារមន្ទីរខេត្តនីមួយៗ ។ មាតិការបស់ពិព័រណ៌ គឺផ្តោតលើបទពិសោធប្រជាជនកម្ពុជាទាំងក្នុងអំឡុងពេលនៃការជម្លៀសដោយបង្ខំ និងលទ្ធផលក្រោយពីការជម្លៀសចំនួនប្រជាជនដ៏ច្រើនលើសលប់ ។ ក្នុងពេលជាមួយគ្នានេះ ពិព័រណ៌នេះក៏ជះឥទ្ធិពលដល់ជីវិតរបស់អតីតកម្មាភិបាលខ្មែរក្រហម ដែលធ្លាប់បម្រើការនៅតាមស្ថានីយរថភ្លើងជាច្រើន នៅតាមតំបន់សំខាន់ៗរបស់ខ្មែរក្រហម ។ អតីតកម្មាភិបាលក៏បានទទួលស្គាល់ពីការមកដល់នៃចំនួនប្រជាជនដ៏ច្រើន ទុកសម្រាប់ធ្វើការនៅសហករណ៍ និងការដ្ឋានការងារ ។ ពិព័រណ៌នេះ ក៏បានគូសបង្ហាញរួមគ្នាពីប្រវត្តិសាស្ត្រអតីតគុកខ្មែរក្រហម ទីតាំងបញ្ចុះសព និងបូជនីយដ្ឋាន ។

ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងមជ្ឈមណ្ឌលឯកសារកម្ពុជាមានក្តីសង្ឃឹមថា នៅពេលដែលបាននាំយករឿងរ៉ាវតាមមូលដ្ឋានទៅតាំងបង្ហាញនៅតាមសារមន្ទីរខេត្ត ប្រជាជនកម្ពុជាដែលរស់នៅតាមភូមិនៅតាមបណ្តាខេត្តនឹងមានសិទ្ធិក្នុងការនិយាយពីបទពិសោធរបស់គាត់នៅពេលដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម ។ យើងក៏មានក្តីសង្ឃឹមថា ពិព័រណ៌នេះនឹងញុះញង់ឲ្យមានការសន្ទនា និងការផ្លាស់ប្តូររវាងជនដែលនៅរស់រានពីជំនាន់មុន និងប្រជាជនកម្ពុជាជំនាន់ក្រោយ ដែលកើតក្រោយឆ្នាំ១៩៧៩ ។

ចំណុចសំខាន់នៃការតាំងពិព័រណ៌នៅតាមបណ្តាខេត្ត គឺដើម្បីផ្តល់ជាកិត្តិយសដល់រឿងរ៉ាវរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកដើមចោទដែលបានមកចូលរួមយ៉ាងក្លាហាននៅក្នុងដំណើរការសវនាការតាមរយៈការប្រាប់ជារឿងរ៉ាវ ឬការនិយាយនៅក្នុងតុលាការ ។ អ្នកដែលនៅរស់រានមានជីវិត ក៏បានផ្តល់ជាសំឡេងដល់ជនទាំងឡាយដែលត្រូវបានសម្លាប់ ឬបាត់ខ្លួន ។

មានអ្នកភូមិ ដើមបណ្តឹងរដ្ឋប្បវេណី និងដើមចោទ២៥០ នាក់ ជនដែលនៅរស់រានពីរបបខ្មែរក្រហម និងសិស្សានុសិស្សវ័យក្មេង រួមទាំងប្រធាន ឬ អ្នកតំណាងពីមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ប្រធានសារមន្ទីរខេត្តបាត់ដំបង និងបន្ទាយមានជ័យ និងអ្នកតំណាងផ្នែកទទួលបន្ទុកជួយជនរងគ្រោះមកពីសាលាក្តីខ្មែរក្រហម បានចូលរួមពិធីបើកសម្ពោធពិព័រណ៌នៅសារមន្ទីរ ខេត្តបាត់ដំបង និងបន្ទាយមានជ័យ ។

## ប្រវត្តិ

ចន្លោះឆ្នាំ១៩៧០ រហូតដល់ឆ្នាំ១៩៧៥ ប្រជាជនបានភៀសខ្លួនរត់មកជ្រកកោននៅទីក្រុងភ្នំពេញ ដើម្បីជៀសផុតពីសង្គ្រាមរវាងកងទ័ព លន់ នល់ និងខ្មែរក្រហម ។ ជាលទ្ធផល ចំនួនប្រជាជន បានកើនឡើងយ៉ាងឆាប់រហ័សរហូតដល់រាប់លាននាក់នៅទីក្រុងភ្នំពេញ ។

កងទ័ពខ្មែរក្រហមបាន ចូលកាន់កាប់ទីក្រុងភ្នំពេញនៅថ្ងៃទី ១៧ ខែមេសា ឆ្នាំ១៩៧៥ ហើយចាប់ផ្តើមប្រើពាក្យ “ជម្លៀស” ដែលបន្ទាប់មកប្រើពាក្យ “ជម្លៀសដោយបង្ខំ” ។ នៅពេលនោះ ទីក្រុងភ្នំពេញបានប្រែក្លាយជាទីក្រុងដ៏ស្ងាត់ជ្រងំគ្មានមនុស្សរស់នៅ ។ បុរសស្ត្រីគ្រប់ស្រទាប់ វណ្ណៈ មនុស្សចាស់ កុមារាកុមារី ព្រះសង្ឃ និងដូនជី ព្រមទាំងសាសនិកជនដទៃទៀត អ្នកជំងឺព្យាបាលនៅមន្ទីរពេទ្យ ស្ត្រីមានផ្ទៃពោះ ឬស្ត្រីដែលទើបនឹងសម្រាលកូនរួច ត្រូវបានបង្ខំឲ្យចាកចេញពីទីក្រុង ។ ប្រជាជនជាច្រើនត្រូវបង្ខំឲ្យចាកចេញដោយថ្មើរជើងឆ្ពោះទៅកាន់ផ្លូវជាតិនានាគ្រប់ទិសទី ជើង ត្បូង លិច កើត ។ ប្រជាជន បានធ្វើដំណើរទៅមុខដោយមិនបានដឹងពីគោលដៅច្បាស់លាស់ ហើយភាគច្រើនត្រូវបានប្រាប់ថា ឲ្យទៅនៅស្រុកកំណើតរបស់ខ្លួនវិញ ។ ប្រជាជនដែលជម្លៀសមកពីក្រុងភ្នំពេញត្រូវបានសម្គាល់ថា ជា “ប្រជាជនថ្មី” ឬ “ប្រជាជន១៧ មេសា” នៅពេលដែល “ប្រជាជនមូលដ្ឋាន” ត្រូវបានចាត់ទុកថា ជាមនុស្សគួរឲ្យទុកចិត្តបាន និងស្មោះត្រង់ជាមួយអង្គការបដិវត្តន៍ ។ ប្រជាជនដែលជាប់ពាក់ព័ន្ធនឹងជីវិតអ្នកទីក្រុងបែបបស្ចិមប្រទេស ឬសម្បូរទ្រព្យធន ត្រូវបានរើសអើង ។ កងទ័ពខ្មែរក្រហម ដែលស្លៀកពាក់ខោអាវខ្មៅ ឬពណ៌អាចម៍សេះ បង់កក្រមា បានបង្ខំប្រជាជនឲ្យធ្វើដំណើរទៅមុខ ហើយពេលខ្លះបានគំរាមកំហែងវាយដំ និងប្លន់យកទ្រព្យសម្បត្តិពីប្រជាជនក្នុងពេលជម្លៀស ។ ប្រជាជនត្រូវដេកសម្រាកនៅតាមដងផ្លូវ និងក្រោមដើមឈើ ហើយហូបតែបាយបន្តិចបន្តួច ។ ដោយសារតែការធ្វើដំណើរផ្លូវឆ្ងាយ

ប្រជាជនដែលត្រូវជម្លៀស បានជួបប្រទះការខ្វះខាតយ៉ាងច្រើនដែលបណ្តាលឲ្យមានការហេវហត់ កើតជំងឺហើមដៃជើង និងរាករូស ។ ជាសរុប ប្រជាជនចំនួនប្រមាណ២លាននាក់ ត្រូវបានជម្លៀសដោយបង្ខំឲ្យចាកចេញពីទីក្រុង ។ ប្រជាជនប្រហែល៣.០០០នាក់ បានស្លាប់ក្នុងពេលជម្លៀស ។

ចាប់ពីខែកញ្ញា ឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៧ ប្រជាជនមួយចំនួនធំត្រូវបានជម្លៀសចេញពីភូមិភាគកណ្តាល និងភូមិភាគនិរតីនៃប្រទេស រួមមានខេត្តកណ្តាល កំពង់ធំ តាកែវ កំពង់ស្ពឺ កំពង់ឆ្នាំង កំពង់ចាម ឆ្ពោះទៅកាន់ខេត្តសៀមរាប ព្រះវិហារ និងភូមិភាគពាយ័ព្យ រួមមាន ខេត្តបាត់ដំបង ពោធិ៍សាត់ និងបន្ទាយមានជ័យ ។

ឯកសារដែលបានបន្សល់ទុកពីរបបខ្មែរក្រហមបានបង្ហាញឲ្យដឹងថា ប្រជាជនប្រមាណពី៨សែន ទៅ៩សែននាក់ ត្រូវបានខ្មែរក្រហមបញ្ជូនទៅកាន់ភូមិភាគពាយ័ព្យ ហើយប្រជាជនចំនួនប្រមាណ៥ម៉ឺន នាក់ផ្សេងទៀតត្រូវបានជម្លៀសចេញពីភូមិភាគបូព៌ា រួមមាន ខេត្តព្រៃវែង និងស្វាយរៀង ។

បុគ្គលិកធ្វើការនៅស្ថានីយរថភ្លើងពិតជាបានឃើញប្រជាជនរាប់ម៉ឺននាក់ត្រូវបានជម្លៀសតាមខ្សែរថភ្លើងចេញពីទីក្រុងភ្នំពេញ ឆ្ពោះទៅកាន់ស្ថានីយរថភ្លើងផ្សេងៗ ដូចជា ខេត្តពោធិ៍សាត់ និង បាត់ដំបង នៃភូមិភាគពាយ័ព្យ ។

នៅក្នុងរបបខ្មែរក្រហម ប្រជាជនត្រូវបានជម្លៀសពីកន្លែងមួយទៅកាន់កន្លែងមួយតាមមធ្យោបាយផ្សេងៗ ដូចជា រថភ្លើង រថយន្តតូច រថយន្តកងទ័ព ទូក កាណូត រទេះគោ ត្រាក់ទ័រ និង ថ្មើរជើង ។ ដោយឡែក ការជម្លៀសប្រជាជនទៅកាន់ភូមិភាគពាយ័ព្យត្រូវបានធ្វើឡើងក្នុងទ្រង់ទ្រាយធំ តាមរយៈរថភ្លើង ដែលនៅក្នុងទូរថភ្លើងនីមួយៗមានមនុស្សចំនួន១០០នាក់ ឈរប្រជ្រៀតគ្នាណែនណាន់តាន់តាប់ ហើយពុំមានអាហារ ឬទឹកបរិភោគគ្រប់គ្រាន់ ។ កងទ័ពខ្មែរក្រហម គឺជាអ្នកមើលការខុសត្រូវក្នុងការជម្លៀសប្រជាជន និងមានភារកិច្ចត្រួតពិនិត្យប្រជាជនជម្លៀសតាមរថភ្លើង ទូក និងរទេះគោ ហើយចាំទទួលប្រជាជនជម្លៀសនៅតាមចំណតស្ថានីយរថភ្លើងនីមួយៗទៅកាន់សហករណ៍នានា ។

ខេត្តបាត់ដំបង និងខេត្តបន្ទាយមានជ័យ ត្រូវបានស្គាល់ថាជាឃ្លាំងបាយរបស់ប្រទេសកម្ពុជា ដែលអាចចិញ្ចឹមប្រជាជនកម្ពុជាទូទាំងប្រទេសបាន ។ ដោយសារតែហេតុផលនេះហើយ បានជាខ្មែរក្រហមធ្វើការជម្លៀសប្រជាជនដោយបង្ខំទៅកាន់ខេត្តទាំងពីរនេះ ។ បើយោងតាមរបាយការណ៍ផែនទីរណ្តៅសាកសពរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ខេត្តបន្ទាយមានជ័យ មានទីតាំងឧក្រិដ្ឋកម្មចំនួន ១៦កន្លែង ។

## នៅពេលដែលអ្នករស់រានពីរបបខ្មែរក្រហម និង ក្មេងជំនាន់ក្រោយបានជួបគ្នា

នៅអំឡុងពេលនៃការបើកពិធីសម្ពោធពិព័រណ៍នៅសារមន្ទីរខេត្តបាត់ដំបង និងបន្ទាយមានជ័យ សិស្សានុសិស្សវិទ្យាល័យ និងនិស្សិតមានឱកាសជួបជាមួយនឹងអ្នកដែលនៅរស់រានពីរបបខ្មែរក្រហម ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកដើមចោទដែលបានដាក់ពាក្យបណ្តឹងទៅសាលាក្តីខ្មែរក្រហម ដោយផ្ទាល់ ដោយមានការពិភាក្សាយ៉ាងរស់រវើក ។

ក្រុមការងារបានសម្ភាសសិស្សានុសិស្សវ័យក្មេងជាច្រើនដែលសិស្សានុសិស្សបាននិយាយថា គេគ្រាន់តែធ្លាប់ឮរឿងរ៉ាវរបស់ខ្មែរក្រហមតាមរយៈជីដូនជីតា និងឪពុកម្តាយតែប៉ុណ្ណោះ ។ ដូច្នេះ សិស្សានុសិស្សទាំងនោះ មិនសូវជឿលើរឿងរ៉ាវទាំងអស់នោះឡើយ ។ សិស្សានុសិស្សមានភាពលំបាក ក្នុងការស្រមៃពីរូបភាពនៃរបបដ៏ឃោរឃៅនោះ និងទុក្ខវេទនាដែលឪពុកម្តាយជីដូនជីតា និងសាច់ញាតិរបស់គេធ្លាប់ទទួលរង ។

ជាឧទាហរណ៍ ឆេង គីមហួយ អាយុ២២ឆ្នាំ ភេទស្រី មកពីសាកលវិទ្យាល័យ CUS នៅខេត្តបន្ទាយមានជ័យ បាននិយាយថា ក្រោយពីពេលបានជួបជាមួយនឹងអតីតជនដែលនៅរស់ពីរបបខ្មែរក្រហម និងបន្ទាប់ពីបានទស្សនាពិព័រណ៍រួចមក គីមហួយគិតថារឿងរ៉ាវដែលជីដូនរបស់គាត់ បាននិយាយប្រាប់ពីជំនាន់ខ្មែរក្រហមពិតជាការពិត ។ គីមហួយ ក៏បានប្រាប់ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារថា ក្មេងជំនាន់ក្រោយគួរតែចងចាំពីប្រវត្តិសាស្ត្រប្រទេសកម្ពុជា ដើម្បីឲ្យច្បាស់ថា នឹងមានសន្តិភាពក្នុងសង្គមកម្ពុជា ។ សាំង ចុង ជានិស្សិតឆ្នាំទី៣ផ្នែកអក្សរសាស្ត្រខ្មែរនៅសាកលវិទ្យាល័យបាត់ដំបង ក៏មានអារម្មណ៍ដូចគ្នាដែរ នៅពេលបានទស្សនាពិព័រណ៍នេះ ។ ចុង មានមតិថា ពិព័រណ៍នេះពិតជាងាយស្រួលអាន ព្រោះមានភាសាពីរនៅតាមបន្ទះពិព័រណ៍ ដូច្នេះសិស្សា

នុសិស្ស ដូចជារូបគាត់ អាចអានទាំងភាសាខ្មែរ និងអង់គ្លេស ។ ថុង បានកត់សម្គាល់ថា ពិព័រណ៌នេះគឺរៀបចំបានយ៉ាងល្អ ដូច្នេះ ថុង នឹងប្រាប់មិត្តភក្តិរបស់គាត់ឲ្យមកទស្សនា ។ ថុង បាននិយាយថា នឹងមកមើលពិព័រណ៌នេះម្តងទៀត ។

ស្របពេលដែលសិស្សានុសិស្សមានឱកាសរៀនសូត្រពីប្រវត្តិសាស្ត្រខ្មែរក្រហមតាមរយៈ ពិព័រណ៌ និងអ្នកដែលនៅរស់ពីរបបខ្មែរក្រហមនោះ អតីតអ្នកដែលនៅរស់ពីរបបខ្មែរក្រហមដែលបានចូលរួមពិធីសម្ពោធពិព័រណ៌នោះ មានភាពរីករាយដែលបានឃើញការដាក់បង្ហាញពីប្រវត្តិសាស្ត្រខ្មែរក្រហមនៅតាមបណ្តាខេត្តដែលខ្លួនរស់នៅ ។ អ្នកដែលនៅរស់ពីរបបខ្មែរក្រហមភាគច្រើនដែលក្រុមការងារបានសម្ភាស បានគិតថា គឺមានសារប្រយោជន៍ក្នុងការតាំងពិព័រណ៌ពីរបបខ្មែរក្រហមនៅតាមសហគមន៍ក្នុងតំបន់ ព្រោះពិព័រណ៌នេះអាចបញ្ជាក់ថា ប្រវត្តិសាស្ត្រខ្មែរក្រហមគឺមិនត្រូវបានបំភ្លេចដោយក្មេងជំនាន់ក្រោយឡើយ ។

ម៉ាត់ ហ៊ីម អាយុ៦៦ឆ្នាំ ជាជនជាតិចាមមកពីខេត្តបន្ទាយមានជ័យ បាននិយាយថា ពិព័រណ៌នេះបានរឭកពីរឿងរ៉ាវផ្ទាល់ខ្លួនរបស់គាត់ដែលធ្លាប់ជួបប្រទះនៅសម័យខ្មែរក្រហម ។ ហ៊ីម មានការសប្បាយចិត្តដែលបានឃើញពិព័រណ៌នេះនៅសារមន្ទីរក្នុងខេត្តដែលគាត់រស់នៅ ដែលអាចរំឭកប្រជាជនពីរបបខ្មែរក្រហមជារៀងរហូត ។ ហ៊ីម បន្ថែមថា គាត់នឹងនាំគ្រួសារ និងកូនៗរបស់គាត់មកមើលពិព័រណ៌ម្តងទៀតនៅពេលខាងមុខ ។ ប្រជាពលរដ្ឋដែលរស់នៅខេត្តបន្ទាយមានជ័យ អាយុ៦៤ឆ្នាំ ឈ្មោះ អែល ឃន មានមតិថា ពិព័រណ៌នេះនឹងក្លាយទៅជាឧបករណ៍ដ៏មានប្រយោជន៍ដើម្បីរំឭកប្រជាជនអំពីអតីតកាល ។ មុនពេល អែល ឃន ចាកចេញពីព្រឹត្តិការណ៍នោះ អែល ឃន បាននិយាយថា នឹងប្រាប់ព័ត៌មានអំពីពិព័រណ៌នេះទៅអ្នកជិតខាងរបស់គាត់ ដូច្នេះ អ្នកជិតខាងរបស់គាត់អាចនាំកូនៗ មកទស្សនាសារមន្ទីរ និងពិព័រណ៌ ។ ក្រុមគ្រួសាររបស់ អែល ឃន ត្រូវបានជម្លៀសដោយរថភ្លើងពីខេត្តកណ្តាលទៅខេត្តពោធិ៍សាត់ដោយខ្មែរក្រហម ។ នៅអំឡុងពេលជិះរថភ្លើងនោះ ជីដូនជីតារបស់ អែល ឃន បានស្លាប់នៅក្នុងរថភ្លើង និងសាកសពរបស់គាត់ត្រូវបានយោធាខ្មែរក្រហមបោះចេញពីទូរថភ្លើង ។

## វាគ្មិន

វាគ្មិនដែលត្រូវចូលរួមនៅឯពិធីសម្ពោធពិព័រណ៌នៅសារមន្ទីរខេត្តបាត់ដំបង និងបន្ទាយមានជ័យ មានដូចជា អ្នកតំណាងមកពីសារមន្ទីរជាតិនៃប្រទេសកម្ពុជា ក្រុមការងាររបស់សារមន្ទីរនៃការចងចាំរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ប្រធានសារមន្ទីរខេត្តបាត់ដំបង និងបន្ទាយមានជ័យ និងអ្នកតំណាង ផ្នែកទទួលបន្ទុកជួយជនរងគ្រោះនៃសាលាក្តីខ្មែរក្រហម ។

លោក គឹម សោភណ្ឌ ប្រធានសារមន្ទីរខេត្តបាត់ដំបង បានស្វាគមន៍ដល់ភ្ញៀវទាំងអស់ និងនិយាយអំពីប្រវត្តិសាស្ត្រពីសារមន្ទីរខេត្តបាត់ដំបង ។ ដោយយោងទៅតាមលោក គឹម សោភណ្ឌ បាននិយាយថា សារមន្ទីរបាត់ដំបងធ្លាប់ជាមន្ទីរឃុំឃាំងនៅរបបខ្មែរក្រហម ។ នៅតាមបរិវេណសារមន្ទីរបានរកឃើញខ្មោះជាច្រើនបន្ទាប់ពីខ្មែរក្រហមបានដួលរលំ នៅឆ្នាំ១៩៧៩ ។

លោក យ៉ង់ តាំងកួយ ប្រធានសារមន្ទីរខេត្តបន្ទាយមានជ័យ បានស្វាគមន៍ដល់ភ្ញៀវទាំងអស់ និងប្រកាសពីការសម្ពោធពិព័រណ៌ពីខ្មែរក្រហមនៅសារមន្ទីរ ខេត្តបន្ទាយមានជ័យ នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៤ ។ លោក តាំងកួយ មានការរីករាយដោយមានការតាំងពិព័រណ៌ពីរបបខ្មែរក្រហមនៅសារមន្ទីរ ខេត្តបន្ទាយមានជ័យ ។ លោក តាំងកួយ សង្ឃឹមថា ពិព័រណ៌នេះនឹងអប់រំក្មេងជំនាន់ក្រោយពីប្រវត្តិសាស្ត្រដ៏ខ្មៅងងឹតរបស់ប្រទេសកម្ពុជា ។

លោក ទេស ឈឿន អ្នកតំណាងមកពីសារមន្ទីរជាតិ បានសង្ខេបពីកិច្ចសហការរវាងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងមជ្ឈមណ្ឌលឯកសារកម្ពុជា ពីការបង្កើតពិព័រណ៌ខ្មែរក្រហមនៅតាមសារមន្ទីរខេត្ត ។

លោក ឌី ឈុនសុង អ្នកតំណាងផ្នែកទទួលបន្ទុកជួយជនរងគ្រោះមកពីសាលាក្តីខ្មែរក្រហម បានសង្ខេបពីគម្រោងសំណងដែលបង្កើតដោយដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០២/០១ ដែលគម្រោងរបស់ពិព័រណ៌នេះក៏ជាផ្នែកមួយដែរ ។

កញ្ញា ស៊ុំ សាវីណា នាយកសារមន្ទីរនៃការចងចាំ បានសង្ខេបពីប្រធានបទ និងគោលដៅរបស់ពិព័រណ៌ ដែលមានបំណងជួយឲ្យមានការរៀនសូត្រពីរបបខ្មែរក្រហម និងជួយឲ្យមានដំណើរការផ្សះផ្សាក្នុងប្រទេសកម្ពុជា ។

## សេចក្តីសន្និដ្ឋាន

ដោយមានការនាំយកពិព័រណ៌ខ្មែរក្រហមទៅតាមសហគមន៍ក្នុងស្រុក ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងមជ្ឈមណ្ឌលឯកសារកម្ពុជា សង្ឃឹមថា នឹងមានការរំលែកចំណេះដឹង និងសម្បជញ្ញៈពីជីវិត និងផ្នែកនៃប្រវត្តិសាស្ត្រដ៏ខ្មៅងងឹតនៃប្រទេសកម្ពុជា ។ ដោយមានការបង្កើតពិព័រណ៌នៅតាមសារមន្ទីរខេត្ត ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងមជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា នឹងមានភាពងាយស្រួលសម្រាប់អ្នកភូមិ អ្នកដែលនៅរស់រានមានជីវិតពីរបបខ្មែរក្រហម និងប្រជាជនខ្មែរជំនាន់ក្រោយដែលរស់នៅតាមខេត្តឆ្ងាយពីរាជធានី មានឱកាសទៅទស្សនាសារមន្ទីរ និងរៀនសូត្រតាមរយៈការពិភាក្សា ។

### សម្រង់មតិយោបល់របស់អ្នកដែលបានចូលរួមពិធីបើកសម្ពោធពិព័រណ៌

**១) ធឿន ច័ន្ទកុម្ភៈ ភេទប្រុស ជានិស្សិតផ្នែកអក្សរសាស្ត្រខ្មែរ នៃសាកលវិទ្យាល័យបាត់ដំបង**



ធឿន ច័ន្ទកុម្ភៈ

ខ្ញុំគិតថា ពិព័រណ៌ស្តីអំពីរបបខ្មែរក្រហមមានសារសំខាន់ណាស់សម្រាប់ក្មេងជំនាន់ក្រោយក្នុងការចងចាំអំពីប្រវត្តិសាស្ត្ររបស់ប្រទេសជាតិខ្លួនឯង ។ ខ្ញុំមានមោទកភាពណាស់ ដែលក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងមជ្ឈមណ្ឌលឯកសារកម្ពុជា បានបង្កើតពិព័រណ៌នេះឡើង ដើម្បីជួយឲ្យខ្ញុំបានយល់ដឹងកាន់តែច្បាស់អំពីប្រវត្តិសាស្ត្រខ្មែរក្រហម ។ ទន្ទឹមនឹងនេះដែរ ខ្ញុំក៏ធ្លាប់បានដឹងអំពីរបបខ្មែរក្រហមតាមរយៈ ឪពុកម្តាយខ្ញុំ និងអ្នកជិតខាង ។ ខ្ញុំក៏ធ្លាប់បានតាមដានការកាត់ក្តីរបស់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមតាមរយៈប៉ុស្តិ៍ទូរទស្សន៍ ។

**២) ផេង ណម ភេទប្រុស អ្នកដាក់ពាក្យបណ្តឹងនៅចំពោះមុខតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម មកពីខេត្តបាត់ដំបង**

ខ្ញុំចាំថា ខ្ញុំបានដាក់ពាក្យបណ្តឹងទៅតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ ប៉ុន្តែខ្ញុំមិនចាំថានៅឆ្នាំណានោះទេ ។ អ្វីដែលខ្ញុំអាចចាំបាន ខ្ញុំបានជម្រាបប្រាប់តុលាការថា ខ្ញុំបានបាត់បង់ឪពុក បងថ្លៃ និងបងប្អូនជីដូនមួយ មួយចំនួននៅក្នុងរបបខ្មែរក្រហម ។ ខ្ញុំធ្លាប់ធ្វើការនៅក្នុងកងចល័តខាងដកស្ទូងនៅក្នុងរបបខ្មែរក្រហម ។ ពេលនោះខ្ញុំរស់នៅតំបន់៤ ។



ផេង ណម

បន្ទាប់ពីបានទស្សនាពិព័រណ៌ស្តីអំពីរបបខ្មែរក្រហម ខ្ញុំគិតថា ពិព័រណ៌នេះនឹងជួយក្មេងជំនាន់ក្រោយឲ្យបានដឹងពីការពិត និងរឿងរ៉ាវដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម ។ នៅក្នុងពិព័រណ៌នេះ ខ្ញុំបានឃើញពីការបង្ខំឲ្យប្រជាជនធ្វើការ ។ ប្រសិនជាអាចខ្ញុំចង់ឲ្យអ្នករៀបចំពិព័រណ៌ដាក់តាំងបង្ហាញវត្ថុ ឬសម្ភារផ្សេងៗដែលខ្មែរក្រហមធ្លាប់បានប្រើប្រាស់ដើម្បីធ្វើទារុណកម្មប្រជាជន ក្នុងគោលបំណងឲ្យក្មេងជំនាន់ក្រោយបានដឹងពីភាពសាហាវឃោរឃៅរបស់ខ្មែរក្រហម ។ ខ្ញុំនឹងនាំកូន និងចៅរបស់ខ្ញុំមកទស្សនាពិព័រណ៌នេះ ដោយសារតែកូន និងចៅរបស់ខ្ញុំមិនសូវជឿនូវអ្វីដែលខ្ញុំបានប្រាប់ពីរបបខ្មែរក្រហមនោះទេ ។

**៣) ឯល កន ភេទស្រី អាយុ៦៤ឆ្នាំ មកពីខេត្តបន្ទាយមានជ័យ**



ឯល កន

ខ្ញុំគិតថា ទំហំពិព័រណ៌គឺធំល្មមសម្រាប់ភ្ញៀវអ្នកមកទស្សនា ។ ម្យ៉ាងវិញទៀត ពិព័រណ៌ស្តីអំពីរបបខ្មែរក្រហមនេះមានសារសំខាន់ណាស់សម្រាប់ប្រជាជនកម្ពុជា និងជួយឲ្យក្មេងជំនាន់ក្រោយយល់ដឹងកាន់តែច្រើនអំពីរឿងរ៉ាវដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម ។ ខ្ញុំមានការពេញចិត្តចំពោះការរៀបចំដាក់តាំងពិព័រណ៌នេះណាស់ ។ នៅពេលដែលខ្ញុំត្រឡប់ទៅផ្ទះវិញ ខ្ញុំនឹងនិយាយប្រាប់អ្នកជិតខាងរបស់ខ្ញុំឲ្យបានដឹងអំពីពិព័រណ៌នេះ ។ នៅក្នុងរបបខ្មែរក្រហម ក្រុមគ្រួសាររបស់ខ្ញុំត្រូវបានខ្មែរក្រហមជម្លៀសតាមរថភ្លើងពីខេត្តកណ្តាលទៅ

កាន់ខេត្តពោធិ៍សាត់ ។ នៅក្នុងពេលជម្លៀសតាមរថភ្លើង ជីដូនជីតារបស់ខ្ញុំបានស្លាប់ ។ ខ្មែរក្រហមបានយកសាកសពអ្នកទាំងពីរបោះចេញមកក្រៅទូរថភ្លើង ។ ខ្ញុំមិនបានឃើញហេតុការណ៍ដោយផ្ទាល់ភ្នែកនោះទេ ។ នៅក្នុងរបបខ្មែរក្រហម ខ្ញុំរស់នៅស្រុកប៉ៃលិនជាមួយប្ដីរបស់ខ្ញុំ ។ នៅឆ្នាំ១៩៧៧ ម្ដាយរបស់ខ្ញុំបានស្លាប់ដោយសារភាពអត់ឃ្លាននៅខេត្តពោធិ៍សាត់ ។ ក្រោយមកទៀត បងប្អូនបង្កើតរបស់ខ្ញុំបានស្លាប់ ។

### ៤) កើត ញាណ ភេទប្រុស អាយុ៧២ឆ្នាំ ដើមបណ្ដឹងរដ្ឋប្បវេណី នៅចំពោះមុខតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ខេត្តបន្ទាយមានជ័យ


កើត ញាណ

ខ្ញុំមានភាពសប្បាយរីករាយ នៅពេលដែលខ្ញុំបានឃើញរឿងរ៉ាវរបស់ជនរងគ្រោះនៃរបបខ្មែរក្រហមត្រូវបានយកមកដាក់តាំងបង្ហាញក្នុងពិព័រណ៍នេះ ជាពិសេសនៅក្នុងសារមន្ទីរខេត្តដែលខ្ញុំរស់នៅ ។ ខ្ញុំសង្ឃឹមថា ក្មេងជំនាន់ក្រោយនឹងអាចរៀនសូត្របានកាន់តែច្រើនអំពីរបបខ្មែរក្រហម ។ ខ្ញុំសូមសំណូមពរឲ្យមានការរៀបចំកម្មវិធីអប់រំនៅតាមសាលារៀនទូទាំងប្រទេសអំពីរបបខ្មែរក្រហម ។ ដូច្នេះ ក្មេងជំនាន់ក្រោយនឹងចងចាំរឿងរ៉ាវរបស់ជនរងគ្រោះ និងជួយដល់ការទប់ស្កាត់កុំឲ្យរបបខ្មែរក្រហមកើតឡើងម្ដងទៀត ។

### ៥) វ៉ិន ឡា ភេទប្រុស អាយុ៤៦ឆ្នាំ គ្រូបង្រៀនផ្នែកប្រវត្តិវិទ្យា ថ្នាក់ទី៩ និងទី១១ នៅវិទ្យាល័យនេគយ័ន ខេត្តបាត់ដំបង

ខ្ញុំបាននឹកឃើញរឿងរ៉ាវដែលខ្ញុំបានជួបប្រទះនៅពេលដែលខ្ញុំចូលមកទស្សនាពិព័រណ៍ស្ដីអំពីការជម្លៀស ដោយបង្ខំនៅក្នុងរបបខ្មែរក្រហម ។ នៅពេលដែលខ្មែរក្រហមចូលមកដល់ទីក្រុងភ្នំពេញ ក្រុមគ្រួសាររបស់ខ្ញុំត្រូវបានខ្មែរក្រហមជម្លៀសចេញពីផ្ទះនៅក្បែរផ្សារថ្មី មកកាន់ខេត្តបាត់ដំបងតាមរយៈរថភ្លើង ។ ក្នុងចំណោមក្រុមគ្រួសារខ្ញុំទាំងអស់ ខ្ញុំគឺជាសមាជិកតែម្នាក់គត់ដែលនៅរស់រានមានជីវិតពីរបបខ្មែរក្រហម ។ សមាជិកគ្រួសារដទៃទៀតបានស្លាប់ម្ដងមួយៗជាបន្តបន្ទាប់ ។ អ្វីដែលខ្ញុំចងចាំបំផុតនៅក្នុងរបបខ្មែរក្រហម គឺខ្ញុំដេកសម្រក់ទឹកភ្នែករាល់យប់ដោយសារតែនឹកគ្រួសាររបស់ខ្ញុំ ។


វ៉ិន ឡា

បច្ចុប្បន្ននេះ ខ្ញុំគឺជាគ្រូបង្រៀនផ្នែកប្រវត្តិវិទ្យា ។ តាមរយៈការបង្រៀនប្រវត្តិសាស្ត្រ ជាពិសេសប្រវត្តិសាស្ត្រខ្មែរក្រហម ខ្ញុំជឿជាក់ថា ក្មេងជំនាន់ក្រោយនឹងយល់ដឹងកាន់តែច្បាស់អំពីរឿងរ៉ាវដែលបានកើតឡើងកាលពីអតីតកាល ។ ជាងនេះទៅទៀត ខ្ញុំគិតថា សិស្សរបស់ខ្ញុំនឹងបានស្វែងយល់កាន់តែច្រើន ដោយសារតែពិព័រណ៍ទាក់ទងនឹងរបបខ្មែរក្រហមត្រូវបានដាក់តាំងបង្ហាញនៅទីរួមខេត្តរបស់ខ្ញុំ ។ ពិព័រណ៍នេះនឹងជួយសម្រួលដល់ការងារបង្រៀនរបស់ខ្ញុំ ។

### ៦) សួស ណាវ៉ាន់ ភេទស្រី អាយុ២៥ឆ្នាំ និស្សិតឆ្នាំទី៣ មុខវិជ្ជាអក្សរសាស្ត្រខ្មែរ នៃសាកលវិទ្យាល័យបាត់ដំបង


សួស ណាវ៉ាន់

ខ្ញុំធ្លាប់ទស្សនាសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែងពីរបីដង ។ វាជាទីកន្លែងមួយដ៏គួរឲ្យរន្ធត់ ។ ខ្ញុំយល់ថា ពិព័រណ៍ស្ដីអំពីការជម្លៀសប្រជាជនដោយបង្ខំនឹងជួយខ្ញុំឲ្យយល់កាន់តែស៊ីជម្រៅទាក់ទងនឹងរបបខ្មែរក្រហម ។ មិនតែប៉ុណ្ណោះ ពិព័រណ៍នេះបានផ្ដល់ព័ត៌មានបន្ថែមដល់ខ្ញុំអំពីរឿងរ៉ាវដែលឪពុកម្ដាយខ្ញុំធ្លាប់ដំណាលប្រាប់ទាក់ទងនឹងរបបខ្មែរក្រហម ។

### ៧) កូប ឯល ភេទប្រុស ជនជាតិខ្មែរអ៊ីស្លាម ជាអ្នកដាក់ពាក្យបណ្ដឹងនៅចំពោះមុខតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម មកពីខេត្តបាត់ដំបង

ខ្ញុំយល់ថា ពិព័រណ៍នេះរៀបចំបានល្អ និងបានដើរតួនាទីក្នុង

ការដាស់តឿនក្មេងជំនាន់ក្រោយអំពីរបបខ្មែរក្រហម ដោយសារតែក្មេងជំនាន់ក្រោយមិនបានដឹងពីរឿងរ៉ាវដែលបានកើតឡើង និងការបំផ្លិចបំផ្លាញដែលបង្កឡើងដោយខ្មែរក្រហមនោះទេ ។ រឿងរ៉ាវរបស់ជនរងគ្រោះដែលបានដាក់តាំងបង្ហាញទាំងអស់ សុទ្ធតែមានសារសំខាន់ក្នុងការពន្យល់ប្រាប់ក្មេងជំនាន់ក្រោយ ។ ខ្ញុំនឹងចូលរួមទស្សនាពិព័រណ៍ជាថ្មីទៀត ប្រសិនបើមានការរៀបចំដាក់តាំងនាពេលអនាគត ។

### ៨) រឿន សុវណ្ណារិទ្ធ ភេទប្រុស អាយុ២០ឆ្នាំ និស្សិតឆ្នាំទី១ នៃសាកលវិទ្យាល័យបាត់ដំបង


រឿន សុវណ្ណារិទ្ធ

ម្តាយរបស់ខ្ញុំធ្លាប់និយាយប្រាប់ខ្ញុំអំពីរឿងរ៉ាវដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម ។ ក្រុមគ្រួសាររបស់គាត់ត្រូវបានខ្មែរក្រហមជម្លៀសចេញពីទីក្រុងទៅកាន់ខេត្តបាត់ដំបង ។ បន្ទាប់មក ខ្មែរក្រហមបានបំបែកគាត់ចេញពីក្រុមគ្រួសារឲ្យទៅរស់នៅក្នុងកងកុមារ ។ ខ្ញុំយល់ថា ការសិក្សាអំពីប្រវត្តិសាស្ត្រខ្មែរក្រហមគឺជារឿងចាំបាច់មួយ និងជួយឲ្យក្មេងជំនាន់ក្រោយបានដឹងពីការដឹកនាំប្រទេសរបស់មនុស្សជំនាន់មុន ព្រមទាំងជួយដល់ក្មេងជំនាន់ក្រោយឲ្យចេះត្រិះរិះពិចារណា និងចេះប្រើវិធីសាស្ត្រត្រឹមត្រូវក្នុងការដឹកនាំប្រទេស ។ នៅពេលដែលខ្ញុំបានឃើញរូបភាពប្រជាជនធ្វើការនៅក្នុងការដ្ឋានលើកទំនប់ ជីកប្រឡាយទឹក ខ្ញុំបាននឹកឃើញដល់រឿងរ៉ាវដែលម្តាយខ្ញុំបានរៀបរាប់ប្រាប់ ។ នៅក្នុងរបបខ្មែរក្រហម ប្រជាជនត្រូវធ្វើការងារជាទម្ងន់ ដូចជា វែកដី ជីកប្រឡាយ និងការងារផ្សេងៗទៀត ។ ខ្ញុំមានអារម្មណ៍អាណិតអាសូរចំពោះប្រជាជនទាំងនោះ នៅពេលខ្ញុំបានឃើញរូបភាពទាំងអស់នោះ ។ ខ្ញុំមិនធ្លាប់ចូលទស្សនាសារមន្ទីរខេត្តពីមុនមកនោះទេ ។ និយាយឲ្យត្រង់ទៅ ខ្ញុំមិនបានដឹងថា នៅខេត្តរបស់ខ្ញុំមានសារមន្ទីរនោះទេ ហើយសារមន្ទីរនោះបើកទ្វារឲ្យសាធារណជនចូលនោះទេ ។ ខ្ញុំនឹងត្រឡប់មកមើលពិព័រណ៍ជាថ្មីម្តងទៀតដើម្បីសិក្សាបន្ថែម ។

### ៩) ម៉ាត់ ហ៊ីម ភេទប្រុស ជនជាតិចាម អាយុ៦០ឆ្នាំ ជាដើមបណ្តឹងរដ្ឋប្បវេណី នៅសាលាក្តីខ្មែរក្រហម មកពីខេត្តបន្ទាយមានជ័យ


ម៉ាត់ ហ៊ីម

ការតាំងពិព័រណ៍នេះបានឆ្លុះបញ្ចាំងអំពីអ្វីដែលខ្ញុំធ្លាប់ឆ្លងកាត់កាលពីរបបខ្មែរក្រហម ។ ខ្ញុំពេញចិត្តដែលបានឃើញការតាំងពិព័រណ៍នេះនៅសារមន្ទីរខេត្តរបស់ខ្ញុំ ។ ពិព័រណ៍នេះនឹងរំឭកប្រជាជនអំពីរឿងហេតុដែលបានកើតឡើងនៅរបបខ្មែរក្រហម ។ ខ្ញុំនឹងនាំគ្រួសារ ជាពិសេសកូនរបស់ខ្ញុំមកទស្សនាពិព័រណ៍នេះម្តងទៀត នៅពេលដែលខ្ញុំមានពេលទំនេរ ។ ខ្ញុំគិតថា ពិព័រណ៍នេះ គឺមានភាពចាំបាច់ក្នុងការរំឭកក្មេងជំនាន់ក្រោយ ដើម្បីឲ្យមានការចងចាំ និងស្វែងយល់ពីរបបខ្មែរក្រហម ។ ពិព័រណ៍នេះនឹងជួយឲ្យអ្នកដឹកនាំជំនាន់ក្រោយកសាងនូវប្រទេសមួយដែលពោរពេញទៅដោយសុខសន្តិភាព ។

### ១០) ខុន ណៃ ភេទស្រី ជាអ្នកដាក់ពាក្យបណ្តឹងនៅសាលាក្តីខ្មែរក្រហម មកពីខេត្តបាត់ដំបង


ខុន ណៃ

ដោយសារតែខ្ញុំ មិនចេះអក្សរ តាមរយៈការមើលរូបថត ខ្ញុំអាចយល់បាននូវរឿងរ៉ាវនៃការតាំងពិព័រណ៍នេះ ។ ការរៀបចំ ការតាំងពិព័រណ៍នេះ ពិតជាល្អ ប៉ុន្តែផ្ទាំងពិព័រណ៍តិចពេក វាគួរតែមានផ្ទាំងពិព័រណ៍ច្រើនជាងនេះ ។ សម្លឹងមើលទៅរូបថត ដែលថតក្នុងអំឡុងរបបខ្មែរក្រហម បានរំឭកខ្ញុំពីបទពិសោធផ្ទាល់ខ្លួនរបស់ខ្ញុំក្នុងរបបខ្មែរក្រហម ។ ក្មេងជំនាន់ក្រោយមិនជឿថា មានរបបខ្មែរក្រហមនោះទេ ហេតុនេះធ្វើឲ្យខ្ញុំមិនចង់ចែករំលែកនូវរឿងរ៉ាវផ្ទាល់ខ្លួនទៅកាន់អ្នកទាំងនោះឡើយ ។ ខ្ញុំផ្ទាល់បានបាត់បង់ប្អូនប្រុសម្នាក់ដែលបាត់ខ្លួននៅខេត្តពោធិ៍សាត់នៅតាមផ្លូវរថភ្លើង ។ ខ្ញុំចង់មើលការតាំងពិព័រណ៍របៀប

នេះទៀត ព្រោះជំនឿនៃប្រវត្តិសាស្ត្រ គឺធ្លាក់ចុះបន្តិចម្តងៗ ។

**១១) សាំង ថុង ភេទប្រុស និស្សិតឆ្នាំទីបី ផ្នែកអក្សរសាស្ត្រខ្មែរនៃ សាកលវិទ្យាល័យបាត់ដំបង**

ខ្ញុំមិនធ្លាប់ចូលរួមទស្សនាពិព័រណ៍ដែលទាក់ទងនឹងវប្បធម៌ពីមុនមកនោះទេ ។ នេះគឺជាលើកទីមួយរបស់ខ្ញុំ ។ ខ្ញុំគិតថា ការតាំងពិព័រណ៍ពីរបបខ្មែរក្រហមបានបង្ហាញយើងឲ្យបានដឹងពីសង្គមខ្មែរក្នុងសម័យនោះ នឹងចូលរួមទប់ស្កាត់មិនឲ្យរបបឃោរឃៅកើតឡើងវិញម្តងទៀត ។ ខ្ញុំធ្លាប់បានឮរឿងរ៉ាវនៃរបបខ្មែរក្រហមពីឪពុកម្តាយខ្ញុំ ក៏ដូចជារៀនពីសាលារៀន ។ ខ្ញុំជឿនូវអ្វីដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម ដោយសារតែឪពុកម្តាយខ្ញុំធ្លាប់បានជួបប្រទះបទពិសោធជាក់ស្តែង ។ ខ្ញុំនឹងព្យាយាមអានឯកសារផ្សេងទៀតដើម្បីបានយល់កាន់តែស៊ីជម្រៅអំពីរបបខ្មែរក្រហម ។ ខ្ញុំក៏ធ្លាប់បានចូលរួមក្នុងសិក្ខាសាលាផ្សេងៗស្តីអំពីរបបខ្មែរក្រហមដែរ ។ ខ្ញុំទទួលបានចំណេះដឹងជាច្រើនទាក់ទងនឹងរបបខ្មែរក្រហម ។ ការយល់ដឹងពីរបបខ្មែរក្រហមជួយឲ្យខ្ញុំ និងក្មេងជំនាន់ក្រោយចងចាំពីអតីតកាល និងជួយឲ្យយើងចេះរួមសាមគ្គីគ្នា ។ ពិព័រណ៍នេះគឺជាសារមួយសម្រាប់ដាស់តឿនដល់ក្មេងជំនាន់ក្រោយឲ្យចេះទប់ស្កាត់កុំឲ្យរបបយង់ឃ្នងកើតឡើងជាថ្មី ។ ខ្ញុំយល់ថា នេះជារឿងត្រឹមត្រូវណាស់ ដែលពិព័រណ៍ស្តីអំពីរបបខ្មែរក្រហមត្រូវបានរៀបដាក់តាំងបង្ហាញនៅក្នុងសារមន្ទីរបុរាណវិទ្យា ។ ស្របពេលជាមួយគ្នានោះ យើងមានឱកាសស្វែងយល់ពីសម័យកាលរុងរឿងរបស់ខ្មែរ ។ បើទោះបីជាក្រោយមក ប្រទេសយើងធ្លាក់ចូលក្នុងសម័យខ្មៅងងឹតក៏ដោយ ។ ដោយសារតែការឃោសនារបស់ខ្មែរក្រហម សង្គមកម្ពុជាក៏ត្រូវបានបែងចែក ។ ខ្ញុំគិតថា នេះជារឿងមួយល្អ ដែលបង្ហាញពីភាពអស្ចារ្យ និងភាពខ្មៅងងឹតនៃប្រវត្តិសាស្ត្រនៅក្នុងទីតាំងតែមួយ ។ យើងគ្រប់គ្នាត្រូវតែសិក្សាពីប្រវត្តិសាស្ត្រ ដើម្បីស្វែងយល់ពីបច្ចុប្បន្នរបស់ខ្លួនយើង ។

ចំពោះរូបភាព និងអត្ថបទនៅក្នុងពិព័រណ៍ ខ្ញុំយល់ថា ងាយស្រួលក្នុងការអាន ។ ខ្ញុំមានការពេញចិត្តជាខ្លាំងនៅពេលដែលអត្ថបទនៅក្នុងពិព័រណ៍សរសេរជាពីរភាសា ខ្មែរ និងអង់គ្លេស ។ ខ្ញុំអាចអានភាសាខ្មែរផង និងរៀនភាសាអង់គ្លេសផង ។ ចំពោះការរចនាពិព័រណ៍វិញ គឺមានភាពទាក់ទាញ និងច្បាស់ ។ នៅពេលដែលខ្ញុំត្រឡប់ទៅវិញ ខ្ញុំនឹងប្រាប់មិត្តរួមថ្នាក់របស់ខ្ញុំអំពីពិព័រណ៍នេះ ។ ខ្ញុំនឹងពន្យល់ប្រាប់មិត្តរួមថ្នាក់របស់ខ្ញុំអំពីមូលហេតុនៃការដាក់តាំងពិព័រណ៍នេះ ។ ខ្ញុំនឹងត្រឡប់មកទស្សនាពិព័រណ៍នេះម្តងទៀត ដោយសារតែខ្ញុំសិក្សាផ្នែកអក្សរសាស្ត្រខ្មែរ ខ្ញុំចាំបាច់ត្រូវដឹងឲ្យបានស៊ីជម្រៅអំពីសិល្បៈ វប្បធម៌ និងប្រវត្តិសាស្ត្រខ្មែរ ។

**១២) សាន់ រូន ភេទប្រុស អាយុ៥៣ឆ្នាំ ជនជាតិខ្មែរអ៊ីស្លាម អ្នកដាក់ពាក្យបណ្តឹងនៅចំពោះមុខតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម មកពីខេត្តបាត់ដំបង**

ខ្ញុំយល់ថា ការដាក់តាំងពិព័រណ៍នៅតាមសារមន្ទីរខេត្តមានសារសំខាន់ណាស់ ដោយសារតែវាបានបង្ហាញប្រាប់អ្នករស់នៅតាមសហគមន៍មូលដ្ឋានអំពីរឿងរ៉ាវដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម ។ ខ្ញុំមានការពេញចិត្តជាខ្លាំងចំពោះការដាក់តាំងពិព័រណ៍នេះ ។ គួរឲ្យស្តាយ ដោយខ្ញុំមិនបាននាំកូនៗរបស់ខ្ញុំមកជាមួយ ។ កូនៗរបស់ខ្ញុំមិនធ្លាប់បានទៅមើលអតីតគុក ឬសហករណ៍របស់ខ្មែរក្រហមនោះទេ ។ ថ្ងៃណាមួយ ខ្ញុំនឹងនាំកូនៗរបស់ខ្ញុំមកទស្សនាពិព័រណ៍នេះ ដើម្បីឲ្យកូនៗរបស់ខ្ញុំបានសិក្សាស្វែងយល់កាន់តែច្បាស់អំពីរបបខ្មែរក្រហម ។ ខ្ញុំនឹងជំរុញលើកទឹកចិត្តអ្នកដែលរស់នៅក្នុងភូមិជាមួយខ្ញុំឲ្យមកទស្សនាពិព័រណ៍នៅសារមន្ទីរខេត្តនេះ ដោយសារតែយើងអាចឃើញនូវវត្ថុសិល្បៈបុរាណខ្មែរផង និងបានឃើញពិព័រណ៍ស្តីអំពីរបបខ្មែរក្រហមផង ។ កាលពីរបបខ្មែរក្រហម ខ្ញុំបានបាត់បង់បងប្អូនបង្កើតចំនួនពីរនាក់ ។ ខ្ញុំមិនដែលបំភ្លេចនូវរឿងរ៉ាវទាំងឡាយដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហមនោះទេ ។ ខ្ញុំសង្ឃឹមថា ប្រជាជនកម្ពុជានឹងមិនភ្លេចអំពីរបបនេះឡើយ ។

**១៣) ឆេង គីមហួយ ភេទស្រី អាយុ២២ឆ្នាំ និស្សិតឆ្នាំទីមួយនៃសាកលវិទ្យាល័យឯកទេសនៃកម្ពុជា ខេត្តបន្ទាយមានជ័យ**

បន្ទាប់ពីបានទស្សនាពិព័រណ៍ស្តីអំពីរបបខ្មែរក្រហម ខ្ញុំយល់ថា វាជាពិព័រណ៍មួយល្អ ដោយសារតែវាអនុញ្ញាតឲ្យក្មេងជំនាន់ក្រោយមានឱកាសយល់ដឹង និងសិក្សាស្វែងយល់អំពីរបបខ្មែរក្រហម ជាពិសេស ការជម្លៀសប្រជាជនដោយបង្ខំ ។ បើទោះបីជាពុំមានព័ត៌មានច្រើន និងរូបភាពច្រើនត្រូវបានដាក់តាំងបង្ហាញក៏ដោយ ក៏ពិព័រណ៍នេះបានបង្ហាញប្រាប់ខ្ញុំថា របបខ្មែរក្រហមពិត

ជាបានកើតឡើង ។ ជាងនេះទៅទៀត ពិព័រណ៍នេះបានបញ្ឆាក់នូវរឿងរ៉ាវដែលជីដូនរបស់ខ្ញុំធ្លាប់ដំណាលប្រាប់អំពីរបបខ្មែរក្រហម ។ ដូច្នេះ ក្មេងជំនាន់ក្រោយត្រូវចងចាំនូវរឿងរ៉ាវដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម និងជួយដល់អ្នកដឹកនាំប្រទេសវ័យក្មេងឲ្យដឹកនាំប្រទេសប្រកបដោយសន្តិភាពនាពេលអនាគត ។ សម្រាប់រូបខ្ញុំផ្ទាល់ ខ្ញុំចង់ឲ្យមានអ្នកដឹកនាំមួយរូប ដើម្បីបង្ហាញអ្នកទស្សនាអំពីអត្ថន័យនៃពិព័រណ៍នេះ ។ អ្វីដែលខ្ញុំធ្លាប់បានដឹងពីរបបខ្មែរក្រហម ដែលជីដូនខ្ញុំធ្លាប់ដំណាលប្រាប់គឺ ជីដូន និងជីតារបស់ខ្ញុំធ្លាប់ធ្វើការលើកទំនប់អាងត្រពាំងថ្ម នៅខេត្តបន្ទាយមានជ័យ ។

## ១៤) ពុយ ភក្តី ភេទស្រី អាយុ២៨ឆ្នាំ គ្រូបង្រៀននៅសាលាបឋមសិក្សារលំ ខេត្តបន្ទាយមានជ័យ

និយាយឲ្យស្មោះត្រង់ ខ្ញុំមិនធ្លាប់ដឹងថា នៅខេត្តបន្ទាយមានជ័យ មានសារមន្ទីរនោះទេ ។ ខ្ញុំទើបតែដឹង នៅពេលដែលខ្ញុំបានមកចូលរួមទស្សនាពិព័រណ៍ស្តីអំពីការជម្លៀសដោយបង្ខំនៅថ្ងៃនេះ ។ នេះជាឱកាសដ៏ល្អមួយសម្រាប់ខ្ញុំ ដើម្បីបានសិក្សាស្វែងយល់កាន់តែច្រើនអំពីរបបខ្មែរក្រហម ។

ក្នុងនាមជាគ្រូបង្រៀនមួយរូប ខ្ញុំនឹងបង្រៀនសិស្សរបស់ខ្ញុំអំពីប្រវត្តិសាស្ត្រខ្មែរក្រហម ។ ប្រសិនបើមានឱកាស ខ្ញុំនឹងនាំកូនសិស្សរបស់ខ្ញុំមកទស្សនាសារមន្ទីរខេត្ត ដើម្បីមើលពិព័រណ៍ស្តីអំពីរបបខ្មែរក្រហម ។ ខ្ញុំសូមសំណូមពរឲ្យអ្នករៀបចំពិព័រណ៍ចាក់បញ្ចាំងខ្សែភាពយន្តឯកសារស្តីអំពីរបបខ្មែរក្រហម និងដាក់តាំងផែនទីខេត្តបន្ទាយមានជ័យនៅក្នុងរបបខ្មែរក្រហម ។

## ១៥) កុប ឯល ភេទប្រុស ជាជនជាតិចាមម៉ូស្លីម និងជាអ្នកដាក់ពាក្យបណ្តឹងនៅសាលាក្តីខ្មែរក្រហម មកពីខេត្តបាត់ដំបង

ការរៀបចំការតាំងពិព័រណ៍នេះ គឺល្អ ហើយចាត់ទុកជាការចងចាំមួយសម្រាប់ក្មេងជំនាន់ក្រោយ ។ មនុស្សជាច្រើន ជាពិសេសក្មេងជំនាន់ក្រោយ មិនបានដឹងអំពីថា តើខ្មែរក្រហមបានបំផ្លាញសង្គមជាតិដល់កម្រិតណានោះទេ ។ រឿងរ៉ាវទាំងអស់ ដែលបានបង្ហាញនៅពិព័រណ៍នេះ ពិតជាមានសារសំខាន់ខ្លាំងណាស់ ព្រោះវាបានប្រាប់ដល់ក្មេងជំនាន់ក្រោយអំពីស្ថានភាពប្រទេសនៅក្រោមរបបខ្មែរក្រហម ។ ខ្ញុំនឹងទស្សនាគ្រប់ការតាំងពិព័រណ៍ទាំងអស់ ប្រសិនបើមានការតាំងពិព័រណ៍ថ្មីៗទៀត ។

## ១៦) រីយ៉ាស់ ភេទស្រី អាយុ៥៦ឆ្នាំ ជនជាតិខ្មែរអ៊ីស្លាម មកពីខេត្តបាត់ដំបង

បន្ទាប់ពីបានទស្សនាពិព័រណ៍នេះ ខ្ញុំមានអារម្មណ៍មិនសប្បាយចិត្តសោះ ដោយសារតែពិព័រណ៍នេះបានរំឭកឡើងវិញនូវរឿងរ៉ាវដែលខ្ញុំធ្លាប់ជួបប្រទះកាលពីរបបខ្មែរក្រហម ។ ប៉ុន្តែ ការរៀបចំតាំងពិព័រណ៍ ស្តីអំពីរបបខ្មែរក្រហម គឺជារឿងមួយល្អ ។ នៅក្នុងរបបខ្មែរក្រហម ខ្ញុំរស់នៅឃុំអូរស្រឡៅ ខេត្តបាត់ដំបង ។ ខ្ញុំធ្វើការនៅក្នុងសហករណ៍ស្លក្រាម ។ ឪពុកចុងរបស់ខ្ញុំបានស្លាប់ដោយសារជំងឺ ។

## ១៧) មាស សុភី ភេទស្រី អាយុ៤៥ឆ្នាំ គ្រូបង្រៀនផ្នែកប្រវត្តិវិទ្យា នៅវិទ្យាល័យសម្តេចឪ ខេត្តបាត់ដំបង

ពិព័រណ៍នេះមានសារសំខាន់ណាស់ ដោយសារតែបានបញ្ចូលរឿងរ៉ាវរបស់ជនរងគ្រោះនៅក្នុងរបបខ្មែរក្រហម និងបានបង្ហាញពីជីវិតប្រជាជនដទៃទៀតដែលធ្លាប់រស់នៅក្នុងរបបខ្មែរក្រហម ។ ពិព័រណ៍នេះ នឹងជួយឲ្យសិស្សបានសិក្សាស្វែងយល់កាន់តែច្រើនពីប្រវត្តិសាស្ត្រខ្មែរក្រហម ។

ខ្ញុំមានមតិយោបល់មួយចំនួន ដែលពិព័រណ៍នេះគួរតែពង្រីងបន្ថែម ។ ខ្ញុំស្នើសុំឲ្យមានការចាក់បញ្ចាំងខ្សែភាពយន្តឯកសារស្តីអំពីរបបខ្មែរក្រហម ។ ព័ត៌មានសំខាន់ៗគួរតែដាក់អក្សរដិត ឬអក្សរទ្រេត ឬដាក់ផ្កាយ ដើម្បីទាក់ទាញការចាប់អារម្មណ៍របស់អ្នកទស្សនា ។

## ១៨) ឃុន ណៃ ភេទស្រី ជាអ្នកដាក់ពាក្យបណ្តឹងនៅចំពោះមុខតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម មកពីខេត្តបាត់ដំបង

បើទោះបីជាខ្ញុំមិនអាចអានអក្សរបាន ប៉ុន្តែតាមរយៈរូបថត ខ្ញុំអាចយល់បានថា ពិព័រណ៍នេះបានបង្ហាញពីទិដ្ឋភាពដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម ។ ខ្ញុំយល់ថា គួរតែបញ្ចូលសាច់រឿងឲ្យបានច្រើន ។ បន្ទាប់ពីបានឃើញរូបថតកាលពីរបបខ្មែរក្រហម រូបថតទាំងនោះបានរំឭកឲ្យខ្ញុំនឹកឃើញនូវរឿងរ៉ាវដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម ។ ក្មេងជំនាន់ក្រោយភាគច្រើនមិនសូវជឿនូវរឿងរ៉ាវដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហមនោះទេ ។ ហេតុដូច្នេះហើយ ខ្ញុំមិនសូវចង់រំឭកពីរឿងរ៉ាវរបស់ខ្ញុំទៅឲ្យអ្នកដទៃនោះទេ ។ នៅក្នុងរបបខ្មែរក្រហម បងប្រុសរបស់ខ្ញុំបានបាត់ខ្លួននៅតាមបណ្តោយផ្លូវរថភ្លើងនៅក្នុងខេត្តពោធិ៍សាត់ ។

ខ្ញុំសង្ឃឹមថា នឹងបានចូលរួមទស្សនាពិព័រណ៍ស្រដៀងគ្នានេះទៀត នៅថ្ងៃអនាគត ។

**១៩) ឆា ចាន់រស្មី ភេទប្រុស និស្សិតឆ្នាំទី៣ ផ្នែកអក្សរសាស្ត្រខ្មែរ នៃសាកលវិទ្យាល័យបាត់ដំបង**

ក្នុងនាមយើងជាកូនខ្មែរ យើងត្រូវដឹងពីប្រវត្តិសាស្ត្ររបស់ខ្លួន ។ ក្រៅពីទូរទស្សន៍ និងវិទ្យុ ខ្ញុំយល់ថា ការដាក់តាំងពិព័រណ៍គឺជាមធ្យោបាយដ៏ល្អមួយក្នុងការចែករំលែក និងផ្សព្វផ្សាយអំពីប្រវត្តិសាស្ត្រ ។ កាលពីមុន ខ្ញុំមិនសូវជឿអំពីរឿងរ៉ាវដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហមនោះទេ ។ ប៉ុន្តែខ្ញុំយល់ថា ប្រសិនបើរបបខ្មែរក្រហមមិនបានកើតឡើងទេ នោះមនុស្សគ្រប់គ្នាមិនអាចនិយាយរឿងរ៉ាវ ដែលបានកើតឡើងដូចៗគ្នានោះទេ ។ ខ្ញុំនឹងជំរុញឲ្យមិត្តរួមថ្នាក់របស់ខ្ញុំមកទស្សនាពិព័រណ៍នេះ ដោយសារតែមិត្តរួមថ្នាក់របស់ខ្ញុំភាគច្រើនមិនសូវបានដឹងអំពីរបបខ្មែរក្រហមនោះឡើយ ។

**២០) Benoit Viault ភេទប្រុស ជាអ្នកទេសចរនៅខេត្តបាត់ដំបង មកពីប្រទេសបារាំង**

សូមចូលរួមអបអរសាទរចំពោះការតាំងពិព័រណ៍នេះ ។ ប្រវត្តិសាស្ត្រអំពីអំពើអាក្រក់មិនចាំបាច់រៀបរាប់ឲ្យលន្លង់លន្លោចនោះទេ ។ ពេលគឺការរៀបរាប់អំពីការពិត និងរូបភាពអាចបង្ហាញ និងធ្វើឲ្យអ្នកទស្សនាងាយយល់ និងចងចាំ ។ សូមអរគុណសម្រាប់ការធ្វើការងារដ៏ល្អនេះ ។

**២១) លី កុសល អាយុ៤៦ឆ្នាំ មកពីខេត្តបន្ទាយមានជ័យ**

ខ្ញុំគិតថានេះគឺជាការតាំងពិព័រណ៍ដ៏ល្អមួយ ព្រោះអាចជួយឲ្យក្មេងជំនាន់ក្រោយស្វែងយល់កាន់តែច្រើនអំពីរបបខ្មែរក្រហម ។ ខ្ញុំពេញចិត្តចំពោះការតាំងពិព័រណ៍នេះ ។ ខ្ញុំនឹងនាំកូន និងចៅរបស់ខ្ញុំមកទស្សនាពិព័រណ៍នេះនៅពេលក្រោយ ។ ខ្ញុំចង់រំឭកដល់កូន និងចៅរបស់ខ្ញុំអំពីអតីតកាល និងបង្ហាញកូន និងចៅ របស់ខ្ញុំអំពីការឈឺចាប់ដែលប្រជាជនធ្លាប់ឆ្លងកាត់ ។ លើសពីនេះទៅទៀត នៅពេលដែលខ្ញុំត្រឡប់ទៅភូមិវិញ ខ្ញុំនឹងចែករំលែកព័ត៌មានជាមួយនឹងសាច់ញាតិ និងអ្នកជិតខាង និងពន្យល់សាច់ញាតិ និងអ្នកជិតខាងរបស់ខ្ញុំអំពីអ្វីដែលខ្ញុំបានជួបប្រទះនៅថ្ងៃនេះ ។ នៅអំឡុងពេលរបបខ្មែរក្រហម ខ្ញុំរស់នៅខេត្តកំពង់ចាម ។ ឪពុកម្ដាយ និងបងប្អូនខ្ញុំពីរនាក់ត្រូវបានខ្មែរក្រហមសម្លាប់ ។

**២២) ហួរ គីមហេង និស្សិតផ្នែកគណនេយ្យ មកពីសាកលវិទ្យាល័យឯកទេសនៃកម្ពុជា ខេត្តបន្ទាយមានជ័យ**

ខ្ញុំចង់ឲ្យមានការតាំងបង្ហាញពិព័រណ៍នេះបន្ថែមទៀតនៅក្នុងខេត្តរបស់ខ្ញុំ ព្រោះខ្ញុំចង់ឲ្យក្មេងជំនាន់ក្រោយ ធ្វើការស្វែងយល់ និងរៀនសូត្របន្ថែមទៀតអំពីប្រវត្តិសាស្ត្ររបស់ខ្លួន ។ ម្ដាយរបស់ខ្ញុំធ្លាប់រៀបរាប់អំពីរឿងរ៉ាវក្នុងរបបខ្មែរក្រហមប្រាប់ខ្ញុំ ។ ខ្ញុំមិនចង់ឲ្យរបបខ្មែរក្រហមកើតឡើងម្ដងទៀតនោះទេ ។

**២៣) ងឹម សុជាតិ ភេទស្រី អាយុ២៥ឆ្នាំ ជានិស្សិតផ្នែកគ្រប់គ្រង មកពីសាកលវិទ្យាល័យឯកទេសនៃកម្ពុជា និងជាគ្រូបង្រៀននៅថ្នាក់បឋម ខេត្តបន្ទាយមានជ័យ**

ខ្ញុំមិនបានយល់ដឹងច្រើនអំពីរបបខ្មែរក្រហមនោះទេ ប៉ុន្តែនៅពេលដែលមានការតាំងពិព័រណ៍អំពីរបបខ្មែរក្រហមនៅខេត្តរបស់ខ្ញុំនេះ ខ្ញុំនឹងអាចរៀនសូត្រកាន់តែច្រើនអំពីរបបខ្មែរក្រហម ។ នៅពេលដែលខ្ញុំឃើញរូបភាពមនុស្សធ្វើការនៅទំនប់ទឹក វែកដី ខ្ញុំចងចាំអំពីរឿងរ៉ាវដែលឪពុកម្ដាយខ្ញុំធ្លាប់ប្រាប់អំពីរបបខ្មែរក្រហម និងបទពិសោធរបស់ឪពុកម្ដាយខ្ញុំ ។ ខ្ញុំគិតថា ពិព័រណ៍នេះមានសារសំខាន់សម្រាប់ក្មេងជំនាន់ក្រោយដើម្បីសិក្សារៀនសូត្រអំពីរបបខ្មែរក្រហម ព្រោះប្រវត្តិសាស្ត្រអាចនឹងកើតឡើងម្ដងទៀត ប្រសិនបើយើងមិនបានដឹងអំពីប្រវត្តិសាស្ត្ររបស់ខ្លួន ។ ខ្ញុំសូមស្នើសុំឲ្យមានការបញ្ចាំងរូបភាព ដើម្បីទាក់ទាញឲ្យមានអ្នកទស្សនាកាន់តែច្រើន ។

**២៤) ពេជ្រ ចន្ទី ភេទស្រី និស្សិតផ្នែកអក្សរសាស្ត្រខ្មែរ មកពីសាកលវិទ្យាល័យបាត់ដំបង**

ពិព័រណ៍នេះពិតជាមានភាពទាក់ទាញណាស់ ។ កម្មសំពិព័រណ៍គឺត្រូវបានរៀបចំត្រឹមត្រូវតាមបច្ចេកទេស ដែលមានភាពស្រួលដល់អ្នកទស្សនា នៅពេលឈរអានពិព័រណ៍ ។ ទោះបីជាយ៉ាងណាក៏ដោយ ខ្ញុំសូមស្នើសុំឲ្យមានអ្នកណែនាំអំពីពិព័រណ៍សម្រាប់ពន្យល់ដល់អ្នកទស្សនា ព្រោះប្រជាជនអាចនឹងមិនសូវយល់អំពីរឿងរ៉ាវដែលដាក់បង្ហាញ ។ ខ្ញុំចង់ឲ្យមានការតាំងពិព័រណ៍ប្រភេទនេះ ជាពិសេស នៅសាកលវិទ្យាល័យរបស់ខ្ញុំ ។ នៅពេលក្រោយ ខ្ញុំនឹងណែនាំមិត្តភក្តិរបស់ខ្ញុំឲ្យមកទស្សនាពិព័រណ៍នេះ ព្រោះខ្ញុំចង់ឲ្យមិត្ត

ភក្តិរបស់ខ្ញុំរៀនសូត្របន្ថែមទៀតអំពីរបបខ្មែរក្រហម ។ ក្រោយពីទស្សនាពិព័រណ៍នេះ ខ្ញុំមានភាពរន្ធត់ដែលបានដឹងថា មានប្រជាជនជាច្រើនត្រូវបានសម្លាប់ នៅខេត្តពោធិ៍សាត់ និងបាត់ដំបង ។

**២៥) ផាត់ សុភក្តិ ជាព្រះសង្ឃ មកពីខេត្តបាត់ដំបង**

អាត្មាមានអារម្មណ៍រំភើប នៅពេលដែលអាត្មាបានឃើញពិព័រណ៍នេះ ។ ពិព័រណ៍នេះបានឆ្លុះបញ្ចាំងពីភាពលំបាកក្នុងរបបខ្មែរក្រហម ។ អាត្មាគិតថា គួរតែបន្ថែម ឬផ្លាស់ពិព័រណ៍ ព្រោះនៅមានរឿងរ៉ាវរបស់ជនដែលនៅរស់រានមានជីវិតពីរបបខ្មែរក្រហមជាច្រើនទៀត ដែលត្រូវបង្ហាញ ។ អាត្មានឹងណែនាំមិត្តភក្តិ របស់អាត្មាមកទស្សនាពិព័រណ៍នេះ នៅពេលក្រោយ ។

**២៦) ស្រី ហូ កេទស្រី អាយុ២១ឆ្នាំ ជានិស្សិតផ្នែកកសិកម្ម មកពីសាកលវិទ្យាល័យបាត់ដំបង**

ខ្ញុំគិតថា យើងគួរតែយល់ដឹងអំពីប្រវត្តិសាស្ត្ររបស់ខ្លួនដើម្បីដឹកនាំប្រទេស ។ យើងគួរតែរៀនសូត្រពីមនុស្សចាស់អំពីរបៀបដឹកនាំប្រទេសកាលពីមុន ។ ខ្ញុំធ្លាប់បានឮអំពីរឿងរ៉ាវក្នុងរបបខ្មែរក្រហមពីឪពុកម្តាយរបស់ខ្ញុំ ដែលឪពុកម្តាយរបស់ខ្ញុំធ្លាប់ធ្វើការផាររវែកដី ជីកប្រឡាយ និងធ្វើស្រែ ។ ក្រៅពីរឿងរ៉ាវរបស់ឪពុកម្តាយខ្ញុំ ខ្ញុំធ្លាប់បានរៀនសូត្រអំពីប្រវត្តិសាស្ត្រខ្មែរក្រហមពីកម្មវិធីទូរទស្សន៍ និងប្រភពផ្សេងៗទៀត ប៉ុន្តែមិនបានល្អិតល្អន់ទេ ។

ខ្ញុំចង់ឃើញរូបភាពដែលខ្មែរក្រហមសម្លាប់មនុស្ស ។ ទោះបីជារូបភាពដែលខ្មែរក្រហមសម្លាប់មនុស្សមានភាពឃោរឃៅ ប៉ុន្តែរូបភាពដែលខ្មែរក្រហមសម្លាប់មនុស្សនឹងរំឭកប្រជាជនកម្ពុជាអំពីប្រវត្តិសាស្ត្រ ដែលខ្មែរសម្លាប់ខ្មែរ ។

**ម៉ែន ពិចិត្រ, សេង គន្ធី, ស៊ីវ សាទីណា, ឆាយ ជាទីន និង ផាង ច័ន្ទនិមល**

# ខ្សែភាពយន្តឯកសាររឿង «ក្បង់ទឹកទន្លេ»

«ក្បង់ទឹកទន្លេ» គឺជាខ្សែភាពយន្តឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលទទួលបានការគាំទ្រ និងទិដ្ឋាការពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។ មកដល់ពេលនេះ ខ្សែភាពយន្ត «ក្បង់ទឹកទន្លេ» ទទួលបានពានរង្វាន់លំដាប់ពិភពលោកចំនួន១២ហើយ ។ «ក្បង់ទឹកទន្លេ» បង្ហាញនូវដំណើរជីវិតមួយដ៏វិសេសវិសាល និងមិនធ្លាប់មានពីមុនមក ដែលផ្តើមចេញពីតំបន់ជនបទ ចុងកាត់មាត់ញកព្រៃភ្នំ និងភូមិនេសាទនៅលើផ្ទៃទឹករបស់តួអង្គទាំងបី ។ ខ្សែភាពយន្តនេះបានចាក់បញ្ចាំងនៅសារមន្ទីរសិល្បៈទំនើប សហរដ្ឋអាមេរិក ចាប់ពីថ្ងៃទី១២ ដល់ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣ និងប្រទេសអូទ្រីស ប៊ែលហ្ស៊ិក អាល្លឺម៉ង់ កូរ៉េខាងត្បូង អ៊ីតាលី អង់គ្លេស និងប្រទេសសិង្ហបុរី ។ ខ្សែភាពយន្តឯកសារនេះ ក៏គ្រោងនឹងដាក់បញ្ចាំងតាមសាកលវិទ្យាល័យ និងភូមិចំនួន៦០ ទូទាំងប្រទេសកម្ពុជា ដើម្បីបើកឲ្យមានការពិភាក្សាស្តីពីការផ្លាស់ប្តូរបរិស្ថាន ដើម្បីស្វែងរកដំណោះស្រាយ ។

ខ្សែភាពយន្តនេះក៏មានចាក់បញ្ចាំងជូនទស្សនារៀងរាល់ថ្ងៃសុក្រនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។

ព័ត៌មានបន្ថែមសូមទាក់ទង កញ្ញា សា ហ្វាទីលី តាមរយៈទូរស័ព្ទលេខ: ០១២ ៥១១ ៩១៤ ។

អ៊ីម៉ែល : truthfatily.s@dccam.org គេហទំព័រ : www.ariverchangescourse.com





# ការជម្លៀសដោយបង្ខំ

គោលបំណងរួមរបស់បក្សកុម្មុយនីស្តកម្ពុជា គឺដើម្បីអនុវត្តនូវបដិវត្តន៍សង្គមនិយមដ៏លឿនមួយនៅក្នុងប្រទេសកម្ពុជាដោយល្បឿន "មហាលោតផ្លោះ មហាអស្ចារ្យ" និងដើម្បីការពារបក្សពី "សត្រូវខាងក្នុង និងសត្រូវខាងក្រៅ" ។ វិធីចម្បងមួយនៅក្នុងការសម្រេចឲ្យបាននូវគោលដៅនេះ គឺការជម្លៀសប្រជាជនជាញឹកញាប់ពីទីក្រុង និងទីប្រជុំជននានាទៅកាន់ទីជនបទ ក៏ដូចជាពីទីជនបទមួយទៅកាន់ទីជនបទមួយទៀត ។

នៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ប្រជាជនយ៉ាងច្រើនត្រូវបានជម្លៀសដោយបង្ខំពីផ្ទះរបស់ខ្លួនជាញឹកញាយទៅកាន់ទីតាំងឆ្ងាយៗនៅទីជនបទ ។ ជួនកាលខ្មែរក្រហមបានហៅទីតាំងទាំងនេះថា ជា "ទីតាំងពិសោធសម្រាប់ប្រជាជនថ្មី" ។

គោលនយោបាយនៃការជម្លៀសប្រជាជនដោយបង្ខំពី



ប្រជាជនបានចាកចេញពីទីក្រុង ដោយសារការជម្លៀសរបស់ខ្មែរក្រហម នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥

ទីតាំងមួយទៅកាន់ទីតាំងមួយទៀត (ឧទាហរណ៍ ការជម្លៀសដោយបង្ខំ) ដោយមិនបានផ្ដល់ដំណឹងឲ្យដឹងជាមុនមុនផ្ដល់ជាសំណង ឬ ផ្ដល់មធ្យោបាយផ្លូវច្បាប់ណាមួយបើកឲ្យមានការតវ៉ា បានបង្កឲ្យមានការឈឺចាប់ និងសម្ពាធយ៉ាងធ្ងន់ធ្ងរទៅលើប្រជាជននិងសហគមន៍ ។

នៅក្នុងរយៈពេល៤៥ខែ របបខ្មែរក្រហមបានដាក់ចេញនូវការជម្លៀសប្រជាជនដោយបង្ខំរវាងតំបន់មួយ និងតំបន់មួយទៀត ។ ក្រុមគ្រួសារត្រូវបានបំបែក ប្ដីត្រូវបំបែកចេញពីប្រពន្ធ កូនចេញពីឪពុកម្ដាយ ហើយក្រុមគ្រួសារជាទីស្រឡាញ់ត្រូវបាត់ខ្លួនដោយមិនដឹងមូលហេតុ ដោយគ្មានដាន ។ សមាជិកជាច្រើនរបស់របប លន់ នល់ និងប្រជាជនជាច្រើនដែលត្រូវបានសង្ស័យថា មានសមានចិត្ត ឬជាប់ពាក់ព័ន្ធនឹង “ខ្មាំង” ត្រូវបានចាប់ខ្លួន និងសម្លាប់ចោល ។

គោលនយោបាយនៃការជម្លៀសដោយបង្ខំរបស់បក្សកុម្មុយនីស្តកម្ពុជា បានព្យាយាមបំបែកទំនាក់ទំនងមនុស្ស និងស្ថាប័នដែលធ្លាប់បានគ្រប់គ្រងការរស់នៅរបស់ប្រជាជនកម្ពុជាភាគច្រើននៅមុនបដិវត្តន៍ឲ្យដាច់ដោយឡែកពីគ្នា ។ លើសពីនេះទៀតសម្រាប់រដ្ឋាភិបាលរបស់ លន់ នល់ គោលនយោបាយនេះត្រូវបានរាប់បញ្ចូលទាំងទំនៀមទម្លាប់របស់គ្រួសារ សាសនា អត្តភាពសហគមន៍ជនជាតិភាគតិច និងខ្សែបណ្ដាញបញ្ញវន្ត ព្រមទាំងអ្នកជំនួញផង ។ ប្រសិនបើគ្មានទំនាក់ទំនងនឹងស្ថាប័នទាំងនេះទេ ក្រុមប្រឆាំងនឹងមានការលំបាកក្នុងការរៀបចំការតស៊ូណាមួយ ។ ប្រសិនបើការជម្លៀសដោយបង្ខំបានទប់ស្កាត់អ្នកទាំងនោះពីភាពស្មោះត្រង់ចំពោះឪពុកម្ដាយ ញាតិសន្ដាន សាសនា និងមេដឹកនាំសហគមន៍ទំនៀមទម្លាប់ដទៃទៀត វាជាការងាយស្រួលក្នុងការបញ្ចុះបញ្ចូលប្រជាជនកម្ពុជា ជាពិសេស ក្មេងៗឲ្យមានការជឿជាក់យ៉ាងស្មោះស្ម័គ្រលើ “អង្គការ” ។

ជារួម របបនេះបានបង្កើតឲ្យមានការជម្លៀសប្រជាជនចំនួនបីដំណាក់កាល ៖

១) ការជម្លៀសប្រជាជនចេញពីទីក្រុង ដូចជា ភ្នំពេញ បាត់ដំបង សៀមរាប និងទីប្រជុំជនមួយចំនួនផ្សេងទៀត ដែលបានចាប់ផ្ដើមនៅថ្ងៃទី១៧ មេសា ១៩៧៥ (ដោយរួមបញ្ចូលទាំងការជម្លៀសប្រជាជនតាមរថភ្លើងចេញ នៅក្នុងអំឡុងពេល៦ខែបន្ទាប់មកទៀតដែរ) ។

២) ការជម្លៀសប្រជាជននៅទីជនបទ នៅក្នុងភូមិភាគកណ្ដាល និរតី បស្ចិម និងបូព៌ា ចាប់ពីចុងឆ្នាំ១៩៧៥ ទៅកាន់ផ្នែកផ្សេងទៀតនៃប្រទេសកម្ពុជា ។

៣) ការជម្លៀសប្រជាជនចេញពីភូមិភាគបូព៌ានៅក្នុងឆ្នាំ១៩៧៧ ។

ប្រជាជនទទួលបានការផ្ដល់ដំណឹងឬការពន្យល់តិចតួចណាស់ សម្រាប់តម្រូវការនៃការចាកចេញពីផ្ទះរបស់ខ្លួន ។ នៅក្នុងរយៈពេលប៉ុន្មានថ្ងៃដំបូង បន្ទាប់ពីការដួលរលំនៃទីក្រុងភ្នំពេញទៅក្នុងដៃរបស់កងកម្លាំងខ្មែរក្រហម ប្រជាជនដែលរស់នៅក្នុងទីក្រុងត្រូវបានផ្ដល់ដំណឹងជាញឹកញយដោយចុងកាំភ្លើងថា ខ្លួនត្រូវចាកចេញពីផ្ទះសម្បែងជាបន្ទាន់ ។ ប្រជាជនជាច្រើនដែលមានរថយន្តមានបំណងបើកបរចេញពីទីក្រុង ប៉ុន្តែមានសាំងតិចតួចណាស់ ។ មិនយូរប៉ុន្មាន មធ្យោបាយធ្វើដំណើរត្រូវបានបោះបង់ចោលនៅក្នុងចរាចរដែលណែនណាន់តាន់តាប់ ឬត្រូវបានកងទ័ពខ្មែរក្រហមរឹបអូសយក ។

នៅក្នុង “ការជម្លៀស” ដោយបង្ខំនៅក្នុងទីក្រុងភ្នំពេញ មន្ទីរពេទ្យ វត្តអារាម សាលារៀន ត្រូវបានបោសសម្អាត ហើយអ្នកជំងឺត្រូវបានបង្ខំឲ្យដើរ ខណៈដែលអ្នកជំងឺនៅលើគ្រែរុញ ត្រូវបានអូស ឬរុញតាមរទេះ ។ ចាស់ជរា អ្នកជំងឺ កូន ក្មេង និងស្ត្រីមានផ្ទៃពោះ ត្រូវបានបង្ខំឲ្យដើរទោះជាស្ថិតនៅក្នុងស្ថានភាពណាក៏ដោយ ។ មនុស្សគ្រប់រូបត្រូវតែចាកចេញ ដោយមិនមានការលើកលែង ។

ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញនៅខែមេសាឆ្នាំ១៩៧៥ ស្ថិតនៅក្នុងសភាពចលាចល ការភ័យខ្លាច និងដោយបង្ខំ ។ ប្រជាជនត្រូវបានប្រាប់ឲ្យដឹងថា ខ្លួនត្រូវតែចាកចេញពីផ្ទះដោយគ្មានលក្ខខណ្ឌ ។ ការប្រយុទ្ធគ្នាបន្តិចបន្តួច រវាងទាហាន លន់ នល់ និងកងកម្លាំងរបស់ខ្មែរក្រហមបានបន្តក្នុងអំឡុងពេលនៃការចាកចេញទាំងហ្វូង ដោយបានកាត់ផ្ដាច់ផ្នែកទាំងមូលនៃទីក្រុង និងបានទប់ស្កាត់សមាជិកគ្រួសារមិនឲ្យចាកចេញពីទីក្រុងជាមួយគ្នា ។ នៅគ្រប់ទីកន្លែងទាំងអស់ ដែលមានមនុស្សដើរ មនុស្សម្នាតែងតែមើលឃើញសាកសព និងទ្រព្យសម្បត្តិដែលត្រូវបានបោះបង់

បោល ។ ប៉ុស្តិ៍ត្រួតពិនិត្យ ត្រូវបានដាក់នៅតាមច្រកចេញដើម្បីកំណត់អត្តសញ្ញាណអតីតទាហាន និងមន្ត្រីរដ្ឋការរបស់របប លន់ នល់ ។ ប្រជាជនជាច្រើនបានលាក់អត្តសញ្ញាណរបស់ខ្លួន ពីព្រោះប្រជាជនទាំងនោះភ័យខ្លាចចំពោះការចាប់ខ្លួន ។

ទាហាន លន់ នល់ ត្រូវបានដឹងឮថា បានសម្លាប់អ្នកទោសជាច្រើន ។ ខ្មែរក្រហមបានឆ្លើយតបទៅវិញជាមួយនឹងការកាប់សម្លាប់ដូចគ្នា ។ មនុស្សគ្រប់រូបដែលត្រូវបានរកឃើញថា មានជាប់ពាក់ព័ន្ធជាមួយនឹងអតីតរបបចាស់ត្រូវបានចាប់ខ្លួន និងសម្លាប់ចោលភ្លាមៗ ។ បញ្ញវន្ត អ្នកមានទ្រព្យសម្បត្តិ និងមនុស្សជាច្រើនដែលទទួលការសង្ស័យ ក៏ត្រូវបានចាប់ខ្លួន និងសម្លាប់ចោលដែរ ។ ដូចការរំពឹងទុក ប្រជាជនបានសួរសំណួរថា "តើយើងត្រូវទៅទីណា? តើយើងត្រូវយកអ្វីទៅខ្លះ? ហើយតើពេលណាយើងនឹងត្រឡប់មកវិញ?

នៅពេលដែលខ្មែរក្រហមឲ្យចម្លើយផ្សេងៗគ្នា ហេតុផលចម្បងដែលកងទ័ពខ្មែរក្រហមបានលើកឡើង គឺថាសហរដ្ឋអាមេរិកនឹងមកទម្លាក់គ្រាប់បែកលើទីក្រុងភ្នំពេញ ដូច្នេះប្រជាជនក្នុងទីក្រុងត្រូវតែចាកចេញ ។ មូលហេតុដែលត្រូវបានផ្តល់ឲ្យមួយទៀតគឺថា ខ្មែរក្រហមត្រូវសម្អាតទីក្រុងឲ្យអស់កម្លាំងរបស់ខ្មាំង ។ ប្រជាជនភាគច្រើនត្រូវបានប្រាប់ឲ្យយករបស់ស្រាលៗ ពីព្រោះប្រជាជនទាំងនោះនឹងត្រូវត្រឡប់មកវិញក្នុងរយៈពេលបីថ្ងៃ ។ ប្រជាជនជាច្រើនបានជឿពាក្យឃោសនានេះ ហើយបានចាកចេញជាមួយនឹងអាហារ ទឹក និងថ្នាំពេទ្យបន្តិចបន្តួចតែប៉ុណ្ណោះ ។

បន្ទាប់ពី "ការជម្លៀស" ដោយបង្ខំភ្លាម ទីក្រុងភ្នំពេញស្ទើរតែទទេស្អាត ហើយអ្នកនៅសេសសល់ភាគច្រើន ត្រូវបានបញ្ជូនទៅកាន់ភូមិទាំងឡាយដែលនៅជាយក្រុង ដែលនៅទីនោះប្រជាជនទាំងនេះស្នាក់នៅ និងធ្វើការជាច្រើនខែ ។ នៅក្នុងករណីជាច្រើនប្រជាជនធ្វើដំណើរទៅកាន់កន្លែងទាំងឡាយដែលខ្លួនមានសាច់ញាតិ ឬមានទំនាក់ទំនងផ្សេងៗទៀត ។ បន្ទាប់ពីរយៈពេលប៉ុន្មានខែក្រោយមក ខ្មែរក្រហមបានជម្លៀសប្រជាជនដោយបង្ខំជាថ្មីម្តងទៀត ជាញឹកញាប់ដោយឡាន និងរថភ្លើង ទៅកាន់សហករណ៍ដែលត្រូវបានបង្កើតឡើងនៅទូទាំងប្រទេស ។

ប្រជាជនជាច្រើនបានបោះបង់ចោលការរស់នៅក្នុងទីក្រុងភ្នំពេញទាំងមូល ដោយប្រហែលជាយកជាប់ខ្លួននូវគ្រឿងអលង្ការ លុយកាក់ ឬរបស់មានតម្លៃផ្សេងៗសម្រាប់ប្រើប្រាស់ក្នុងករណីដែលខ្លួនត្រូវការផ្គត់ផ្គង់ ។ មិនមានអ្នកណាម្នាក់ដឹងថា តើខ្លួននឹងត្រូវចាកចេញពីផ្ទះរយៈពេលប៉ុន្មាន ហើយអ្នកដែលស្មានថា ខ្លួននឹងចាកចេញតែរយៈពេលបីថ្ងៃ ពិតជាមិនបានដឹងថា វាគឺជាពេលវេលាចុងក្រោយដែលខ្លួននឹងបានឃើញទីក្រុងភ្នំពេញ (ឬទីក្រុង ឬទីប្រជុំជនដែលខ្លួនរស់នៅ) រយៈពេលជិតបួនឆ្នាំទៀត ។

ការជម្លៀសប្រជាជនជាច្រើនដោយបង្ខំ អាចនិយាយបានថា ជាសោកនាដកម្មមួយសម្រាប់មនុស្សជាច្រើន និងជាការចាប់ផ្តើមនៃយុគសម័យដ៏ខ្មៅងងឹតមួយ... 

នៅក្នុងឆ្នាំ២០០១ រដ្ឋសភាជាតិកម្ពុជាបានអនុម័តច្បាប់មួយ ដើម្បីបង្កើតតុលាការមួយសម្រាប់កាត់ទោសឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តឡើងនៅក្នុងអំឡុងពេលនៃរបបខ្មែរក្រហមពីឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩ ។ តុលាការនេះមានឈ្មោះថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ (អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬ អ.វ.ត.ក) ។ ច្បាប់នេះត្រូវបានកែប្រែនៅឆ្នាំ២០០៤ បន្ទាប់ពីរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងក្នុងការសហការឲ្យដំណើរការអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

មាត្រា៥ និងមាត្រា៦ នៃច្បាប់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានចែងថា មេដឹកនាំជាន់ខ្ពស់ ឬជនទាំងឡាយណាដែលត្រូវបានចាត់ទុកថា ជាអ្នកដែល "ទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គឺត្រូវប្រឈម

និងការកាត់ទោសចំពោះតួនាទីរបស់ខ្លួនក្នុងការប្រព្រឹត្តខុក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ខុក្រិដ្ឋកម្មសង្គ្រាម និងបទខុក្រិដ្ឋដទៃទៀត ។ ការជម្លៀសដោយបង្ខំនូវជនណាម្នាក់ ដែលជនប្រព្រឹត្តបានដឹងថាជននោះរស់នៅទីកន្លែងនោះ ដោយស្របច្បាប់ គឺជាទង្វើហាមឃាត់ ដែលស្ថិតនៅក្នុងនិយមន័យដ៏ទូលំទូលាយនៃខុក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងខុក្រិដ្ឋកម្មសង្គ្រាម ។

ក្នុងប្រវត្តិសាស្ត្រ រដ្ឋាភិបាលដែលរឹតបណ្តឹងសិទ្ធិសេរីភាពរបស់ប្រជាជន និងគ្រប់គ្រងដោយប្រើអំណាច បានប្រើប្រាស់សកម្មភាពជម្លៀសដោយបង្ខំចំពោះប្រជាជនដែលលែងត្រូវការ ឬ ធ្វើឲ្យចុះខ្សោយ ដាក់ទណ្ឌកម្ម ឬគ្រប់គ្រង ក្រុមខ្លះ ដែលកំពុងរស់នៅក្នុងតំបន់ត្រួតត្រារបស់ខ្លួន ។ ទោះជាយ៉ាងណាក៏ដោយ ការជម្លៀសដោយបង្ខំត្រូវបានហាមឃាត់ដោយច្បាប់អន្តរជាតិ ពីព្រោះ សកម្មភាពនេះបានរំលោភលើសិទ្ធិជាមូលដ្ឋានរបស់មនុស្ស ដោយរួមបញ្ចូលទាំងសិទ្ធិរស់នៅក្នុងផ្ទះរបស់នរណាម្នាក់ដោយមានសុវត្ថិភាព និងសេចក្តីថ្លៃថ្នូរ ។ រដ្ឋាភិបាលអាចជម្លៀសប្រជាជនពីផ្ទះរបស់គេ នៅពេលដែលប្រជាជនទាំងនោះយល់ព្រមឲ្យមានការជម្លៀសដោយមិនមានការគាបសង្កត់ហួសហេតុពេក ឬក្នុងករណីខ្លះ រដ្ឋាភិបាលផ្តល់ដល់អ្នកទាំងនោះនូវសំណងផ្នែកហិរញ្ញវត្ថុដែលសមរម្យ និងផ្តល់ឱកាសឲ្យបញ្ចេញយោបល់តាមដំណើរផ្លូវច្បាប់ចំពោះការជម្លៀសនេះ ។ គម្រោងការជម្លៀសដោយបង្ខំធំមួយនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មិនបានផ្តល់ឲ្យជនរងគ្រោះនូវសំណងសមរម្យ និងឱកាសសម្រាប់យុត្តិធម៌ឡើយ ។ នៅក្នុងចំណោមអ្នកជំនាញច្បាប់ វាច្បាស់ណាស់ថា ការជម្លៀសដោយបង្ខំគឺជាអំពើខុសច្បាប់ ។

## សំឡេងរបស់អ្នកដែលត្រូវខ្មែរក្រហមជម្លៀស

អ្នកស្រី យឹម សុវណ្ណ ដែលជាដើមបណ្តឹងរដ្ឋប្បវេណីមួយរូប នៅចំពោះមុខដំណើរការកាត់សេចក្តីនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នៅក្នុងសំណុំរឿង០០២ រៀបរាប់អំពីការជម្លៀសប្រជាជនដោយបង្ខំចេញពីទីក្រុងភ្នំពេញៈ

ពេលនោះម៉ោងប្រហែលជាពរសៀល ហើយមុនដំបូងឪពុករបស់គាត់បដិសេធមិនព្រមចាកចេញ ។ "ខ្មែរក្រហមបានមកដល់ដោយមានកាំភ្លើង និងអង្គរខ្លះ ហើយខ្មែរក្រហមប្រាប់ឪពុកខ្ញុំថា "មិត្តត្រូវតែចាកចេញ បើមិនដូច្នោះទេ អាមេរិកាំងនឹងមកទម្លាក់គ្រាប់បែកលើទីក្រុងភ្នំពេញ" ។ ឪពុកខ្ញុំប្រញាប់ប្រញាល់ទៅរៀបចំវ៉ាលិស និងយកអង្ករខ្លះមុនពេលចាកចេញពីកន្លែងរបស់យើង ។ វាពិតជាលំបាកខ្លាំងណាស់ក្នុងការចាកចេញ ។" អ្នកស្រី សុវណ្ណ បានរំឭកទៀតថា "ខ្មែរក្រហមមានសុទ្ធតែអាវុធទាំងប្រុសទាំងស្រី ។ ខ្មែរក្រហមស្លៀកឯកសណ្ឋានពណ៌ខ្មៅ និងក្រមាពណ៌ក្រហម ។ ខ្មែរក្រហមបានប្រាប់គ្រួសារយើងថា "អង្គការលើ" បានប្រាប់យើងឲ្យចាកចេញ ហើយយើងត្រូវទៅភូមិកំណើតរបស់យើងចំនួនបីថ្ងៃ បើមិនដូច្នេះទេ អាមេរិកាំងនឹងមកទម្លាក់គ្រាប់បែក និងសម្លាប់យើង ។ កងទ័ពឲ្យពេលយើងតែ១៥នាទីប៉ុណ្ណោះដើម្បីចាកចេញ ហើយប្រសិនបើយើងប្រកែក ខ្មែរក្រហមនឹងចាត់វិធានការ" ។

អ្នកស្រីរៀបរាប់ថា អ្នកស្រីបានឃើញកងទ័ពបាញ់បំបាក់សោទ្វារផ្ទះមួយនៅម្តុំផ្សារអូរឫស្សី ហើយបន្ទាប់មក កងទ័ពបានបាញ់នៅពេលដែលប្រជាជនរត់ចេញពីផ្ទះ ។ អ្នកស្រីក៏បានឃើញទាហាន លន់ នល់ ដែលរងរបួសនៅឯពេទ្យទាហានមួយនៅម្តុំបុរីកីឡា ដែលជាកន្លែងកងទ័ព លន់ នល់ ។ យោធាខ្មែរក្រហមរុញអ្នកទាំងនោះទម្លាក់ពីលើគ្រែ ។ អ្នករបួសមួយចំនួនត្រូវបានសាច់ញាតិយកទៅ ប៉ុន្តែអ្នកផ្សេងទៀត ត្រូវបានទុកចោលឲ្យស្លាប់ ។ មិនមានអ្នកណាម្នាក់ដែលស្លាប់នៅក្នុងអំឡុងពេលជម្លៀសទទួលបានការធ្វើបុណ្យសពនោះទេ ។ សាកសពត្រូវបានបោះចោលទៅក្នុងប្រឡាយទឹក ឬទុកចោលនៅតាមដងផ្លូវ ។

លោក ឈុំ សុខា ជាដើមបណ្តឹងរដ្ឋប្បវេណី ហើយនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក្នុងសំណុំរឿង០០២ បានឡើងផ្តល់សក្ខីកម្មអំពីដំណើរចាកចេញពីទីក្រុងភ្នំពេញរបស់ក្រុមគ្រួសាររបស់លោកៈ

លោក សុខា បានរៀបរាប់ថា លោកបានឃើញសាកសពនៅតាមចិញ្ចើមផ្លូវដែលមើលឃើញដោយសារភ្លើងឡាន ផ្សែងភ្លើងឆេះផ្ទះ និងសាកសពដែលត្រូវបានដុតនៅម្តុំពោធិ៍ចិនតុង និងនៅខាងមុខនាយកដ្ឋានដឹកជញ្ជូន ។ លោក សុខា បានពន្យល់ថា លោក និងម្តាយរបស់លោក ប្អូនស្រី ពូ និងជីដូនជីតា បានធ្វើដំណើរទៅមុនដោយថ្មើរជើង ហើយឪពុក និងពូរបស់លោក បាន

ទៅតាមទាន់លោក បន្ទាប់ពីដើរបានពីរគីឡូម៉ែត្រ ។ លោក សុខា បានផ្តល់សក្ខីកម្មថា ឪពុករបស់លោកបានប្រាប់លោកថា គាត់ត្រូវចាប់ខ្លួន ប៉ុន្តែដោយគាត់សម្គាល់ឃើញថា មនុស្សមួយក្រុមត្រូវបានចាប់ចងមួយខ្សែ គាត់បានរត់គេច ហើយបានប្រាប់ក្រុមគ្រួសារឲ្យប្រញាប់ប្រញាល់ ។ លោកបានរៀបរាប់ថា ក្រុមគ្រួសាររបស់លោកបានសម្រាកនៅវត្តអង្គក្រូច អស់រយៈពេលជាច្រើនថ្ងៃ ពីព្រោះប្អូនស្រីរបស់លោកហើមជើង ហើយមិនអាចដើរបាន ។ ក្រោយមក អង្គការបានប្រាប់ថា ក្រុមគ្រួសាររបស់លោកត្រូវបានអនុញ្ញាតឲ្យវិលត្រឡប់ទៅកាន់ភូមិកំណើតដែលស្ថិតនៅភូមិត្បូងក្តី ក្នុងខេត្តព្រៃវែង ។ ដើមបណ្តឹងរដ្ឋប្បវេណីពន្យល់ថា ប្អូនស្រីរបស់លោកនៅតែមានបញ្ហាជើងនៅឡើយ ដូច្នេះ ម្តាយរបស់លោកបានដូរគ្រឿងអលង្ការ និងខោអាវល្អៗ ដើម្បីឲ្យប្អូនស្រីលោកអាចធ្វើដំណើរតាមរទេះបាន ។ បន្ទាប់មក ក្រុមគ្រួសារបានមកដល់ភូមិមួយនៅក្បែរបឹងមួយ ក្នុងស្រុកបាទី ។ គាត់បានស្នាក់នៅទីនោះមួយយប់ មុនពេលបន្តដំណើរទៅកាន់ភូមិបឹងខ្លាក់ ។

រយៈពេលមួយខែបន្ទាប់ពីចាកចេញពីទីក្រុងភ្នំពេញ លោក សុខា បានផ្តល់សក្ខីកម្មថា ក្រុមគ្រួសាររបស់លោកបានមកដល់ភូមិត្បូងក្តី ក្នុងខេត្តព្រៃវែង ដែលជាភូមិកំណើតរបស់គ្រួសារ ។

អ្នកស្រី ឡាយ ប៊ុននី ដែលជាដើមបណ្តឹងរដ្ឋប្បវេណី នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក្នុងសំណុំរឿង០០២ បានឡើងផ្តល់សក្ខីកម្មអំពីការជម្លៀសដោយបង្ខំចេញពីទីក្រុងភ្នំពេញៈ

អ្នកស្រី ប៊ុននី បានផ្តល់សក្ខីកម្មថា កងទ័ពខ្មែរក្រហមបានប្រាប់ប្រជាជនឲ្យចាកចេញតាមគ្រប់មធ្យោបាយដែលមាន ។ កងទ័ពទាំងនេះមិនបានប្រាប់ប្រជាជនថា តើរបស់របរជាប់ខ្លួនអ្វីខ្លះដែលត្រូវយកទៅជាមួយនោះទេ ។ អ្នកស្រីនិយាយថា គ្រួសាររបស់អ្នកស្រីមិនបានយកអង្ករទៅជាមួយទេ ។ ក្រុមគ្រួសារអ្នកស្រីយកតែលុយ ដែលខ្លួនគិតថា អាចប្រើប្រាស់បាននៅតាមផ្លូវ ។ អ្នកស្រីបានបន្ថែមថា កងទ័ពខ្មែរក្រហមមិនបានប្រាប់អ្នកស្រីថា លុយមិនមានប្រយោជន៍ទេ ហើយអ្នកស្រី "មានការអស់សង្ឃឹម" នៅពេលដែលអ្នកស្រីបានដឹងអំពីរឿងនេះនៅតាមផ្លូវ ។

អ្នកស្រី ប៊ុននី ពន្យល់ថា ប្រជាជនដែលមិនអាចដើរដោយខ្លួនឯងបាន ដូចជាអ្នកជំងឺនៅក្នុងមន្ទីរពេទ្យ "នឹងត្រូវរុញដោយរទេះពេទ្យ ឬសែងដោយស្នែង ឬអង្រឹង ។ អ្នកខ្លះដែលមានជំងឺធ្ងន់ធ្ងរអាចត្រូវមនុស្សម្នាក់ទៀតអៀវ" ។ អ្នកស្រីបានរំឭកថា មនុស្សមួយចំនួនសម្រាលកូននៅតាមផ្លូវ ហើយអ្នកជម្លៀសអាចពួសំឡេងស្រែកយំ ។ អ្នកស្រីបន្ថែមថា នៅទីបញ្ចប់ អ្នកជម្លៀសមួយចំនួនរកបានពេទ្យឆ្មប ដើម្បីជួយខ្លួន ។

អ្នកស្រី ប៊ុននី ត្រូវបានបណ្តេញដោយបង្ខំជាមួយនឹងកូនស្រីអាយុ៥ឆ្នាំ ។ អ្នកស្រី ប៊ុននី បានរំឭកអំពីរឿងរបស់កូនស្រីអាយុ៥ឆ្នាំ ថាៈ

នៅពេលយើងមកដល់ស្រុកខ្សាច់កណ្តាល កូនស្រីរបស់ខ្ញុំបានឈឺអស់ពីរបីថ្ងៃរួចទៅហើយ ។ នាងមានជំងឺរាកធ្ងន់ធ្ងរ ។ ខ្ញុំត្រូវបានប្រាប់ឲ្យបេះស្លឹកឈើខ្លះដើម្បីព្យាបាលជំងឺរបស់នាង ។ គ្រប់ក្រុមគ្រួសារទាំងអស់មានជំងឺគ្រុន ។ នៅពេលដែលមីងរបស់ខ្ញុំឃើញដូចនេះ គាត់ចង់យកកូនស្រីរបស់ខ្ញុំទៅនៅជាមួយគាត់ ដើម្បីឲ្យនាងទទួលបានការព្យាបាល ។ ខ្ញុំបានយល់ព្រមឲ្យនាងទៅ ។ ខ្ញុំជឿជាក់ថា កូនស្រីរបស់ខ្ញុំនឹងទទួលបានការព្យាបាល និងថែរក្សាបានត្រឹមត្រូវ ប៉ុន្តែ ខ្ញុំបែរជាបានទទួលដំណឹងថា នាងបានស្លាប់បាត់ទៅហើយ ។

អ្នកស្រី ប៊ុននី ត្រូវបានបង្ខំឲ្យផ្លាស់ប្តូរទីកន្លែងម្តងទៀត ពីស្រុកខ្សាច់កណ្តាលទៅខេត្តពោធិ៍សាត់ ដែលនៅទីនោះ អ្នកស្រីរៀបរាប់ថា អាហារមានសភាពអាក្រក់ ។ អ្នកជម្លៀស "ហូបតាមផ្លូវ ហើយអាហារទាំងនោះ មិនល្អសម្រាប់យើងទេ ។ វាបង្កផលសម្រាប់ក្រពះ" ។

លោក មាស សាវ៉ាន់ ជាវេជ្ជបណ្ឌិតម្នាក់ធ្វើការនៅក្នុងទីក្រុងភ្នំពេញនៅមុនថ្ងៃជ័យជម្នះរបស់កងទ័ពខ្មែរក្រហមលើកម្លាំងទាហានរបស់ លន់ នល់ ។ គាត់ពន្យល់ពីស្ថានភាពនាពេលនោះយ៉ាងសង្ខេបមុនពេលជម្លៀស ។ នៅឯបុរីកីឡា នៅពេលនោះខ្ញុំ (លោក មាស សាវ៉ាន់) កំពុងធ្វើការនៅក្នុងបន្ទប់វះកាត់មួយ ។ មានផ្នែកវះកាត់ចំនួន៥ ដែលត្រូវទទួលអ្នករបួស ។ នេះគឺជាកន្លែងដំបូងដែលអ្នករបួសត្រូវចូល ។

នៅថ្ងៃទី១៦ មានការទម្លាក់គ្រាប់បែកនៅម្តុំផ្សារឌុយម៉ិច ។ មនុស្សទទួលរងរបួស ហើយត្រូវបានបញ្ជូនទៅទីនោះ ។ ខ្ញុំមិនចាំ

ចំនួនអ្នកជំងឺទេ ប៉ុន្តែផ្នែកនីមួយៗបន្តទទួលអ្នករបួស ហើយមិនមានគ្រែគ្រប់គ្រាន់សម្រាប់ទទួលអ្នករបួសទេ ។ ដូច្នេះយើងត្រូវតែឲ្យអ្នករបួសដែលចូលមកថ្មីសម្រាកនៅលើឥដ្ឋ ។

មនុស្សមួយចំនួនមិនមានរបួសធ្ងន់ធ្ងរទេ ហើយអ្នកទាំងនោះអាចដើរបាន ។ មនុស្សមួយចំនួនរបួសជើង ហើយអ្នកទាំងនោះមិនអាចដើរបានទេ ហើយត្រូវតែនៅលើគ្រែ ។ ខ្ញុំអាចនឹកឃើញក្មេងស្រីអាយុ៧ឆ្នាំម្នាក់ដែលមានរបួសជាទម្ងន់ ។ នាងបានប្រាប់ខ្ញុំថា នាងរបួសដោយសារតែគ្រាប់បែក ។ ក្មេងស្រីនោះដេកនៅលើឥដ្ឋ ។ ខ្ញុំមិនអាចជួយសង្គ្រោះជីវិតនាងបាន នៅពេលដែលខ្ញុំត្រូវបានជម្លៀសចេញពីមន្ទីរពេទ្យ ។

នៅព្រឹកថ្ងៃទី១៧ នៅពេលដែលខ្ញុំត្រូវបានប្រាប់ឲ្យចាកចេញ មនុស្សនៅក្នុងមន្ទីរពេទ្យត្រូវបានប្រាប់ឲ្យចេញទៅក្រៅ ។ អ្នកជំងឺមួយចំនួននៅលើគ្រែត្រូវរុញតាមរទេះ ។

លោក សារ៉ាន់ បាននិយាយអំពីអារម្មណ៍របស់គាត់អំពីព្រឹត្តិការណ៍ទាំងនេះ ក្នុងនាមជាវេជ្ជបណ្ឌិត ដែលមានវិជ្ជាជីវៈម្នាក់ៈ ម្តាយរបស់ខ្ញុំបានប្រាប់ខ្ញុំឲ្យធ្វើជាវេជ្ជបណ្ឌិត មិនមែនទាហានទេ ។ ខ្ញុំបានបូជាជីវិតដើម្បីជួយអ្នកជំងឺ ដែលរួមទាំងកងទ័ពរបួសរបស់ខ្មែរក្រហមដែរ ។ ខ្ញុំព្យាបាលរបួសឲ្យកងទ័ពខ្មែរក្រហមពីរនាក់ ។ នៅពេលដែលខ្ញុំត្រូវបានបញ្ជាឲ្យចាកចេញពីភ្នំពេញ ខ្ញុំមានអារម្មណ៍ពិបាកខ្លាំងណាស់ ពីព្រោះនៅពេលនោះ ខ្ញុំគិតថាអ្នកជំងឺ អ្នករបួសនឹងទទួលបានជំនួយយ៉ាងល្អនៅក្នុងអំឡុងពេលជម្លៀស ប៉ុន្តែក្នុងពេលជាមួយគ្នានោះដែរ ខ្ញុំមិនច្បាស់នៅក្នុងចិត្តទេ ថាតើអ្នកទាំងនោះនឹងទទួលបានការថែរក្សាសមរម្យ ។ ខ្ញុំអាចនឹកឃើញដល់ក្មេងស្រីម្នាក់ ដែលមានរបួសធ្ងន់ធ្ងរ ហើយបានអង្វរខ្ញុំឲ្យយកនាងចេញទៅជាមួយផង ។ ខ្ញុំមិនអាចជួយនាងបានទេ ។ ខ្ញុំមានកាតព្វកិច្ចត្រូវតែជួយនាងក្នុងនាមជាវេជ្ជបណ្ឌិត ប៉ុន្តែខ្ញុំមិនអាចជួយនាងឲ្យហួសពីអ្វីដែលខ្ញុំអាចធ្វើបានទេ ។

លោក សារ៉ាន់ បានបន្តថាៈ “នៅពេលនោះ មិនមានបុគ្គលិកពេទ្យ ឬកងទ័ពខ្មែរក្រហមណាម្នាក់នៅទីនោះដើម្បីទទួលមើលការខុសត្រូវក្នុងមន្ទីរពេទ្យឡើយ ។ ខ្ញុំមិនបានដឹងថា មានរឿងអ្វីកើតឡើងបន្ទាប់មកទៀតទេ ។ ប៉ុន្តែ នៅពេលនោះខ្ញុំប្រាកដក្នុងចិត្តណាស់ថា មិនមានអ្នកណាម្នាក់នៅទីនោះ ដើម្បីជួយបុគ្គលិកពេទ្យនៅក្នុងអំឡុងពេលនៃការជម្លៀសទេ” ។

លោក សារ៉ាន់ បានបន្តរៀបរាប់អំពីអារម្មណ៍របស់គាត់នៅពេលដែលគាត់ត្រូវបានបង្ខំឲ្យចាកចេញពីអ្នកជំងឺរបស់គាត់ ៈ ក្នុងនាមខ្ញុំជាបុគ្គលិកពេទ្យ វាគឺជាកាតព្វកិច្ចរបស់ខ្ញុំ ។ និយាយតាមត្រង់ទៅ ខ្ញុំមានអារម្មណ៍ពិបាកក្នុងខ្លួនណាស់ ក្នុងការទុកអ្នកជំងឺចោល ។ នៅក្នុងចិត្តរបស់ខ្ញុំ នៅពេលដែលខ្ញុំទុកអ្នកជំងឺចោល ទីមួយ អ្នកទាំងនោះនឹងស្លាប់ ហើយទីពីរ ប្រសិនបើខ្មែរក្រហមនឹងជួយអ្នកជំងឺ អ្នកនោះនឹងអាចរស់បាន ។ ប៉ុន្តែ រឿងគឺថា តើខ្ញុំអាចជួយអ្វីដល់អ្នកជំងឺបានក្នុងនាមខ្ញុំជាគ្រូពេទ្យ? ខ្ញុំមិនអាចជួយអ្វីបានច្រើនទេ ។ នៅពេលដែលខ្ញុំចាកចេញ ខ្ញុំបានចាកចេញទាំងអារម្មណ៍មិនស្រួល ហើយខ្ញុំនៅតែគិតអំពីប្រពន្ធរបស់ខ្ញុំ ។ ខ្ញុំមានអារម្មណ៍មិនស្រួលសោះនៅពេលដែលខ្ញុំចាកចេញ ពីព្រោះខ្ញុំបានទុកអ្នកជំងឺចោល ជាពិសេស ក្មេងស្រីម្នាក់ ហើយខ្ញុំនៅតែនឹកឃើញរូបភាពក្មេងស្រីនេះនៅឡើយ ។

មុនដំបូង យើងត្រូវចាកចេញពីភ្នំពេញតែបីថ្ងៃប៉ុណ្ណោះ ហើយនៅក្នុងអំឡុងពេលបីថ្ងៃនេះ វាមានការលំបាកខ្លាំងណាស់ នៅពេលដែលយើងធ្វើដំណើរនៅតាមផ្លូវ ។ បន្ទាប់មក យើងឆ្លងកាត់ស្ពានព្រះមុនីវង្ស ។ បន្ទាប់ពីរយៈពេលបីថ្ងៃ បានកន្លងផុតទៅ នៅតែមានមនុស្សច្រើននៅឡើយនៅត្រើយស្ពានម្ខាងទៀត ។ ខ្ញុំនៅតែរង់ចាំប្រពន្ធរបស់ខ្ញុំ ហើយខ្ញុំនៅតែមានសង្ឃឹមថា ខ្ញុំនឹងត្រូវបានអនុញ្ញាតឲ្យត្រឡប់ទៅវិញបន្ទាប់ពីរយៈពេលបីថ្ងៃ ។ ខ្ញុំមានការបារម្ភអំពីប្រពន្ធរបស់ខ្ញុំខ្លាំងណាស់ ដោយសារគាត់មានផ្ទៃពោះ និងមិនស្គាល់ភ្នំពេញច្បាស់ ។ បន្ទាប់ពីរយៈពេលបីថ្ងៃបានកន្លងផុតទៅ ខ្ញុំបានស្វែងរកប្រពន្ធរបស់ខ្ញុំនៅក្នុងចំណោមហ្វូងមនុស្សដែលកំពុងតែឆ្លងស្ពាននៅឡើយ ។ នៅទីបញ្ចប់ ខ្ញុំអស់សង្ឃឹម ហើយខ្ញុំត្រូវតែស្វែងរកមធ្យោបាយផ្សេងទៀត ដើម្បីស្វែងរកប្រពន្ធរបស់ខ្ញុំនៅភូមិកំណើតរបស់ប្រពន្ធខ្ញុំ ។

បន្ទាប់ពីរយៈពេលបីថ្ងៃបានកន្លងផុតទៅ មានការប្រកាសមួយពីភ្នំពេញតាមមេក្រូអំពាវនាវឲ្យអតីតមន្ត្រីរដ្ឋការត្រឡប់ទៅធ្វើការនៅភ្នំពេញវិញ ។ ខ្ញុំបានឃើញមនុស្សមួយចំនួនត្រឡប់ទៅភ្នំពេញវិញ ។ ប៉ុន្តែអ្នកទាំងនោះទៅតែខ្លួនឯង ដោយមិនមានសមាជិកគ្រួសារទៅជាមួយទេ ហើយខ្ញុំមិនបានឃើញអ្នកទាំងនោះ

ត្រឡប់មកវិញទេ ។ ជាមួយនឹងស្ថានភាពនេះ ខ្ញុំគិតថា មានបញ្ហាអ្វីមួយកើតឡើងនៅភ្នំពេញមិនខាន ហើយខ្ញុំមានការខ្វល់ខ្វាយអំពីបញ្ហានេះណាស់ ។

លោកវេជ្ជបណ្ឌិត បានបន្តពន្យល់អំពីរបៀបដែលគាត់ឆ្លងកាត់ប៉ុស្តិ៍ត្រួតពិនិត្យជាច្រើននៅតាមផ្លូវទៅកាន់ភូមិកំណើតរបស់ប្រពន្ធគាត់ ។ គាត់ត្រូវបានសួរចម្លើយនៅគ្រប់ប៉ុស្តិ៍ត្រួតពិនិត្យនីមួយៗ ហើយគាត់បានរៀនកុហកខ្មែរក្រហមបានយ៉ាងឆាប់រហ័ស ពីព្រោះលោកមិនទុកចិត្តខ្មែរក្រហមទាំងនោះ ។

និយាយតាមត្រង់ទៅ ខ្ញុំមិនទុកចិត្តខ្មែរក្រហមទេ ។ ខ្ញុំមិនទុកចិត្ត ពីព្រោះខ្ញុំមើលឃើញថា អ្នកដែលត្រូវបានហៅឲ្យត្រឡប់ទៅភ្នំពេញវិញ មិនដែលឃើញត្រឡប់មកវិញទេ ។ ខ្ញុំមិនទុកចិត្តពីព្រោះខ្មែរក្រហមនិយាយអំពីការទម្លាក់គ្រាប់បែកភ្លាមៗ ហើយយើងត្រូវតែជម្លៀសរយៈពេលបីថ្ងៃប៉ុណ្ណោះ ប៉ុន្តែខ្មែរក្រហមកុហក ។ រឿងនេះមិនបានកើតឡើងទេ ។ ជាការពិតណាស់ ប្រសិនបើប្រជាជនត្រូវបានអនុញ្ញាតឲ្យត្រឡប់មកវិញ ពួកគេប្រាកដជាអាចរស់រានមានជីវិតបាន ។ ប៉ុន្តែ រឿងនេះមិនបានកើតឡើងទេ ដូច្នេះខ្ញុំបានសម្រេចចិត្តថា ខ្ញុំត្រូវតែកុហក ។

មកដល់ព្រឹត្តិការណ៍ដែលបានកើតឡើង បន្ទាប់ពីលោកបានមកដល់ភូមិកំណើតរបស់ប្រពន្ធ លោក សារ៉ាន់ បាន និយាយថា ៖ នៅពេលដែលខ្ញុំបានមកដល់ភូមិ ម្តាយក្មេកខ្ញុំយំពីព្រោះគាត់មិនបានឃើញប្រពន្ធរបស់ខ្ញុំ ។ ខ្ញុំ ខ្លួនឯងមានការខកចិត្តយ៉ាងខ្លាំង ពីព្រោះខ្ញុំមិនបានឃើញប្រពន្ធរបស់ខ្ញុំ ។

## ទួលពោធិ៍ជ្រៃ

នៅឆ្នាំ១៩៧៥ ទួលពោធិ៍ជ្រៃគឺជាវាលដីធំមួយ ដែលស្ថិតនៅជិតទន្លេសាប និងព្រៃលិចទឹក ។ ទោះជាយ៉ាងនេះក្តី នៅខែមេសា ឆ្នាំ១៩៧៥ កន្លែងនេះត្រូវបានដឹងថា ជាទីតាំងសម្លាប់ទាហាន លន់ នល់ និងជនស៊ីវិលរាប់ពាន់នាក់ ។ ទីតាំងនេះ ជាទីតាំងដែលមានការសម្លាប់រង្គាលដ៏អាក្រក់បំផុតមួយក្នុងអំឡុងពេលនៃការជម្លៀសដោយបង្ខំជាលើកដំបូងរបស់របបកម្ពុជាប្រជាធិបតេយ្យ នៅពេលដែលខ្មែរក្រហមធ្វើការបោសសម្អាតទីក្រុង និងចម្រាញ់រកអតីតមន្ត្រីរបស់ លន់ នល់ និងអ្នកដែលមានចិត្តមេត្តា ។

នៅថ្ងៃទី១៧ មេសា ១៩៧៥ កងយោធារបស់ លន់ នល់ ក្នុងខេត្តពោធិ៍សាត់ បានទទួលសេចក្តីណែនាំតាមរយៈវិទ្យុជាតិផ្សាយពីភ្នំពេញឲ្យទម្លាក់អាវុធចុះ ។ មកដល់ថ្ងៃទី១៩ ខែមេសា ខ្មែរក្រហមបានចូលកាន់កាប់ខេត្តពោធិ៍សាត់ ។ ភ្លាមៗបន្ទាប់ពីនេះ ខ្មែរក្រហមបានដឹកទាហាន លន់ នល់ តាមរថយន្តទៅការិយាល័យនៅទីរួមខេត្ត ទៅជួបមេដឹកនាំខ្មែរក្រហម ។ កិច្ចប្រជុំមានរយៈពេលបីទៅបួនម៉ោង ហើយមានទាហាន និងមន្ត្រីរដ្ឋការស៊ីវិលប្រមាណ ៥០០នាក់ បានចូលរួម ។

នៅកិច្ចប្រជុំ ទាហាន លន់ នល់ ទទួលបានវគ្គបណ្តុះបណ្តាលអប់រំនយោបាយដើម្បីត្រៀមខ្លួនជួបជាមួយអង្គការនៅថ្ងៃបន្ទាប់ ។ ខ្មែរក្រហមក៏បានជំរុញឲ្យអ្នករស់នៅក្នុងទីរួមខេត្តពោធិ៍សាត់ចាកចេញដែរ ។ ទាហាន នល់ នល់ ត្រូវបានប្រាប់ថា ខ្លួននឹងត្រូវបានបញ្ជូនទៅចូលរួមវគ្គបណ្តុះបណ្តាល និងទៅជួបជាមួយសម្តេចព្រះនរោត្តម សីហនុ ។ ទាហានទាំងនោះក៏ត្រូវបានប្រាប់បន្ថែមទៀតថា ខ្លួននឹងទទួលបានតួនាទីរបស់ខ្លួនឡើងវិញបន្ទាប់ពីកិច្ចប្រជុំ ។ អ្នកដែលចូលរួមនៅក្នុងកិច្ចប្រជុំ រួមមាន មន្ត្រីយោធា លន់ នល់ ដែលមានឋានន្តរស័ក្តិចាប់ពីអនុសេនីយ៍ត្រីរហូតដល់ឧត្តមសេនីយ៍ ។ បន្ទាប់ពីកិច្ចប្រជុំ ទាហាន លន់ នល់ ហាក់ដូចជាមានការសប្បាយចិត្ត ដោយបាននិយាយលេងជាមួយសាច់ញាតិ ខណៈពេលរង់ចាំ ហើយប្រាប់សាច់ញាតិថា ខ្លួននឹងទៅចូលរួមវគ្គសិក្សា និងជួបជាមួយសម្តេច ។

យោងតាមសក្ខីកម្មរបស់លោក សាត លីម បន្ទាប់ពីកិច្ចប្រជុំជាមួយខ្មែរក្រហម ទាហាន លន់ នល់ ត្រូវបានដឹកតាមឡានទៅកាន់កន្លែងប្រជុំជាមួយអង្គការ ដែលសំដៅទៅកាន់ទួលពោធិ៍ជ្រៃ ។ បើយោងតាមមនុស្សម្នាក់ទៀតឈ្មោះ អ៊ុង ឆាត់ ទាហាន លន់ នល់ ហាក់ដូចជាឡើងឡានដោយស្ម័គ្រចិត្ត ។ នៅឯបន្ទាយភូមិពោរ ខ្មែរក្រហមបានដាក់ប៉ុស្តិ៍ត្រួតពិនិត្យ ដើម្បីការពារកុំឲ្យប្រជាជនធ្វើដំណើរចូលទៅកាន់តំបន់នោះ ។ ខ្មែរក្រហមអនុញ្ញាតឲ្យឡានចូលទៅកាន់បន្ទាយម្តងតែមួយប៉ុណ្ណោះ ។

ឡានដែលពេញទៅដោយទាហាន លន់ នល់ បានចាកចេញពីបន្ទាយភូមិពោធិ៍ម្តងមួយ ក្នុងចន្លោះពី២០នាទីម្តង ។ របាយការណ៍មួយចំនួនអះអាងថា ឡានទាំងនោះដឹកសុទ្ធតែទាហាន និងមន្ត្រីស៊ីវិលរបស់ លន់ នល់ ។ ខ្មែរក្រហមនឹងមិនអនុញ្ញាតឲ្យឡានមួយ

ទៀតចូលទៅកាន់ទួលពោធិ៍ជ្រៃ រហូតដល់គេឃើញឡានដែលចូលទៅមុនត្រឡប់មកវិញ ។ អ្នកភូមិកត់សម្គាល់ឃើញថា ទាហាន លន់ នល់ ហាក់ដូចជាមានអារម្មណ៍ធូរស្រាលនៅលើឡានឆ្ពោះទៅកាន់ទីតាំងនោះ ដោយសារទាហានទាំងនេះត្រូវបានប្រាប់ថា ខ្លួននឹងជួបជាមួយអង្គការ និងសម្តេច ទោះជាយ៉ាងនេះក្តី ឡានត្រឡប់មកវិញ ដោយគ្មានមនុស្សជិះ ។ អ្នកភូមិបានរាយការណ៍ថា បានឮសំឡេងគ្រាប់កាំភ្លើងនៅក្បែរភូមិ ។ ទាហាន លន់ នល់ ដែលត្រូវបានបញ្ជូនទៅកាន់ទួលពោធិ៍ជ្រៃ ត្រូវបានសម្លាប់ ។ វាមិនច្បាស់លាស់ទេ ថាតើមានទាហាន លន់ នល់ ប៉ុន្មាននាក់ ដែលត្រូវបានសម្លាប់នៅទួលពោធិ៍ជ្រៃ ហើយការប៉ាន់ស្មាន គឺស្ថិតនៅពីចន្លោះយ៉ាងតិច២.០០០នាក់ ហើយអាចមានចំនួនច្រើនរហូតដល់ទៅ៨.០០០នាក់ ។

វាលពិឃាដទួលពោធិ៍ជ្រៃ មានប្រតិបត្តិការចាប់ពីចុងឆ្នាំ១៩៧៥ រហូតដល់ឆ្នាំ១៩៧៧ ដែលនៅក្នុងរយៈពេលនោះ ការសម្លាប់អតីតទាហាន និងមន្ត្រីស៊ីវិលក្នុងទ្រង់ទ្រាយធំត្រូវបានធ្វើឡើង ។

## សំឡេងរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

លោក សាត លីម ដែលជាអតីតទាហានខ្មែរក្រហម និងជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក្នុងសំណុំរឿង០០២ បានធ្វើសក្ខីកម្មអំពីអ្វីដែលលោកបានឃើញ និងឮ នៅពេលលោកស្ថិតនៅក្នុងតំបន់ទួលពោធិ៍ជ្រៃ ក្នុងខែមេសា ឆ្នាំ១៩៧៥ ។

លោក លីម បានផ្តល់សក្ខីកម្មថា ទាហាន លន់ នល់ ប្រមាណ ៣.០០០នាក់ ត្រូវបានសម្លាប់នៅក្នុងអំឡុងពេលនៃការវាយប្រហារចុងក្រោយទៅលើទួលពោធិ៍ជ្រៃ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។ លោក លីម កត់សម្គាល់ឃើញថា ទាហាន លន់ នល់ បានចុះចាញ់ដោយលើកទង់ស នៅបន្ទាយទួលពោធិ៍ជ្រៃ ។ លោកជឿជាក់ថា មានទាហានប្រហែល ១០០នាក់ ដែលស្លៀកសម្លៀកបំពាក់យោធា និងកងកុម្ម៉ង់ដូប៉ុន្មាននាក់នៅក្នុងសម្លៀកបំពាក់ស៊ីវិល ។ នៅពេលដែលទាហានទាំងនោះចុះចាញ់ អ្នកទាំងនោះត្រូវបានដកហូតអាវុធ ហើយត្រូវបានប្រមូលផ្តុំជាក្រុមៗ ។ នៅទីបញ្ចប់ទាហាន លន់ នល់ ត្រូវបានបញ្ជូនចេញពីទីរួមខេត្តទៅកាន់ទួលពោធិ៍ជ្រៃ ដែលនៅទីនោះពួកគេត្រូវបានសម្លាប់ ។

អ្នកស្រី យឹម សុវណ្ណ ដែលជាដើមបណ្តឹងរដ្ឋប្បវេណីមួយរូបនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានៅក្នុងសំណុំរឿង០០២ បានផ្តល់សក្ខីកម្មអំពីអ្វីដែលអ្នកស្រីបានឃើញ និងបានឮនៅពេលដែលអ្នកស្រីនៅឯតំបន់ទួលពោធិ៍ជ្រៃនៅចុងឆ្នាំ១៩៧៦ ។

អ្នកស្រី សុវណ្ណ បានឆ្លងកាត់ឃុំទួលពោធិ៍ជ្រៃជាញឹកញាប់នៅចុងឆ្នាំ១៩៧៦ និងដើមឆ្នាំ១៩៧៧ ដើម្បីទៅប្រមូលស្បូវ ។ អ្នកភូមិនៅពោធិ៍សាត់បានប្រាប់អ្នកស្រីថា ទាហាន លន់ នល់ ត្រូវបានសម្លាប់នៅទួលពោធិ៍ជ្រៃ ។ អ្នកស្រី សុវណ្ណ បានឮពីកងទ័ពខ្មែរក្រហមថា ទាហាន លន់ នល់ បន្ទាប់ពីទទួលបានការណែនាំពីកងទ័ពខ្មែរក្រហម ត្រូវបានដឹកតាមឡានទៅកាន់ទួលពោធិ៍ជ្រៃដើម្បីសម្លាប់ នៅខែមេសា ឆ្នាំ១៩៧៥ ។ អ្នកភូមិបានប្រាប់អ្នកស្រីសុវណ្ណ ថា ការសម្លាប់បានកើតឡើងប្រហែល “កន្លះខែ” ។ អ្នកស្រីក៏បានឃើញទួលមួយដែលពោរពេញទៅដោយពំនូកដីនៅឯទួលពោធិ៍ជ្រៃ ដែលអ្នកស្រីសន្និដ្ឋានថា ជាកន្លែង “កប់ខ្មោច” ។ អ្នកស្រីបានជួបជាមួយប្រជាជនដែលមកពីសហករណ៍ក្បាលឈើពុក ដែលសាច់ញាតិរបស់អ្នកទាំងនោះត្រូវបានសម្លាប់នៅទីនោះ ។ អ្នកស្រីបានពណ៌នាទីតាំងនោះថាជាវាលធំមួយ ដែលស្ថិតនៅជិតទន្លេសាបនិងជិតព្រៃលិចទឹក ។ អ្នកស្រី សុវណ្ណ បានកត់សម្គាល់ថា អ្នកស្រីមិនបានដឹងអំពីតួលេខពិតប្រាកដ អំពីចំនួនទាហាន លន់ នល់ ដែលបានស្លាប់នៅទួលពោធិ៍ជ្រៃនោះទេ ។ អ្នកស្រីបានកត់សម្គាល់ឃើញថា មិនមែនតែ ទាហាន លន់ នល់ នោះទេ មន្ត្រីស៊ីវិលពីរបបចាស់ក៏ត្រូវបានប្រមូលផ្តុំ ហើយបញ្ជូនទៅសម្លាប់នៅទួលពោធិ៍ជ្រៃដែរ ។

លោក អ៊ុង ឆាត់ ដែលជាអតីតយោធាខ្មែរក្រហម និងជាសាក្សីមួយរូបនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក្នុងសំណុំរឿង០០២ បានធ្វើសក្ខីកម្មអំពីអ្វីដែលលោកបានឃើញ និងបានឮនៅពេលដែលលោកនៅទួលពោធិ៍ជ្រៃ ក្នុងអំឡុងខែមេសា ឆ្នាំ១៩៧៥ ។

លោក ឆាត់ បានរៀបរាប់ថា លោកបានប្រទះឃើញទាហាន

លន់ នល់ នៅឯបន្ទាយទួលពោធិ៍ជ្រៃ ។ “អង្គការអនុញ្ញាតឲ្យឡានចូលទៅទីនោះម្តងមួយតែប៉ុណ្ណោះ ។ ខ្ញុំបានឃើញយោធាខ្មែរក្រហមរាប់រយនាក់ឡោមព័ទ្ធទាហាន លន់ នល់ ។ កងទ័ពខ្មែរក្រហមក៏បានដាក់ប៉ុស្តិ៍ត្រួតពិនិត្យនៅទីនោះ ដើម្បីហាមឃាត់មិនឲ្យប្រជាជនធ្វើដំណើរទៅកាន់តំបន់នោះ ។ ខ្ញុំត្រូវបានយោធាបញ្ឈប់ ហើយសាកសួរ ។ ប៉ុន្តែដោយសារខ្ញុំមានក្រដាសអនុញ្ញាត យោធាបានអនុញ្ញាតឲ្យខ្ញុំឆ្លងកាត់ ។ នៅពេលដែលខ្ញុំនៅទីនោះ ខ្ញុំបានឃើញយោធាខ្មែរក្រហមអនុញ្ញាតឲ្យឡានឆ្លងកាត់តំបន់នោះម្តងមួយៗ ក្នុងចន្លោះ ២០នាទីម្តង ។ ខ្មែរក្រហមនឹងមិនអនុញ្ញាតឲ្យឡានមួយទៀតចូលទៅកាន់ទួលពោធិ៍ជ្រៃទេ រហូតដល់បានឃើញឡានដែលចូលទៅមុនត្រឡប់មកវិញ ។ ក្រោយមក ខ្ញុំបានឃើញឡានដែលបានដឹកទាហាន លន់ នល់ ទៅកាន់ទីនោះមុននេះបន្តិច ត្រឡប់មកវិញដោយគ្មានមនុស្សជិះ” ។

ក្រោយមក លោក ឆាត់ និងអ្នកភូមិពីរនាក់ទៀត បានទៅមើលសាកសពក្នុងបន្ទាយទួលពោធិ៍ជ្រៃ ។ លោកបានរាយការណ៍ថា សាកសពទាហានទាំងអស់ស្ថិតនៅលើដី ដែលមានក្បាលបែរទៅទិសខាងជើង ។ ទាហានទាំងនេះស្លៀកសម្លៀកបំពាក់ស៊ីវិលជាជាងឯកសណ្ឋានយោធា ។ សាកសពត្រូវបានចងភ្ជាប់គ្នាជាក្រុមដោយខ្សែពួរ ដែលមានពី១៥ ទៅ២០នាក់ ដោយដៃរបស់អ្នកទាំងនោះត្រូវបានចងទៅខាងក្រោយ ។

លោក សុម អាឡាត ដែលជាអតីតទាហាន លន់ នល់ និងជាសាក្សីមួយរូបនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក្នុងសំណុំរឿង០០២ បានផ្តល់សក្ខីកម្មអំពីអ្វីដែលលោកបានឃើញ និងបានឮនៅពេលដែលលោកនៅឯតំបន់ទួលពោធិ៍ជ្រៃក្នុងខែមេសា ឆ្នាំ១៩៧៥ ។

នៅឯកិច្ចប្រជុំនៅសាលាខេត្ត ខ្មែរក្រហមបានអប់រំយើងអំពីគោលនយោបាយផ្សះផ្សា និងអំពីការកសាងប្រទេស ។ ហើយចុងក្រោយ ខ្មែរក្រហមនិយាយអំពីការជឿជាក់នៅក្នុងការទៅទទួលអង្គការ ។ នេះគឺជាវិធីសាស្ត្ររបស់ខ្មែរក្រហម ដូច្នេះ យើងមានការជឿជាក់ទៅលើខ្មែរក្រហម ។ ជាទូទៅ យើងមិនបានដឹងថានឹងមានអ្វីកើតឡើងនោះទេនៅពេលអនាគត ប៉ុន្តែយើងទាំងអស់គ្នាយល់ព្រមទៅចូលរួមការជួបជុំនោះ ។

ទួលពោធិ៍ជ្រៃមានចម្ងាយប្រហែល២០គីឡូម៉ែត្រពីខេត្ត ។ នៅពេលដែលយើងត្រូវបានប្រមូលផ្តុំឲ្យទៅទួលពោធិ៍ជ្រៃ ដែលនេះគឺជាការទៅទទួលអង្គការ ខ្ញុំបានយល់ព្រមទៅ ប៉ុន្តែនៅពេលនោះ រថយន្តដែលខ្ញុំជិះឈប់នៅពាក់កណ្តាលផ្លូវ ។

តាមពិតទៅ ខ្ញុំចង់ទៅជាមួយនឹងឡានមួយនោះ ប៉ុន្តែដោយវាមានមនុស្សពេញទៅហើយ ខ្ញុំត្រូវបានប្រាប់ឲ្យចាំជិះឡានបន្ទាប់ ។ ដូច្នេះ ខ្ញុំខ្លួនឯង មិនបានទៅដល់ទួលពោធិ៍ជ្រៃទេ ។ ទោះជាយ៉ាងនេះក្តី រយៈពេលបីថ្ងៃក្រោយមក ខ្ញុំបានឮថា មនុស្សទាំងនោះត្រូវបានសម្លាប់ ។

ទាក់ទងទៅនឹងការទៅទទួលអង្គការ យើងមិនដែលបានឮអំពីអង្គការទេ នៅពេលដែលយើងបានឮអំពីផ្នែករដ្ឋបាល ។ ដូច្នេះ យើងត្រូវបានប្រាប់ថា យើងនឹងទៅទទួលអង្គការ ហើយយើងចង់ជួបអង្គការ ពីព្រោះយើងសង្ឃឹមថា បន្ទាប់ពីយើងផ្សះផ្សាជាមួយគ្នារួច យើងនឹងប្រមូលកម្លាំងគ្នាដើម្បីកសាងប្រទេស ប៉ុន្តែខ្ញុំមិនដែលដឹងថា អង្គការជាអ្នកណាទេ ។

**គម្រោងសារមន្ទីរនៃការចងចាំ**


# ស្តាប់រឿងរ៉ាវប្រវត្តិសាស្ត្រតាមវិទ្យុ

មជ្ឈមណ្ឌលឯកសារកម្ពុជាមានកម្មវិធី “សំឡេងអំពើប្រល័យពូជសាសន៍ ៖ យុត្តិធម៌ និងការអត់ឃ្មាន” ចាក់ផ្សាយតាមស្ថានីយ៍វិទ្យុ ◆ វិទ្យុជាតិកម្ពុជា *FM 105.75 MHz* រាជធានីភ្នំពេញវេលាម៉ោង១រសៀល និងម៉ោង៧និង៣០នាទីល្ងាច ◆ វិទ្យុខេត្តកំពត *FM 93.25 MHz* វេលាម៉ោង៧ព្រឹក និងម៉ោង៧ល្ងាច ◆ វិទ្យុខេត្តព្រះវិហារ *FM 99 MHz* វេលាម៉ោង៧:៣០ព្រឹក និងម៉ោង៤រសៀល ◆ វិទ្យុខេត្តបាត់ដំបង *FM 103.25 MHz* វេលាម៉ោង៨ព្រឹក និងម៉ោង៤រសៀល ។

សម្រាប់ព័ត៌មានលម្អិត សូមទាក់ទង ម៉ែន ពិចិត្រ តាមរយៈរយៈទូរស័ព្ទ ០២៣ ២១១ ៨៧៥ ឬ០៩២ ១៦៨ ៥៤៣ ។

# សំណុំរឿង០០៣ និង ០០៤ : និយមន័យនៃពាក្យអ្នកទទួលខុសត្រូវខ្ពស់បំផុតផ្អែកលើច្បាប់ព្រហ្មទណ្ឌអន្តរជាតិ

*(នៅមានត)*

***ចំណងនៃឆន្ទានុសិទ្ធិ និងការវិនិច្ឆ័យតាមលក្ខណៈវិជ្ជាជីវៈត្រឹមត្រូវ***

ដោយសារអត្ថន័យនៃពាក្យ "ទទួលខុសត្រូវខ្ពស់បំផុត" ចង្អុលបង្ហាញតិចតួចក្នុងបរិបទនៃយុត្តាធិការបុគ្គលសម្រាប់ឧក្រិដ្ឋកម្មអន្តរជាតិ ហើយដូច (ដែលត្រូវបានចង្អុលបង្ហាញដោយលោក ហេដ័រ និង សេហ៊័រ) ប្រវត្តិនៃការចរចា និងច្បាប់ត្រាវូ ប្រេប៉ាទ័រ (Travaux prépatoires ឬ Preparatory works) រកឃើញថា ចំនួនជនសង្ស័យជាក់ស្តែងមិនត្រូវបានយល់ស្របគ្នានៅឡើយទេ ។ មាត្រា១២(១) នៃកិច្ចព្រមព្រៀង ចែងយ៉ាងច្បាស់ថា ច្បាប់ប្រទេសកម្ពុជាគួរតែត្រូវបានផ្តល់ជាទស្សនៈដើម្បីពិភាក្សាក្នុងការចង្អុលបង្ហាញ ។ ទោះបីជាយ៉ាងណាក្តី ការប្រើប្រាស់យុត្តាធិការបុគ្គលដើម្បីព្យាករណ៍លើកម្រិតជាប់ពាក់ព័ន្ធនៃស្ថានទម្ងន់ទោស បានប៉ះពាល់យ៉ាងខ្លាំងដល់មូលដ្ឋានច្បាប់ព្រហ្មទណ្ឌក្នុងស្រុក ដោយសារការចោទប្រកាន់បទឧក្រិដ្ឋព្រហ្មទណ្ឌក្នុងស្រុកភាគច្រើនត្រូវបានសន្មតថា បុគ្គលណាក៏ដោយដែលសង្ស័យចំពោះការប្រព្រឹត្តបទឧក្រិដ្ឋធ្ងន់ធ្ងរ នឹងត្រូវបានស៊ើបអង្កេត និងត្រូវជំនុំជម្រះ ប្រសិនបើមានភស្តុតាងនោះ ។ នៅក្នុងប្រព័ន្ធច្បាប់ដូច្នេះសម្រាប់ព្រះរាជអាជ្ញា ឬចៅក្រម មិនអាចកំណត់ថា បុគ្គលម្នាក់ត្រូវតែទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មធ្ងន់ធ្ងរនោះទេ ប៉ុន្តែមិនមែនជាជនសង្ស័យដ៏សមស្របដើម្បីធ្វើការជំនុំជម្រះ ដោយសារបុគ្គលនោះ មិនស្ថិតនៅក្នុងចំណោម "អ្នកទទួលខុសត្រូវខ្ពស់បំផុត" សម្រាប់ឧក្រិដ្ឋកម្ម ។ ផ្ទុយមកវិញ ក្រមព្រហ្មទណ្ឌក្នុងស្រុកកំណត់ជាមុនថា ប្រសិនបើមានភស្តុតាងគ្រប់គ្រាន់ ដែលអាចបញ្ជាក់ថា បុគ្គលម្នាក់ជាប់ទាក់ទងនឹងឧក្រិដ្ឋកម្ម បុគ្គលនោះនឹងត្រូវផ្តន្ទាទោសដោយមិនចាំបាច់សួរចម្លើយបន្ថែម ។

ទាក់ទងនឹងការសន្មតទូទៅដែលថា ឧក្រិដ្ឋកម្មធ្ងន់ធ្ងរ នឹងត្រូវបានចោទប្រកាន់ដោយយោងលើភស្តុតាងមិនមានបញ្ញត្តិនៅក្នុងច្បាប់ព្រហ្មទណ្ឌរបស់ប្រទេសកម្ពុជា ដែលផ្តល់ការណែនាំក្នុងការបកស្រាយថា តើបុគ្គលប្រភេទណាត្រូវបានចាត់ទុកថាជា "អ្នកទទួលខុសត្រូវខ្ពស់បំផុត" សម្រាប់ឧក្រិដ្ឋកម្មអន្តរជាតិនៅឡើយទេ ។ ផ្ទុយទៅវិញ ក្រមនីតិវិធីព្រហ្មទណ្ឌរបស់ប្រទេសកម្ពុជា ដែលបានអនុម័តដោយក្រសួងយុត្តិធម៌ និងចូលជាធរមាននៅក្នុងឆ្នាំ២០០៧ បានផ្តល់ការចង្អុលបង្ហាញទាក់ទងនឹងការអនុវត្តកិច្ចដំណើរការនីតិវិធីស៊ើបអង្កេតមុនការជំនុំជម្រះ និងកាតព្វកិច្ច និងព្រំដែននៃឆន្ទានុសិទ្ធិទាក់ទងនឹងនីតិវិធីទាំងនេះ ។ សម្រាប់ប្រធានបទនេះ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាមានភាពស្រដៀងគ្នាទៅនឹងនីតិវិធីស៊ើបអង្កេតនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ក្រមនីតិវិធីព្រហ្មទណ្ឌនោះចែងថា ការចោទប្រកាន់នៅតុលាការក្នុងស្រុក ព្រះរាជអាជ្ញា ជាអ្នកស្នើឲ្យមានការស៊ើបអង្កេត ។ តាមរយៈ "ដីកាបញ្ជូនសំណុំរឿងឲ្យស៊ើបសួរ" ព្រះរាជអាជ្ញាបានផ្តល់យុត្តាធិការបង្គាប់ដល់ចៅក្រមស៊ើបអង្កេតដើម្បីបញ្ចប់ការស៊ើបអង្កេត ។ ទាក់ទងនឹងឆន្ទានុសិទ្ធិក្នុងការស៊ើបអង្កេត មាត្រា១២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌនោះ ចែងថា ការស៊ើបអង្កេតគឺជា "ការបង្គាប់" សម្រាប់បទឧក្រិដ្ឋ និងជា "ជម្រើស" សម្រាប់បទល្មើសមជ្ឈិម ។ ឆន្ទានុសិទ្ធិដែលបានកំណត់នេះ ធ្វើឡើងនៅពេលដែលចៅក្រមស៊ើបអង្កេតទទួលបាន "ដីកាបញ្ជូនសំណុំរឿងឲ្យស៊ើបសួរ" ពីព្រះរាជអាជ្ញា និងនៅពេលដែលការស៊ើបអង្កេតបានចាប់ផ្តើម ។ មាត្រា១២៧ នៃក្រមនោះ ចែងថា ចៅក្រមស៊ើបអង្កេត "ត្រូវធ្វើការស៊ើបអង្កេតទាំងអស់ ដែលមានប្រយោជន៍ក្នុងការស្វែងរកការពិត" ហើយជាងនេះទៅទៀត "ត្រូវមានកាតព្វកិច្ចក្នុងការស៊ើបអង្កេតសម្រាប់ការចោទប្រកាន់ និងលើកលែងការចោទប្រកាន់" ។ កាតព្វកិច្ចតាមការបង្គាប់ទាំងនេះឆ្លុះបញ្ចាំងអំពីកាតព្វកិច្ច ដែលមាននៅក្នុងវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលចែងថា សហព្រះរាជ

អាជ្ញា «ត្រូវ» បើកការស៊ើបអង្កេត នៅពេលដែលមានហេតុផលក្នុងការជឿជាក់ថា ឧក្រិដ្ឋកម្មមួយត្រូវបានប្រព្រឹត្តឡើង ហើយក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ហើយថា ការស៊ើបអង្កេត «គឺត្រូវធ្វើឡើងចំពោះឧក្រិដ្ឋកម្មដែលស្ថិតនៅក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា» ។

ដើម្បីបិទបញ្ចប់ការស៊ើបអង្កេតលើបទល្មើសព្រហ្មទណ្ឌក្នុងស្រុក ចៅក្រមស៊ើបអង្កេតត្រូវតែចេញ «ដីកាដំណោះស្រាយ» ស្រដៀងគ្នាទៅនឹង «ដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះ» នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ដីកាដំណោះស្រាយក្នុងស្រុកអាចជាដីកាបញ្ជូនទៅជំនុំជម្រះ ឬដីកាលើកលែងការចោទប្រកាន់ ហើយការច្រានចោលសំណុំរឿងស្ថិតនៅក្នុងដីកា «លើកលែងការចោទប្រកាន់» ។ មាត្រា២៤៧នៃក្រមនីតិវិធីព្រហ្មទណ្ឌប្រទេសកម្ពុជាចែងថា «ចៅក្រមស៊ើបអង្កេតត្រូវតែចេញដីកាលើកលែងការចោទប្រកាន់ក្នុងលក្ខណដូចខាងក្រោម ៖ ១) អំពើប្រព្រឹត្តមិនមែនជាបទឧក្រិដ្ឋ បទមជ្ឈិម ឬ បទលហុ ។ ២) ជនដែលប្រព្រឹត្តអំពើនោះ នៅតែគេមិនស្គាល់អត្តសញ្ញាណ ។ ៣) គ្មានភ័ស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនត្រូវចោទ ។

មិនមានការបញ្ជាក់អំពីសម្ពាធនៃឆន្ទានុសិទ្ធិផ្សេង ដែលចៅក្រមស៊ើបអង្កេតអាចចេញដីកាលើកលែងការចោទប្រកាន់ និងអាចប្តឹងឧទ្ធរណ៍ដល់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ នីតិវិធីនៃដីកាដំណោះស្រាយ ដែលត្រូវបានប្រើប្រាស់នៅក្នុងតុលាការព្រហ្មទណ្ឌប្រទេសកម្ពុជា អាចផ្ទុយទៅនឹងវិធាន៦៧(៣) នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលចែងថា ចៅក្រមស៊ើបអង្កេតត្រូវតែចេញដីកាលើកលែងការចោទប្រកាន់នៅក្នុងលក្ខណៈដូចខាងក្រោម ៖ ១) អំពើដែលចោទប្រកាន់មិនរាប់បញ្ចូលជាបទឧក្រិដ្ឋដែលស្ថិតនៅក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ ។ ២) ជនប្រព្រឹត្តបទឧក្រិដ្ឋនោះមិនទាន់កំណត់អត្តសញ្ញាណនៅឡើយ ។ ៣) ពុំមានភ័ស្តុតាងគ្រប់គ្រាន់ ដើម្បីផ្តន្ទាទោសជនត្រូវចោទប្រកាន់ ។

នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មិនមានច្បាប់ណាមួយដែលត្រូវអនុវត្តដោយផ្ទាល់នៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវបានលើកឡើងថា សម្ពាធនៃឆន្ទានុសិទ្ធិអាចមានអត្ថិភាពនៅពេលសហចៅក្រមស៊ើបអង្កេតអាចសម្រេចចិត្តចេញដីកាលើកលែងការចោទប្រកាន់ ។

មាត្រា២៦១នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា បានចែងថា នៅពេលដែលទទួលបានបណ្តឹងទាក់ទងនឹងការស៊ើបអង្កេត សភាស៊ើបសួរ «ត្រូវពិនិត្យមើលពីនិយ័តភាពនៃនីតិវិធី និងការប្រព្រឹត្តទៅដ៏ល្អនៃនិតិវិធីនេះ» ហើយ (ប្រសិនបើ) ពិនិត្យឃើញថា មានមូលហេតុនៃមោឃភាព សភាស៊ើបសួរអាចចាត់ទុកជាមោឃៈដោយឯកឯងនូវនីតិវិធីទាំងមូល ឬផ្នែកណាមួយ ។ សភាស៊ើបសួរ អាចបង្គាប់ឲ្យមានការស៊ើបអង្កេតបន្ថែម ប្រសិនបើខ្លួនចាត់ទុកថា ជាទង្វើដ៏មានប្រយោជន៍ និងអាចតែងតាំងចៅក្រមមួយក្នុងចំណោមចៅក្រមរបស់ខ្លួន ដើម្បីបន្តតំណែងរបស់ចៅក្រមស៊ើបអង្កេត ដើម្បីធ្វើការងារបែបនេះ ។ ប្រសិនបើសភាស៊ើបសួរ ធ្វើការស៊ើបអង្កេត ចៅក្រមដែលតែងតាំងដោយសភាស៊ើបសួរនឹងត្រូវធ្វើការស៊ើបអង្កេតបន្ថែម ។ សភាស៊ើបសួរនោះ ធ្វើសេចក្តីសន្និដ្ឋានលើការស៊ើបអង្កេត ដូចគ្នានឹងចៅក្រមស៊ើបអង្កេតតាមរយៈការចេញដីកាដំណោះស្រាយទាំងការនាំជនសង្ស័យទៅជំនុំជម្រះ ឬចេញដីកាលើកលែងទោស ។

ដូច្នេះហើយ ច្បាប់ប្រទេសកម្ពុជា ផ្តល់នូវសេចក្តីណែនាំមិនគ្រប់គ្រាន់ក្នុងការបង្ហាញនូវដែនសមត្ថកិច្ចរបស់សហចៅក្រមស៊ើបអង្កេត ក្នុងការវាយតម្លៃថា តើជនសង្ស័យណា ត្រូវបានចាត់ទុកថាជា «មេដឹកនាំជាន់ខ្ពស់» និង «អ្នកទទួលខុសត្រូវខ្ពស់បំផុត» ចំពោះឧក្រិដ្ឋកម្មក្នុងរបបកម្ពុជាប្រជាធិបតេយ្យនៅក្នុងប្រទេសកម្ពុជា ។ សម្រាប់ផ្នែកជាច្រើន ច្បាប់នីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្លុះបញ្ចាំងពីបញ្ញត្តិនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលមាននៅក្នុងច្បាប់ និងវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលចែងថាការស៊ើបអង្កេតត្រូវតែធ្វើឡើងចំពោះឧក្រិដ្ឋកម្ម ដែលស្ថិតក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ហើយឧក្រិដ្ឋកម្មទាំងនោះត្រូវតែមានលក្ខណៈធ្ងន់ធ្ងរ ។ ការច្រានចោលការចោទប្រកាន់ អាចធ្វើឡើងបានតែក្នុងករណីដែលភ័ស្តុតាងប្រឆាំងនឹងជនសង្ស័យមានមិនគ្រប់គ្រាន់សម្រាប់ការចោទប្រកាន់

តែប៉ុណ្ណោះ ។ ដូច្នេះហើយ ប្រសិនបើការវិភាគលើច្បាប់នីតិវិធីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងច្បាប់របស់ប្រទេសកម្ពុជា ដែលគ្រប់គ្រងលើសមត្ថកិច្ចនៃការស៊ើបអង្កេត លើកឡើងថា ឆន្ទានុសិទ្ធិដើម្បីប្រានចោលការចោទប្រកាន់ប្រឆាំងទៅនឹងជនដែលត្រូវបានចោទប្រកាន់សម្រាប់ឧក្រិដ្ឋកម្មធ្ងន់ធ្ងរ គួរតែត្រូវបានបកស្រាយក្នុងន័យចង្អៀតបំផុត ដោយសារអំណាចដែលបុគ្គលនោះមាន គឺពុំមានចែងជាក់លាក់នៅក្នុងច្បាប់ទាំងពីរនេះទេ ។

## ឃ) តម្រូវការសម្រាប់ទិសដៅច្បាប់អន្តរជាតិ

ជារួម នៅពុំមានការឯកភាពគ្នា នៅក្នុងចំណោមអ្នកដែលធ្វើសេចក្តីព្រៀងកិច្ចព្រមព្រៀង ទាក់ទងនឹងអត្ថន័យនៃពាក្យ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" នៅក្នុងកិច្ចព្រមព្រៀង និងច្បាប់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានៅឡើយទេ ។ ស្រដៀងគ្នានេះដែរ មិនមានច្បាប់ណាដែលអនុវត្តផ្ទាល់នៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬច្បាប់ព្រហ្មទណ្ឌប្រទេសកម្ពុជាលើកឡើងពីអំណាចក្នុងការជំនុំជម្រះ ឬស៊ើបអង្កេតតាមសមត្ថកិច្ចផ្អែកលើការវាយតម្លៃលើភាពជាប់ទាក់ទងនៃការទទួលខុសត្រូវក្នុងចំណោមជនសង្ស័យពីបទព្រហ្មទណ្ឌ ឬលើកឡើងអំពីអត្ថន័យនៃពាក្យ "អ្នកទទួលខុសត្រូវខ្ពស់បំផុតទេ" ។ ដូច្នេះហើយ លទ្ធផលនេះមិនមានភាពគួរឲ្យភ្ញាក់ផ្អើលឡើយ ដោយសារយុត្តាធិការបុគ្គលដែលត្រូវបានកំណត់សម្រាប់ឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ផ្អែកលើការវាយតម្លៃអំពីភាពជាប់ពាក់ព័ន្ធនៃការទទួលខុសត្រូវបុគ្គល គឺជាលក្ខណៈដោយឡែក និងខុសប្លែកគ្នាពីច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ។

ជាងនេះទៅទៀត ការផ្អែកលើ "គោលដៅ និងគោលបំណង" នៃកិច្ចព្រមព្រៀងដើម្បីស្វែងយល់អំពីអត្ថន័យនៃពាក្យ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ដូចដែលបានចែងក្នុងសន្ធិសញ្ញាក្រុងវីយែនដែលបណ្តាលឲ្យមានបញ្ហាជាច្រើន ដោយសារគោលដៅ និងគោលបំណងនៃកិច្ចព្រមព្រៀងនោះ គឺដើម្បីនាំយក "មេដឹកជាន់ខ្ពស់" និង "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ដទៃទៀតមកកាត់ទោសសម្រាប់ឧក្រិដ្ឋកម្មក្នុងរបបខ្មែរក្រហម ។ នៅពុំទាន់មានការពន្យល់ជាក់លាក់ណាមួយចំពោះពាក្យ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" នៅក្នុងនីតិវិធីព្រហ្មទណ្ឌនៅឡើយទេ ហើយដោយសារច្បាប់កម្ពុជា បានជួយតិចតួចក្នុងការកំណត់និយមន័យលើពាក្យនេះ ។ ច្បាប់កិច្ចព្រមព្រៀង និងច្បាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាចែងថា ច្បាប់អន្តរជាតិគួរតែបានប្រែជាជំនួយដល់ការកំណត់និយមន័យដ៏សំខាន់នេះ ។

ដូចដែលបានបង្ហាញនៅផ្នែកខាងក្រោម ខណៈពេលដែលច្បាប់អន្តរជាតិរារាំងដោយចេតនា ចំពោះការកំណត់អត្ថន័យជាក់លាក់ជាសកល ស្តីពីកម្រិតនៃការទទួលខុសត្រូវ យុត្តិសាស្ត្រនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិលើកឡើងអំពីប្រភេទបុគ្គល ដែលមានលក្ខណៈសម្បត្តិជាអ្នកទទួលខុសត្រូវខ្ពស់បំផុត ហើយយុត្តិសាស្ត្ររបស់ច្បាប់ព្រហ្មទណ្ឌអន្តរជាតិនេះ ចែងថា សេចក្តីសម្រេចត្រឹមត្រូវណាមួយទាក់ទងនឹងការទទួលខុសត្រូវរបស់បុគ្គល ត្រូវតែផ្អែកលើការវាយតម្លៃអំពីស្ថានទម្ងន់នៃឧក្រិដ្ឋកម្មដែលត្រូវចោទប្រកាន់ និងកម្រិតនៃការទទួលខុសត្រូវរបស់ជនសង្ស័យ ។ ដំណើរការវាយតម្លៃនេះ ត្រូវតែយកជនសង្ស័យ និងជនជាប់ចោទដទៃផ្សេងទៀត ដែលត្រូវបានជំនុំជម្រះដោយរដ្ឋអំណាចតែមួយ ដែលជាកម្រិតប្រៀបធៀប ដើម្បីចៀសវាងនូវលក្ខណៈមិនស្រប និងជម្លោះ ។

## ង) ទស្សនៈ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" យោងតាមច្បាប់ព្រហ្មទណ្ឌអន្តរជាតិ

នៅពេលដែលគេកំណត់ថា វាជាការចាំបាច់ដែលត្រូវសម្លឹងមើលច្បាប់អន្តរជាតិសម្រាប់ជាមធ្យោបាយ ក្នុងការបកស្រាយពាក្យ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" នៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បន្ទាប់មកគេគួរតែពិចារណាអំពីការស្វែងរកគោលការណ៍ច្បាប់ដែលមានប្រយោជន៍ ។ ដោយសារការកំណត់លើយុត្តាធិការផ្អែកលើការវាយតម្លៃលើភាពជាប់ពាក់ព័ន្ធនៃការទទួលខុសត្រូវមានលក្ខណៈដូចគ្នាទាំងស្រុងទៅនឹងច្បាប់ព្រហ្មទណ្ឌអន្តរជាតិដូច្នេះយុត្តិសាស្ត្របែបនេះទំនងជាផ្នែកដ៏ប្រសើរសម្រាប់ចាប់ផ្តើម ។ ដូច្នេះហើយ យុត្តិសាស្ត្ររឹងមាំរបស់តុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និងតុលាការព្រហ្មទណ្ឌអន្តរជាតិ ស្តីពីបញ្ហានៃការទទួលខុសត្រូវយុត្តាធិការបុគ្គល និងការជ្រើសរើសជនសង្ស័យ រួមផ្សំគ្នាដើម្បីផ្តល់គោលការណ៍ណែនាំមួយចំនួនស្តីពីបញ្ហាគន្លឹះនៃដំណើរការ និងការពិចារណាដ៏ត្រឹមត្រូវក្នុងការវាយ

តម្លៃលើភាពជាប់ទាក់ទងនឹងការទទួលខុសត្រូវ ។ ការអនុវត្តនៅតុលាការទាំងនោះបង្ហាញយ៉ាងច្បាស់ថា ការពិចារណាពីសំខាន់ក្នុងការកំណត់អំពីពិរុទ្ធភាព គឺជាស្ថានទម្ងន់នៃបទឧក្រិដ្ឋកម្មដែលត្រូវចោទប្រកាន់ និងកម្រិតនៃការទទួលខុសត្រូវរបស់បុគ្គលដែលជាប់ពាក់ព័ន្ធ ។ ជាងនេះទៅទៀត ក្រោមយុត្តិសាស្ត្ររបស់ច្បាប់ឧក្រិដ្ឋកម្មអន្តរជាតិដែលមានស្រាប់ ស្ថានទម្ងន់ និងការទទួលខុសត្រូវ គឺត្រូវបានពិចារណាក្នុងបរិបទនៃការបកស្រាយ អំពីប្រវត្តិនៃបញ្ហា និងត្រូវប្រៀបធៀបជាមួយនឹងសំណុំរឿងដទៃទៀត ទោះបីជាមិនស្ថិតក្នុងលក្ខណៈផ្លូវការក៏ដោយ ។

**តុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន ៖ "អ្នកទទួលខុសត្រូវខ្ពស់បំផុត"**

ក្នុងឆ្នាំ២០០០ ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិបានស្នើសុំឲ្យមានការបង្កើតតុលាការ ក្រោមយុត្តាធិការបុគ្គលស្តីពីអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតសម្រាប់ការប្រព្រឹត្តឧក្រិដ្ឋកម្មអន្តរជាតិក្នុងប្រទេសសេរ៉ាឡេអូន ។ លទ្ធផលនោះគឺថាតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន ដែលជាតុលាការចម្រុះត្រូវបានបង្កើតដោយអនុលោមតាមសន្ធិសញ្ញារវាងអង្គការសហប្រជាជាតិ និងរដ្ឋាភិបាលប្រទេសសេរ៉ាឡេអូន ជាមួយនឹងអាណត្តិ ដើម្បីចោទប្រកាន់បុគ្គលដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះការរំលោភបំពានធ្ងន់ធ្ងរ ដែលបានប្រព្រឹត្តក្នុងទឹកដីប្រទេសសេរ៉ាឡេអូនចាប់តាំងពីថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៦ តាមច្បាប់មនុស្សធម៌អន្តរជាតិ និងច្បាប់ប្រទេសសេរ៉ាឡេអូន ។ មាត្រា១នៃលក្ខន្តិកៈរបស់តុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូនផ្តល់អំណាចក្នុងការចោទប្រកាន់បុគ្គល ដែលទទួលខុសត្រូវខ្ពស់បំផុតសម្រាប់ការរំលោភបំពានធ្ងន់ធ្ងរក្រោមច្បាប់មនុស្សធម៌អន្តរជាតិ និងច្បាប់ប្រទេសសេរ៉ាឡេអូន ។

ពាក្យ "ទទួលខុសត្រូវខ្ពស់បំផុត" គឺជាប្រធានបទនៃការពិភាក្សាដេញដោលជាច្រើន មុនពេលបង្កើតតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន ។ អគ្គលេខាធិការអង្គការសហប្រជាជាតិ កាលគ្រានោះ លោក កូហ្វី អាណាន់ បានថ្លែងថា ពាក្យ "ទទួលខុសត្រូវខ្ពស់បំផុត" គួរតែត្រូវបានយល់ដឹងថា ជាសូចនាករណ៍អំពីការកំណត់ចំនួនជនជាប់ចោទ តាមរយៈដីកាបន្ទាប់បញ្ជា ស្ថានទម្ងន់ និងកម្រិតនៃឧក្រិដ្ឋកម្ម ហើយលោកបានស្នើថា ពាក្យ "ទទួលខុសត្រូវខ្ពស់បំផុត" គួរតែត្រូវបានប្រើប្រាស់ និងអង្កេត ៖

*ទន្ទឹមពេលដែលអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតរួមមាន មេដឹកនាំនយោបាយ មេដឹកនាំយោធា អ្នកដទៃដែលមានអំណាចបញ្ជា អាចត្រូវបានចាត់ទុកថាជា "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ដោយវិនិច្ឆ័យតាមរយៈស្ថានទម្ងន់នៃឧក្រិដ្ឋកម្ម ឬកម្រិតនៃឧក្រិដ្ឋកម្មនោះ ។ ដូច្នេះហើយ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" បង្ហាញអំពីទាំងតួនាទីជាអ្នកដឹកនាំ និងតួនាទីកាន់អំណាចរបស់ជនជាប់ចោទ និងស្ថានទម្ងន់ ឬកម្រិតនៃឧក្រិដ្ឋកម្ម ។*

ចុងក្រោយ តុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូនបានប្រើពាក្យ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" នៅក្នុងលក្ខន្តិកៈរបស់ខ្លួន ហើយពាក្យនេះត្រូវបានចែងដើម្បីប្រើការ ជាការចង្អុលបង្ហាញសម្រាប់ឆន្ទានុសិទ្ធិក្នុងការចោទប្រកាន់ ។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍ចែងថា លក្ខន្តិកៈរបស់តុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន ដែលបានឲ្យព្រះរាជអាជ្ញាទទួលខុសត្រូវសម្រាប់ការស៊ើបអង្កេត និងការចោទប្រកាន់បុគ្គលទទួលខុសត្រូវខ្ពស់បំផុត បានកំណត់អំពីបុគ្គលណាដែលសក្តិសមចោទប្រកាន់ ដែលនេះជាបញ្ហានៃឆន្ទានុសិទ្ធិក្នុងការចោទប្រកាន់ ហើយមិនសក្តិសមសម្រាប់ការត្រួតពិនិត្យតាមផ្លូវច្បាប់នោះឡើយ ។ អង្គជំនុំជម្រះបានសង្កត់ធ្ងន់ថា ភាពចាំបាច់របស់ព្រះរាជអាជ្ញា ស្តីពីធ្វើការងារដោយឯករាជ្យ និងមិនស្វែងរក ឬទទួលការណែនាំពីពីរដ្ឋាភិបាល ឬពីប្រភពដទៃ ហើយបានសន្និដ្ឋានលើសេចក្តីសម្រេចក្នុងរឿងក្តី ព្រះរាជអាជ្ញា តទល់នឹង ព្រីម៉ា ដែលមាន ៖

*វាជារឿងមិនអាចយល់បាន បន្ទាប់ពីការជំនុំជម្រះរយៈពេលវែង និងចំណាយថវិកាអស់ច្រើន អង្គជំនុំជម្រះតុលាការកំពូល បានសន្និដ្ឋានថា ទោះបីជាឧក្រិដ្ឋកម្មធ្ងន់ធ្ងរប្រឆាំងទៅនឹងជនជាប់ចោទ មិនមានលក្ខណៈសមហេតុផល ។ ការចោទប្រកាន់នោះគួរតែត្រូវបានធ្វើឡើង ដោយសម្អាងថា ជនជាប់ចោទមិនមែនជាមនុស្សម្នាក់ក្នុងចំណោមមនុស្ស*

ដែលទទួលខុសត្រូវខ្ពស់បំផុត ។

ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះបានកត់សម្គាល់ថា "សុចរិតភាព" ត្រូវអនុវត្តចំពោះការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ព្រះរាជអាជ្ញា ។

ព្រះរាជអាជ្ញារបស់តុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន បានចោទប្រកាន់ជនសង្ស័យចំនួន១២នាក់ និងបានកាត់ទោសមនុស្ស៩នាក់ ហើយជនជាប់ចោទបីនាក់ បានស្លាប់ មុនពេលចេញសាលក្រម ។ ជនជាប់ចោទ១២នាក់ទទួលតួនាទីផ្សេងៗគ្នាក្នុងចំណោមភាគីដ៏សំខាន់ទាំង៣ក្នុងជម្លោះប្រទេសសេរ៉ាឡេអូន ដូចជា រណសិរ្សបង្រួបបង្រួមបដិវត្តន៍ កងកម្លាំងការពារជនស៊ីវិល និងក្រុមប្រឹក្សាបដិវត្តន៍កងកម្លាំង ដែលតុលាការនេះត្រូវបានបង្កើតដើម្បីវិនិច្ឆ័យ ។ ជនជាប់ចោទទាំងនោះ រួមមាន ចាប់ពីមេបញ្ជាការរហូតដល់អ្នកកាន់តួនាទីសំខាន់ដទៃ ប៉ុន្តែអ្នកទាំងនោះស្ថិតក្រោមការបញ្ជាពីថ្នាក់លើ ។ ឧទាហរណ៍ រឿងក្តីរវាងព្រះរាជអាជ្ញាតទល់នឹងស៊ីសាយ អង្គជំនុំជម្រះតុលាការកំពូលរបស់តុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន បានរកឃើញថា ជនជាប់ចោទអូហ្គូសស៊ីន បៅ មិនមែនជាសមាជិករបស់ក្រុមប្រឹក្សាបដិវត្តន៍កងកម្លាំង ឬជាការក្រុមប្រឹក្សាកំពូលរបស់រណសិរ្សបង្រួបបង្រួមបដិវត្តន៍ ដែលទទួលខុសត្រូវលើការសម្រេចចិត្តនោះទេ ហើយគាត់ស្ថិតនៅតំបន់ដាច់ដោយឡែក អំឡុងពេលដែលក្រុមបដិវត្តន៍កងកម្លាំង និងរណសិរ្សបង្រួបបង្រួមបដិវត្តន៍កាន់អំណាច ។ ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះតុលាការកំពូល បានរកឃើញថា បៅ គឺជាគ្រូបង្រៀនពីមនោគមវិជ្ជា ហើយមនោគមវិជ្ជាបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងចលនារបស់រណសិរ្សបង្រួបបង្រួមបដិវត្តន៍ និងស្ថិតក្រោមទឹកដីដែលគ្រប់គ្រងដោយរណសិរ្សបង្រួបបង្រួមបដិវត្តន៍ ។ កងកម្លាំងរបស់ បៅ ទទួលខុសត្រូវចំពោះការពង្រឹងការដាក់ទណ្ឌកម្មច្បាប់ និងបទបញ្ជា ។ នៅក្នុងរឿងក្តីរវាងព្រះរាជអាជ្ញាតទល់នឹង ហ្វូហ្វាណា និង ខុនដេវ៉ា ជនជាប់ចោទ អាល់លូ ខុនដេវ៉ា គឺជាបុគ្គលជាន់ខ្ពស់របស់កងកម្លាំងការពារជនស៊ីវិល ដែលទទួលខុសត្រូវការប្រកាសជ្រើសរើសសមាជិកថ្មី ហើយគាត់តែងតែចូលរួមពិធីចាក់ថ្នាំការពារដល់សកម្មប្រយុទ្ធពីការរងរបួសដោយគ្រាប់កាំភ្លើងមុនពេលទៅសមរភូមិ ។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានគាំទ្រចំពោះការចោទប្រកាន់ ខុនដេវ៉ា ដោយរកឃើញថា ខុនដេវ៉ា "មានអំណាចក្នុងការចេញបញ្ជាផ្ទាល់មាត់ និងជាលាយលក្ខណ៍អក្សរ ។ គាត់អាចបញ្ជាឲ្យមានការស៊ើបអង្កេតចំពោះការប្រព្រឹត្តខុស និងផ្ញើការជំនុំជម្រះនៅតុលាការ ហើយគាត់មានសមត្ថកិច្ចក្នុងការដាក់បញ្ជានោះ" ។ មិនមានការដាក់កំហិតរបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ដែលថា ព្រះរាជអាជ្ញារបស់តុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូនមិនបានធ្វើការងារឲ្យបានល្អប្រសើរក្រោមសុចរិតភាពក្នុងការកំណត់ថា បៅ និង ខុនដេវ៉ា ត្រូវបានចាត់ទុកថាជាអ្នកទទួលខុសត្រូវខ្ពស់បំផុតសម្រាប់ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងប្រទេសសេរ៉ាឡេអូន ។ **(នៅមានត)**

**រ៉េន ឌុលជីហ្វាលក្វ**

# ដំណឹងស្វែងរកបងប្អូន

ខ្ញុំបាទឈ្មោះ ញ៉ែន ស៊ី ស្នាក់នៅផ្ទះលេខ៤៧៦G សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ក្រុងភ្នំពេញ ប្រកាសស្វែងរកឈ្មោះ អៀរ ទៀងហាវ ភេទប្រុស កើតឆ្នាំ១៩៤៨ នៅភូមិក្រពាំងក្រឡឹង ឃុំតាំងស្យា ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ។ ពីមុន ទៀងហាវ គឺជាសាស្ត្រាចារ្យរូបវិទ្យា-គីមី នៅវិទ្យាល័យអង្គរ ទីរួមខេត្តសៀមរាប ។ នៅខែវិច្ឆិកា ឆ្នាំ១៩៧៥ ទៀងហាវ និងភរិយាឈ្មោះ គួច សាយទៀង ត្រូវខ្មែរក្រហមជម្លៀសទៅនៅភូមិកន្ទួត ឃុំណាំតៅ ស្រុកភ្នំស្រុក ខេត្តបាត់ដំបង ។

នៅខែធ្នូ ឆ្នាំ១៩៧៥ ខ្មែរក្រហមបានប្រមូលបញ្ញវន្តនៅតាមភូមិឃុំ ក្នុងស្រុកភ្នំស្រុក ហើយបានបញ្ជូន ទៀងហាវ និងភរិយាទៅនៅភូមិប្រាសាទ ឃុំប្រាសាទ ស្រុកព្រះនេត្រព្រះ ខេត្តបាត់ដំបង (បច្ចុប្បន្នខេត្តបន្ទាយមានជ័យ) ។ ទៀងហាវ និងភរិយាបានបាត់ខ្លួននៅឆ្នាំ១៩៧៦ ។

ប្រសិនបើបងប្អូនណាបានឮឬស្គាល់ឈ្មោះដូចខាងលើសូមផ្តល់ដំណឹងមកខ្ញុំបាទតាមរយៈអាសយដ្ឋានក្រសួងរៀបចំដែនដីនរគនីយកម្ម និងសំណង់ ទូរស័ព្ទលេខ ០១២ ៩៥៨ ៥៤៦ ឬ អ៊ីមែល nhansy04@yahoo.com ។ **សូមអរគុណ!**

# ការចងចាំនៃការជម្លៀសដោយបង្ខំ

នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៧៦ ប៉ុល ពត បានប្រកាសថា មាន "ខ្មាំងស៊ីរូងបង្កប់ផ្ទៃក្នុងជួរបក្ស" ដូច្នេះត្រូវតែមានការ "តាមដាន" និងដាក់កម្រិតដល់ការធ្វើបន្សុទ្ធកម្ម ដើម្បីបដិវត្តន៍ខ្មែរក្រហម ។ ខ្មែរក្រហមព្រមានថា "គ្មានមន្ទីរពេទ្យណាអាចព្យាបាលជំងឺនេះបានទេ" ។ ដូច្នេះវិធីដ៏ល្អប្រសើរសម្រាប់អង្គការមានតែ "កម្ចាត់" ប្រភេទជននោះចោល ។ តាមពិតខ្មែរក្រហមជារឿយៗតែងតែប្រើពាក្យពេចន៍ បន្ទូរបន្ថយទម្ងន់នៃទង្វើរបស់ខ្លួនដោយប្រៀបធៀបទៅនឹងអ្វីដែលខ្លួនបានសន្មតថាជា ជំងឺសតិអារម្មណ៍ ។ ពាក្យស្លោកមួយដែលខ្មែរក្រហមបានប្រើ "ត្រូវតែកម្ចាត់ចោលឲ្យអស់នូវខ្មាំងរូបី និងខ្មាំងអរូបី ខ្មាំងសតិអារម្មណ៍ ដូចដែលខ្មែរក្រហមបានព្យាយាមបង្អែងដានជនប្រឆាំងនឹងបដិវត្តន៍របស់ខ្លួន តាមរយៈការស្វែងរកភាគវិនិច្ឆ័យលើ "ការចងចាំរបស់ខ្មាំង" ដែលជារោគរ៉ាំរ៉ៃ ។

នៅពេលដែលខ្មែរក្រហមទទួលបានជោគជ័យ និងដណ្តើមបានទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ភ្លាមៗនោះខ្មែរក្រហមចាប់ផ្តើមបង្ខំឲ្យប្រជាជន និងជនភៀសខ្លួនដែលរស់នៅក្នុងទីក្រុងចាកចេញពីទីក្រុងទៅនៅតាមទីជនបទ ។ ខ្មែរក្រហមបានប្រកាសថា "បងប្អូនប្រុសស្រីទាំងឡាយអង្គការស្នើសុំ ឲ្យបងប្អូនចាកចេញពីទីក្រុងភ្នំពេញក្នុងរយៈពេលបីថ្ងៃ ព្រោះអង្គការត្រូវការបោសសម្អាតខ្មាំងសម្ងំលាក់ខ្លួនចេញឲ្យអស់ ។ សហរដ្ឋអាមេរិក



ប្រជាជនបានចាកចេញពីទីក្រុង ដោយសារការជម្លៀសរបស់ខ្មែរក្រហម នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥

មិនអាចភ្លេចនូវភាពបរាជ័យរបស់ខ្លួនបាននោះទេ ការចាកចេញនេះ ក៏ដើម្បីជៀសវាងការទម្លាក់គ្រាប់បែក បេ-៥២ របស់សហរដ្ឋអាមេរិកផងដែរ» ។ ខ្មែរក្រហមបានអះអាងថា ការចាកចេញនេះមានរយៈពេលខ្លី ហើយប្រជាជននឹងត្រឡប់ទៅលំនៅស្ថានរបស់ខ្លួនវិញក្នុងពេលឆាប់ៗ ដូច្នេះប្រជាជនមិនចាំបាច់នាំយករបស់របរអ្វីច្រើនទៅជាមួយនោះទេ ។ ផ្ទុយទៅវិញការនាំយករបស់របរមានតម្លៃនឹងត្រូវដកហូត ។ ទាំងក្នុងពេល និងក្រោយពេលជម្លៀស ខ្មែរក្រហមស្នើសុំឲ្យប្រជាជនបោះបង់ចោលអ្វីដែលជាភ័ស្តុតាងសម្គាល់អត្តសញ្ញាណរបស់ខ្លួន ដូចជា «រូបថតឬវត្ថុនានាដែលមានជាប់នៅនឹងខ្លួនអាចត្រូវបានចោទថា ជាជំងឺដែលសល់ពីការចងចាំ» ។ នេះជាការបកស្រាយរបស់អ្នករស់រានមានជីវិតម្នាក់ឈ្មោះ ម៉ម ប៊ុតធីតា ។ ប៊ុតធីតា បានពន្យល់ទៀតថា «សំបុត្រដែលផ្ញើមកពីឪពុករបស់ខ្ញុំត្រូវបានចាត់ទុកថា បានបង្ហាញពីភាពមិនប្រក្រតីនាពេលអតីតកាល » ។

ការផ្លាស់ប្តូរតួនាទី និងកាតព្វកិច្ចរបស់ប្រជាជនជិតពីរលាននាក់ ដែលត្រូវបានជម្លៀសចេញពីទីក្រុងភ្នំពេញ ដោយយកគំរូតាមលទ្ធិម៉ៅនិយម ត្រូវបានចាត់ទុកជាសម័យដ៏មហារុងរឿង មហាលោតផ្លោះ ។ ប្រជាជនត្រូវធ្វើដំណើរយ៉ាងឆ្ងាយសន្ធឹម ដោយថ្មើរជើង រថភ្លើង រទេះគោ រថយន្តដឹកទំនិញ ត្រាក់ទ័រ និងទូកនេសាទនានា ដោយមិនគិតពីអាយុ ឬស្ថានភាពសុខភាពនោះទេ ។ សូម្បីតែនៅតាមមន្ទីរពេទ្យនានា ក៏ពុំមានអ្នកជំងឺស្នាក់នៅដែរ ។ ភ័ស្តុតាងជាច្រើនបានបង្ហាញថា ការដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជា បានចូលរួមដោយផ្ទាល់ក្នុងការសម្រេចចិត្តជម្លៀសប្រជាជនដោយបង្ខំ ។ ទន្ទឹមនឹងគ្នានេះដែរ ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញទៅកាន់ភូមិភាគផ្សេងៗ ត្រូវបានតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមលើកយកមកជំនុំជម្រះក្នុងសំណុំរឿង០០២ ផ្នែកទីមួយ ។

ជាក់ស្តែង ខ្មែរក្រហមជម្លៀសប្រជាជនដោយបង្ខំ ដោយពុំមានផ្តល់ជំនួយ ឬមធ្យោបាយអ្វីទាំងអស់ដែលធ្វើឲ្យអ្នកដែលត្រូវបានជម្លៀសទទួលរងនូវភាពអមនុស្សធម៌ជាច្រើន រួមមានបែកបាក់ក្រុមគ្រួសារ បាត់ខ្លួន ជំងឺ ស្រេកឃ្លាន វាយដំ អំពើហិង្សាផ្លូវភេទ និងសម្លាប់ ។ ការកំណត់ក្រុមមនុស្ស និងការធ្វើទុក្ខបុកម្នេញក្រុមមនុស្សនោះកើតឡើងជាបន្តបន្ទាប់នៅក្នុងអំឡុងពេលជម្លៀសដោយបង្ខំ ។ ខ្មែរក្រហមបាន បែងចែកប្រជាជនជាពីរក្រុមដាច់ដោយឡែកពីគ្នា ប្រជាជនថ្មី និងប្រជាជនមូលដ្ឋាន ។ ប្រជាជនថ្មី ឬ «ប្រជាជន ១៧មេសា» ជាអតីតប្រជាជនមកពីទីក្រុង ។ ចំណែកឯប្រជាជានមូលដ្ឋានជាប្រជាជនដែលរស់នៅជនបទស្រាប់ នៅតាមភូមិឃុំក្នុងអំឡុងពេលសង្គ្រាមស៊ីវិល ។ អ្នករាជការនៅក្នុងរបបសាធារណរដ្ឋខ្មែរ អ្នករស់នៅទីក្រុង ជនជាតិចាម ជនជាតិភាគតិចដូចជា វៀតណាម និង ចិន ព្រមទាំងព្រះសង្ឃ និងដូនជី ក៏ជាក្រុមមនុស្សដែលត្រូវបែងចែកសម្រាប់យកទៅអប់រំដែរ ។ គួរបញ្ជាក់ដែរថា អ្នកដែលរស់រានជីវិតចេញពីរបបខ្មែរក្រហមទទួលរងនូវការប៉ះទង្គិចផ្លូវចិត្ត និងផ្លូវកាយរហូតដល់សព្វថ្ងៃ ។

បើយោងតាមវិធានផ្ទៃក្នុង មាត្រាទី២៣ របស់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់មានសិទ្ធិប្តឹងទាមទារ និងទទួលបានសំណងសមូហភាព និងផ្លូវចិត្តតែប៉ុណ្ណោះ ។ នៅក្នុងសំណុំរឿង០០២ផ្នែកទីមួយ ភាគីដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសុំសំណងសមូហភាព និងផ្លូវចិត្តចំនួន១៣ ។ ការចូលរួមរបស់ជនរងគ្រោះក្នុងដំណើរការស្វែងរកយុត្តិធម៌មានសារសំខាន់ណាស់ ដែលមិនត្រឹមតែតំណាងឲ្យជនរងគ្រោះដទៃទៀតនោះទេ ថែមទាំងលើកស្ទួយដល់ការជួសជុល និងផ្សះផ្សានៅក្នុងសហគមន៍ ។ ការដាក់តាំងពិព័រណ៍អចិន្ត្រៃយ៍ស្តីអំពីការជម្លៀសដោយបង្ខំនៅតាមសារមន្ទីរខេត្ត ដោយបង្ហាញពីរឿងរ៉ាវរបស់ជនរងគ្រោះនៃរបបខ្មែរក្រហម ប្រវត្តិភូមិ មន្ទីរបូជនីយដ្ឋាន មន្ទីរសន្តិសុខ នឹងឆ្លុះបញ្ចាំងអំពីការចងចាំនៃអំពើប្រល័យពូជសាសន៍ និងការអប់រំដល់ក្មេងៗជំនាន់ក្រោយអំពីទិដ្ឋភាពនានាដែលបានកើតឡើងក្នុងរបបខ្មែរក្រហម ។

**ហ៊ុយ សម្ផស្ស, ហាថសុន ម៉ាករេន និង ផាត កុសល**

◆ **និយាយពីការរស់នៅក្នុងសម័យខ្មែរក្រហម គឺនិយាយពីការផ្សះផ្សា អប់រំកូនចៅឱ្យអត់ឱន អធ្យាស្រ័យគ្នា**

◆ **រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ គឺរៀនពីការទប់ស្កាត់អំពើប្រល័យពូជសាសន៍**

# ការស្លាប់នៅក្នុងចលនា : ការជម្លៀសដោយបង្ខំ និង របបកម្ពុជាប្រជាធិបតេយ្យ

យើងស្គាល់មុខរបស់ជនរងគ្រោះនៅមន្ទីរស-២១ តាមរយៈរូបភាពស-ខ្មៅរបស់អ្នកទោស ដែលធ្លាប់ជាប់ឃុំឃាំង សួរចម្លើយ និងទទួលរងទារុណកម្ម ។ រូបភាពរបស់ជនរងគ្រោះទាំងនោះនៅតែតាមលងបន្លាចយើងគ្រប់គ្នារាល់ពេលដែលយើងដើរចូលទៅក្នុងអគារនៃអតីតមន្ទីរស-២១ ។ បច្ចុប្បន្ន មន្ទីរនេះត្រូវបានស្គាល់ថាជាសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ។ នៅពេលដែលយើងធ្វើដំណើរទៅដល់វាលពិឃាតជើងឯក ហើយនាំគ្នាដើរយ៉ាងស្ងប់ស្ងាត់ឆ្លងកាត់រណ្តៅសាកសពជាច្រើន ធ្វើឲ្យយើងសញ្ជឹងគិតពីជីវិត និងការស្លាប់របស់ជនរងគ្រោះដែលបានបាត់បង់ជីវិតនៅវាលពិឃាតនេះ ។ រូបភាពរបស់ជនរងគ្រោះនៅទួលស្លែង និងមន្ទីរបូជនីយដ្ឋានជើងឯក បានរំឭកអំពីអំពើហិង្សាដែលបានកើតឡើង នៅក្នុងប្រទេសកម្ពុជាចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ។ រូបភាពខាងលើ បានបង្ហាញពីទង្វើនៃអំពើប្រល័យពូជសាសន៍ ។ របបកម្ពុជាប្រជាធិបតេយ្យត្រូវបានបង្កើតឡើងដោយខ្មែរក្រហម ដែលជាកំណើតនៃចលនា "មហាលោតផ្លោះមហាអស្ចារ្យ" ។ លើសពីនេះទៅទៀត ខ្មែរក្រហមតែងតែនិយាយពាក្យមួយឃ្លាថា "កង់ប្រវត្តិសាស្ត្រចេះតែវិលទៅមុខ អ្នកដែលដើរមិនទាន់នឹងត្រូវកិនស្លាប់" ។

ចាប់តាំងពីខែមេសា ឆ្នាំ១៩៧៥ បុរស ស្ត្រី និងកុមារ ត្រូវបានខ្មែរក្រហមជម្លៀសដោយបង្ខំ ទៅកាន់តំបន់ផ្សេងៗគ្នា ។ ប្រជាជនប្រមាណពីរលាននាក់ត្រូវបានខ្មែរក្រហមជម្លៀសចេញពីទីក្រុងភ្នំពេញ ។ សម្រាប់ប្រជាជនមួយចំនួន ការជម្លៀសនេះគឺជាការជម្លៀសលើកទីពីរ ដោយសារតែប្រជាជនទាំងនោះកាលពីមុនរបបខ្មែរក្រហមធ្លាប់បានផ្លាស់ទីលំនៅរបស់ខ្លួនម្តងរួចមកហើយ ដោយសារតែការហែកហួរនៃសង្គ្រាម ។ ប្រជាជនកម្ពុជាត្រូវបានខ្មែរក្រហមបង្ខំឲ្យចេញពីផ្ទះ ឬស្រុកកំណើតរបស់ខ្លួនដោយធ្វើដំណើរតាមរថយន្ត រថភ្លើង រទេះគោ និងដោយថ្មើរជើង ។ នៅពេលដែលមានការជម្លៀសដោយបង្ខំកើតឡើង ប្រជាជនមួយចំនួនបានបាត់បង់ជីវិតដោយសារតែកង្វះអាហារបរិភោគ ជំងឺ ការចាប់ និងការសម្លាប់ ។ ប្រជាជនកម្ពុជាត្រូវបានជម្លៀសជាបន្តបន្ទាប់ រសាត់ខ្ចាត់ខ្ចាយដូចខ្យល់ ទៅធ្វើការងារកសិកម្មតាមឃុំ និងតាមសហករណ៍ ដូចជានៅខេត្តសៀមរាប ខេត្តព្រះវិហារ ខេត្តបាត់ដំបង និងខេត្តបន្ទាយមានជ័យ ។ ប៉ុន្តែសម្រាប់ខ្មែរក្រហមវិញ សូម្បីតែឈ្មោះក៏មិនអាចដាក់ដដែលបានដែរ ។ ជំនួសមកវិញ ខ្មែរក្រហមបានប្រែក្លាយខ្លួនឯងទៅជាជនអនាមិក នៅទីកន្លែងមួយដែលមិនស្គាល់ឈ្មោះ និងទីតាំងមិនពិតប្រាកដ ដោយដើរតាមមនោគមវិជ្ជាតែមួយគត់របស់ខ្លួន ។ នៅចន្លោះឆ្នាំ១៩៧៥-១៩៧៩ មនុស្សម្នាក់មិនបានរស់នៅកន្លែងតែមួយនោះទេ ពោលគឺមនុស្សម្នាក់អាចធ្វើការ និងស្លាប់នៅគ្រប់ទីកន្លែង ។ ខ្មែរក្រហមបានបង្កើតការិយាធិបតេយ្យរបស់ខ្លួន ដោយបែងចែកជាភូមិភាគ និងតំបន់ព្រមទាំងបានដាក់ឈ្មោះ ភូមិភាគ ឬតំបន់ទាំងនោះដោយកំណត់ជាលេខ ។ ជាលទ្ធផល ប្រជាជនប្រហែលជាកន្លះលាននាក់ត្រូវបានបញ្ជូនទៅភូមិភាគពាយ័ព្យ ។ បុរស ស្ត្រី និងកុមារជាច្រើនបានហែលឆ្លងសមុទ្រនៃទុក្ខវេទនា ។ ការឈឺចាប់របស់ប្រជាជនទាំងនោះបានកើតឡើងគ្រប់ទីកន្លែង ដែលផ្ទុយនឹងទេសភាពវាលស្រែ និងព្រឹក្សព្រៃដ៏ខៀវស្រងាត់លើទឹកដីរបស់ប្រទេសកម្ពុជា ។

ផ្លូវដែក គឺជាសមាសភាពសំខាន់មួយនៃការអនុវត្តរបស់ខ្មែរក្រហម ។ ការជម្លៀសប្រជាជនរាប់សែននាក់ដោយបង្ខំត្រូវបានអនុវត្តឡើងពីភូមិភាគមួយ ទៅភូមិភាគមួយ ពីតំបន់មួយទៅតំបន់មួយជាពិសេសពីទីក្រុងទៅតំបន់ដាច់ស្រយាល ។ ការជម្លៀសប្រជាជន ដែលប្រព្រឹត្តឡើងដោយខ្មែរក្រហម ខុសពីការជម្លៀសរបស់ណាហ្ស៊ីអាល្លឺម៉ង់ ឬការជម្លៀសនៅប្រទេសចិន "ការជម្លៀសឡើងលើភ្នំ និងការចុះទៅតាមទីជនបទ" ។ រថភ្លើងរបស់ខ្មែរក្រហមបានទម្លាក់បុរស ស្ត្រី និងកុមារទៅតាមចំណតផ្សេងៗឲ្យទៅធ្វើការ

នៅតាមការដ្ឋាន និងសហករណ៍ផ្សេងៗ ដូចជានៅបឹងខ្នារ និង ព្រៃស្វាយ ឬទៅកោះធំ និងបាត់ដំបង ។

ដើម្បីធានាដល់ការគ្រប់គ្រងវិន័យ និងសណ្តាប់ធ្នាប់របស់ កម្ពុជាប្រជាធិបតេយ្យ សហករណ៍តូចធំ ជាច្រើនត្រូវបានបង្កើត ឡើង ដែលនៅក្នុងនោះមានប្រជាជនពីរាប់រយទៅរាប់ពាន់នាក់ ។ ប៉ុន្តែការបង្កើតនេះ មិនបាននៅទ្រឹងមួយកន្លែងនោះទេ ពោលគឺ ការផ្លាស់ទីមនុស្សបានកើតឡើងជារៀងរាល់ថ្ងៃ ។ មនុស្សម្នាក់ ត្រូវបានខ្មែរក្រហមផ្លាស់ពីកន្លែងមួយទៅកន្លែងមួយទៀត ទៅដក ស្ទូងនៅតាមវាលស្រែ ទៅជម្រះស្មៅ ជីកប្រឡាយ និងទៅលើក ទំនប់ទឹកជាដើម ។ នៅក្នុងដំណើរការនេះ ជីវភាពរស់នៅតាមបែប លក្ខណៈគ្រួសារត្រូវបានបំបាត់ ។ ប្តីត្រូវបានបំបែកចេញពីប្រពន្ធ ឪពុកម្តាយបំបែកចេញពីកូនៗ បងបំបែកចេញពីប្អូន ។ បើតាម ការលើកឡើងរបស់ជនរងគ្រោះម្នាក់ដែលរស់រានមានជីវិតពីរបប ខ្មែរក្រហមបានរំឭកថា «ខ្មែរក្រហមបានជម្លៀសខ្ញុំចេញពីស្រុកឲ្យ ទៅនៅក្នុងព្រៃ ។ ខ្មែរក្រហមធ្វើបែបនេះក្នុងគោលបំណងបង្វែរ គោលដៅរបស់យើង ដើម្បីងាយស្រួលគ្រប់គ្រងយើងទាំងអស់ គ្នា» ។ មនុស្សគ្រប់គ្នាត្រូវតែឆ្ពោះទៅមុខ ព្យាយាមធ្វើយ៉ាងណាឲ្យ នៅពីមុខកង់ប្រវត្តិសាស្ត្រ បើមិនដូច្នោះទេ កង់ប្រវត្តិសាស្ត្រ នឹងកិនស្លាប់ជាមិនខាន ។ របបកម្ពុជាប្រជាធិបតេយ្យ គឺជារបប ប្រល័យពូជសាសន៍ដែលមានចលនា ។

នៅតាមសហករណ៍ និងការដ្ឋានការងារ រាល់សកម្មភាព ការងារទាំងអស់របស់ស្ត្រី បុរស និងកុមារ ដែលស្ថិតក្រោមកម្តៅ សូរ្យសែង ឬព្យុះភ្លៀង តែងតែស្ថិតក្រោមការតាមដានរបស់ អង្គការ ។ កងទ័ពខ្មែរក្រហមតែងតែមានវត្តមាន និងតាមដានយ៉ាង តឹងរ៉ឹងនៅគ្រប់ទីកន្លែង ដូចជាឈរយាមនៅពេលមានការជម្លៀស ដើរត្រួតពិនិត្យតាមសហករណ៍ និងតាមការដ្ឋាន ។ រាល់សកម្មភាព និងទស្សនៈទាំងឡាយណា ដែលខុសប្រក្រតីទោះតូចក្តីធំក្តីនឹងត្រូវ ខ្មែរក្រហមចាត់វិធានការដាក់ទណ្ឌកម្មជាបន្ទាន់ ។ ជាក់ស្តែង ការឃុំ ឃាំងខ្លួននៅក្នុងមន្ទីរសន្តិសុខចំនួនប្រមាណជា២០០កន្លែងនៅ ទូទាំងប្រទេសត្រូវធ្វើឡើងដូចៗគ្នា ។

ការផ្លាស់ទីមានសារសំខាន់ ប៉ុន្តែការផ្លាស់ទីនោះត្រូវបាន ខ្មែរក្រហមដាក់កំហិត ។ ប្រជាជនគ្រប់រូបត្រូវតែបង្កបង្កើនផល ស្រូវ ដែលជាការងារស្នូល ។ ប៉ុន្តែទិន្នផលដែលទទួលបាន ត្រូវបាន ខ្មែរក្រហម នាំចេញបន្តទៅក្រៅប្រទេស ដូចជា ប្រទេសចិន ប្រទេស យូហ្គោស្លាវី ម៉ាដាហ្គាស្កា និង ហុងកុង ជាដើម ។ ជាលទ្ធផល ប្រជា ជនកម្ពុជារាប់សែននាក់ត្រូវទទួលរងការអត់ឃ្លាន និងកង្វះជីវជាតិ ។ ជាងនេះទៅទៀត ប្រជាជនត្រូវធ្វើការជីកប្រឡាយ លើកទំនប់ ដឹកជញ្ជូនទឹកពីកន្លែងដែលសំបូរ ទៅកន្លែងដែលខ្វះខាតទឹក បើកបរ រថយន្តដឹកទំនិញ ចែវទូក ឃ្វាលគោក្របី បើករថភ្លើង និងការងារ ដទៃជាច្រើនទៀត ។ ពោល គឺប្រជាជនគ្រប់រូបត្រូវចូលរួមចំណែក ជួយជំរុញឲ្យកង់ប្រវត្តិសាស្ត្ររបស់កម្ពុជាប្រជាធិបតេយ្យវិល ទៅមុខមិនឈប់ឈរ ដែលនៅទីបញ្ចប់ឈានទៅដល់អំពើហិង្សា ឃោរឃៅ ។

ដូចដែលយើងគ្រប់គ្នាបានឃើញរណ្តៅសាកសពវាល ពិឃាដជើងឯក និងរណ្តៅសាកសពរាប់ពាន់កន្លែងរាយប៉ាយទូទាំង ប្រទេស ដែលរូបភាពឆ្លុះបញ្ចាំងពីសង្គមកម្ពុជានារបបខ្មែរក្រហម ហើយធ្វើឲ្យយើងគ្រប់គ្នានឹកឃើញរូបភាពជាប់ឃុំឃាំងចំពោះ អ្នកទោសនៅគុកទួលស្លែង ។ ចំពោះសោកនាដកម្មដែលបានកើត ឡើង ទីតាំងដែលពាក់ព័ន្ធទៅនឹងការជម្លៀសដោយបង្ខំ កង់ប្រវត្តិ សាស្ត្ររបស់កម្ពុជាប្រជាធិបតេយ្យ ដែលជោគជាំដោយញើស ឈាម និងទឹកភ្នែករបស់ប្រជាជនដែលគ្មានកំហុសរាប់លាននាក់ ដែលបានបន្សល់ទុកនៅក្នុងរណ្តៅសាកសព គឺជាភស្តុតាងយ៉ាង ច្បាស់ និងរឹងមាំមួយសម្រាប់បង្ហាញពីឧក្រិដ្ឋកម្មប្រឆាំងមនុស្ស ជាតិដែលបានបង្កឡើងដោយខ្មែរក្រហម ។ **វេមស៍ អេ ថាយន័រ**

## អានទស្សនាវដ្តីតាមគេហទំព័រ

ទស្សនាវដ្តីស្វែងរកការពិតទាំងអស់ត្រូវបានផ្សព្វផ្សាយតាម គេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ អ្នកអានអាចរកបាន តាមៈ http://d.dccam.org/Projects/Magazines/Magazine_Searching.htm . ព័ត៌មានបន្ថែម សូមទាក់ទង ញាណ សុជាតិ ទូរស័ព្ទលេខ ០១៦ ៨៧៦ ៦៩២ ឬ ០២៣ ២១១ ៨៧៥ ។

# ជីវិត ក្នុងព្យុះមរណា

### ១) ព្រឹត្តិការណ៍ថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥

សូរគ្រាប់កាំភ្លើងត្បាល់ចម្រុះធុន ឮសូរលឺយៗ នៅឯទិសព្រលានយន្តហោះអន្តរជាតិភ្នំពេញ ជូនឮយប់ ឬឮថ្ងៃ នេះគឺជាការចូលវាយសម្រុកផ្តាច់ព្រ័ត្រដើម្បីរំដោះរដ្ឋធានីភ្នំពេញរបស់កងទ័ពអាវខ្មៅ ខ្មែរក្រហមពីរបបសាធារណរដ្ឋខ្មែរ ដែលដឹកនាំដោយលោកសេនាប្រមុខ លន់ នល់ ។ ខែនេះ គឺជា ខែមេសា ឆ្នាំ១៩៧៥ ដែលប្រជាជនខ្មែរទាំងអស់ តែងតែប្រារព្ធពិធីបុណ្យចូលឆ្នាំខ្មែរប្រពៃណីជាតិ ចាប់ពីថ្ងៃទី១៤ ដល់ថ្ងៃទី១៦ ។ នៅល្ងាចថ្ងៃទី១៣ ខែមេសា ឆ្នាំ១៩៧៥នេះ ឪពុករបស់ខ្ញុំបានធ្វើដំណើរមកពីខេត្តសៀមរាប តាមរយៈយន្តហោះឈ្នួលមួយគ្រឿងដែលមកចុះចតកណ្តាលគ្រាប់ផ្លោង នៅព្រលានយន្តហោះពោធិ៍ចិនតុង ។ គាត់បានរកខ្ញុំនៅផ្ទះជួលនៅឯភ្នំពេញនេះ ទាំងតក់ក្រហល់ ហើយប្រាប់ខ្ញុំថា សភាពការណ៍ស្រុកទេសយើងឥឡូវមិនស្រួលនោះទេ គាត់មកនេះ គឺដើម្បីមើលថែខ្ញុំ ព្រោះខ្ញុំនៅក្មេងសេចក្តីណាស់ ។ កាលណោះ ខ្ញុំអាយុ២១ឆ្នាំហើយ និងរៀននៅថ្នាក់ទីមួយទំនើប នៃវិទ្យាល័យព្រះយុគន្ធរ ។ ខ្ញុំរស់នៅផ្ទះជួលរួមគ្នាមួយល្វែង ខាងលិចផ្សារអូរឡាំពិក ដែលមានគ្នាប្អូននាក់ រួមទាំងខ្ញុំ គឺ កាំង ប្រ ហៅ ឈន់ ចុង ជាពេទ្យមធ្យម ចេញធ្វើការហើយ កាំង មួយ និស្សិតពេទ្យឆ្នាំទីពីរ ជាប្អូនបង្កើតរបស់ ប្រ និងលឹម ទ្រី ជានិស្សិតពេទ្យឆ្នាំទីពីរ និងជាបងប្អូនជីដូនមួយរបស់ ប្រ និង មួយ ។ អ្នកទាំងបីមកពីស្រុកសំរោង ខេត្តតាកែវ ។




រូបខាងឆ្វេង ៖ អ៊ុង វិជ្ជា ហៅ ប៊ុន ធឿន និង សៀវ សុដុន ថតឆ្នាំ១៩៧៤

ថ្ងៃទី១៦ ខែមេសា ឆ្នាំ១៩៧៥ ជាថ្ងៃចុងបញ្ចប់នៃពិធីបុណ្យចូលឆ្នាំខ្មែរ នៅម៉ោងប្រហែលជាងពរសៀលទៅហើយ ខ្ញុំត្រេកអរណាស់ដែលមិត្តសម្លាញ់ ប៊ុនធឿន មកលេងខ្ញុំ ដូចសព្វដង តែលើកនេះ គាត់បាត់យូរបន្តិច ។ យើងទាំងពីរនាក់ស្រឡាញ់គ្នាណាស់ ។ ប៊ុនធឿន ជិះកង់មកលេងខ្ញុំ លើកនេះមានទឹកមុខក្រៀមក្រំ ទោះបីជា ខ្ញុំហៅឲ្យគាត់អង្គុយលេងសិន ក៏មិនព្រម គឺគាត់អង្គុយលើកង់រហូត ។ បន្ទាប់មក ប៊ុនធឿន បានទាញឧបករណ៍ ផ្លុំភ្លេងអាម៉ូនីកា ចេញពីក្នុងហោប៉ៅហុចមកឲ្យខ្ញុំ ហើយផ្តាំថា “ឯងទុកប្រើចុះ ព្រោះឯងធ្លាប់លេងហ្គីតា” ។ និយាយគ្នាលេងបានបន្តិច ប៊ុនធឿនក៏លាខ្ញុំចេញទៅផ្ទះរបស់គាត់នៅឃ្លាំងរំសេវ គឺជាការលាខ្ញុំទៅ គឺ

លាទៅជារៀនរហូត ។ ប៉ុនធឿន ជាមនុស្សសុចរិត ព្យាយាម និងមានជំនាញខាងជាងឈើទៀតផង ។ ខ្ញុំចាំមិនភ្លេចទេ អនុស្សាវរីយ៍រវាងយើងទាំងពីរ ដូចជា ទៅមើលការប្រយុទ្ធគ្នានៅសមរភូមិភ្នំក្រោម ខេត្តសៀមរាប សមរភូមិអរិយក្សត្រនៅមុខវាំង ចាប់ត្រីតភ្លើង ធ្វើកន្ហារ ជាដើម ។

មិនខុសពីការរំពឹងទុករបស់ឪពុកខ្ញុំមែន ចូលមកដល់ថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ ទាហានអាវខ្មៅចូលកាន់កាប់ទីក្រុងភ្នំពេញបានយ៉ាងងាយ អាស្រ័យដោយទាហាន លន់ នល់ បាក់ទឹកចិត្តទម្លាក់អាវុធឈប់ច្បាំង ។ តាមសងខាងដងផ្លូវ ប្រជាជនបានចេញមកឈរនៅក្នុងទឹកមុខញញឹមរីករាយស្វាគមន៍ទទួលកងទ័ពរំដោះខ្មែរក្រហម ពោរពេញដោយក្តីសង្ឃឹមថា នឹងនាំយកនូវសន្តិភាពមិនខានឡើយ ។ ស្រាប់តែមួយម៉ោងក្រោយមក វិទ្យុជាតិភ្នំពេញបានប្រកាសក្តែងៗឡើងថា "កងទ័ពមិត្តយើង គឺចូលមករំដោះទីក្រុងភ្នំពេញបានទាំងស្រុងដោយចុងកាណុង គឺមិនមែនចូលមកដើម្បីចរចាសន្តិភាពឡើយ" ។ ចរន្តអគ្គិសនីចាប់ផ្តើមកាត់ផ្តាច់ចាប់តាំងពីពេលល្ងាចនោះមក ហើយយើងម្នាក់ៗ ស្ថិតក្នុងស្ថានភាពស្រឡាំងកាំង គ្មានដឹងទិសតំបន់ បាត់បង់នូវភាពម្ចាស់ការ នាំគ្នាពន្លត់ភ្លើងទៀនសម្ងំ ចូលដេកយ៉ាងស្ងៀមស្ងាត់ ក្រោមស្នូរគ្រាប់កាំភ្លើងដៃឮសូររប៉េះរប៉ោះម្តងខាងនេះ ម្តងខាងណោះ ។

## ២) ការទទួលរងនូវសម្ពាធផ្នែកផ្លូវកាយ និងផ្លូវចិត្តយ៉ាងធ្ងន់ធ្ងរ

លុះព្រឹកថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩៧៥ យើងបានមកឈរលេងនៅផ្លូវធំពីផ្សារអូរឡាំពិក មកកាន់ផ្លូវម៉ៅសេទុងដូចប្រជាជនដទៃទៀតដែរ យើងឃើញទាហានអាវខ្មៅ ខ្លះដើរ ខ្លះទៀតជិះម៉ូតូ ឬរថយន្ត ក្នុងទឹកមុខសន្តិភាពគួរជឿជាក់ឥតខបមា ។ ផ្តើមចេញពីទិដ្ឋភាពដូចនេះ បានញុំាំងឲ្យបងប្រុស ឈន់ថុង នឹកចង់ដើរមើលទិដ្ឋភាពដូចនេះឲ្យបានច្រើនទៀត គាត់ក៏បបួលខ្ញុំជិះកង់មើលគេមើលឯងពិតប្រាកដមែន ។ ខ្ញុំប្រាប់គាត់ថា មិនទាន់ស្រស់ស្រូបអាហារពេលព្រឹកផង គាត់តបមកវិញថា មិនខ្វះទេ ឲ្យតែមានលុយ គឺគេលក់ឲ្យហើយ ។ តាមការពិតខ្ញុំគ្មានចិត្តទៅបន្តិចសោះ ប៉ុន្តែគាត់ចេះតែទទូច បន្ទុំចិត្តខ្លាំងពេក ណាមួយឪពុកខ្ញុំគាត់នៅស្ងៀមទៀត ប្រហែលជាគាត់យល់ថា បងឈន់ ថុង រៀន ថ្នាក់ខ្ពស់ហើយជាចាស់ទុំយល់ហេតុការណ៍បានច្រើនគួរឲ្យគាត់ទុកចិត្តបានហើយ មើលទៅ ។ ពេលនោះ ខ្ញុំស្ថិតក្នុងសម្លៀកបំពាក់ខោខ្លេវធម្មតា តែចំណែកគាត់ ពាក់អាវតេតារុងពណ៌ស្ករ ដៃខ្លី ស្លៀកសារុងប្រុសក្រឡាចត្រង្គ ដែលមានខ្ញុំជាអ្នកជិះកង់ឌុបគាត់ ។ គួរបញ្ជាក់ថា បងឈន់ ថុង គាត់មិនសូវចុះសម្រុងជាមួយ អ៊ីស្រីម្ចាស់ផ្ទះជួល ក៏ដូចជា ប្អូនជីដូនមួយ លឹមទ្រី ដែរ ហើយសូម្បីតែលោកគ្រូពេទ្យ ជាអ្នកជិតខាងដែលមានផ្ទះនៅជាប់របងខាងលិចផ្ទះ ក៏គាត់មិនសូវត្រូវគ្នាដែរ ។ ខ្ញុំចាំបានថា មានពេលមួយនោះ បងឈន់ថុងទាស់សម្តីគ្នាជាមួយលោកគ្រូពេទ្យ ខ្ញុំបានចូលទៅឃាត់ និងទាញគាត់ ឲ្យមកផ្ទះវិញទាន់ កុំអីត្រូវលោកគ្រូពេទ្យនោះ ចាក់សោរបងជាប់ យើងទាំងពីរនាក់នៅក្នុងផ្ទះគាត់បាត់ទៅហើយ ។

មិនមែនងាយស្រួលដូចយើងគិតឯណា យើងជិះចេញបានចម្ងាយប្រហែល២០០ម៉ែត្រប៉ុណ្ណោះ ត្រូវបានទាហានអាវខ្មៅពីរនាក់ ម្នាក់លើកបេ៤០ភ្ជង់ និងម្នាក់ទៀតលើកកាំភ្លើងអាកាភ្ជង់ឲ្យយើងទាំងពីរទៅមុខឲ្យលឿនដាច់ខាតកុំថយក្រោយឲ្យសោះក្នុងនោះក៏មានអ្នកដំណើរដូចយើងច្រើននាក់ដែរ ។ ប្រហែលជា២០ម៉ែត្រ ខាងមុខយើង ទាហានអាវខ្មៅវ័យក្មេងម្នាក់ បានលើកកាំភ្លើងអាកា បាញ់បញ្ចិតក្បាលយុវជនម្នាក់ អស់ប្រហែលកន្លះបង់គ្រាប់ដែលកំពុងឱនដឹកកង់រត់បត់ត្រឡប់មកវិញ ក្នុងទឹកមុខភិតភ័យ ។ ខ្ញុំលួចក្រឡេកមើលមុខ បងឈន់ ថុង មួយភ្លែតឃើញមុខគាត់សស្លាំងទទួលគាត់ជាកូនកាត់ចិនផងនោះ មុខកាន់តែ ស ធ្វើឲ្យខ្ញុំកាន់តែភ័យជាងមុនទៅទៀត ។ យើងក៏បន្តដំណើរ ដោយទាហានអាវខ្មៅម្នាក់នោះ លើកកាំភ្លើងភ្ជង់តម្រង់មកយើង ។ ចូលមកដល់ផ្លូវម៉ៅសេទុងអ្នកដំណើរទាំងអស់ តម្រូវឲ្យបត់ស្តាំ ឆ្ពោះទៅកាន់ស្ទឹងមានជ័យដោយមានទាហានអាវខ្មៅប្រមាណ១០នាក់ ដើរតាមជាប់ពីក្រោយអ្នកដំណើរទាំងអស់ ក្រែងមាននរណាម្នាក់គេចដើរទៅផ្លូវផ្សេង ។ លើកនេះ ខ្ញុំទាំងពីរនាក់មិនបន្តង់យូរឡើយ គឺខិតខំស្រូតរូតដំណើរទៅមុខឲ្យបានលឿន ដើម្បីគេចពីការឃ្លាំមើលរបស់ទាហានទាំងអស់នោះ ។ លុះជិតមកដល់ស្ទឹងមានជ័យ យើងមើលទៅមុខមិនមានឃើញ ទាហានយាមកាមផង ហើយក្រឡេកមើលក្រោយ ក៏ដាច់ឆ្ងាយពីគេគ្រាន់បើដែរ ។ ស្ថិតក្នុងឱកាសដ៏ល្អនេះ នៅខាងស្តាំដៃយើងមានផ្លូវក្រាលកៅស៊ូមួយខ្សែបែកចេញទៅទិសខាងលិចយើងក៏បត់កង់ធាក់យ៉ាងលឿនទៅតាមផ្លូវនោះទៅ ។ នៅតាមផ្លូវ

នេះ គឺជួបជាមួយមនុស្សតែម្នាក់គត់ ពាក់អាវធំ ពណ៌ស៊ីកឈើ មានខ្សែក្រវាត់ចុងជាយអាវ លេចខាងក្រោម ដើរប្រាសទិសជាមួយយើង តែម្នាក់នោះ ក៏មិនចាប់អារម្មណ៍អ្វីនឹងខ្ញុំទាំងពីរដែរ ។ ដោយភ័យពេកតែមួយសន្ទុះសោះ យើងធ្វើដំណើរបានប្រហែលប្រាំគីឡូម៉ែត្រ ហើយក៏ឈប់កង់បន្តិចដើម្បីពិគ្រោះគ្នា ។

ក្រោយគិតគ្នារួចហើយ យើងក៏សម្រេចចិត្តប្តូរទិសដៅធ្វើដំណើរវិញ យើងឈប់ធ្វើដំណើរតាមផ្លូវធំទៀតហើយ គឺយើងទាំងពីរដឹកកង់ចុះពីលើថ្នល់ជាតិ មកខាងស្តាំដៃ ដោយធ្វើដំណើរកាត់តាមវាលស្រែវិញម្តង វាមានសុវត្ថិភាពជាង ។ ដោយខែមេសានេះ ជារដូវប្រាំង យើងអាចជិះកង់ កាត់តាមវាលស្រែបានដើម្បីសំដៅចូលទៅកាន់ ទីក្រុងភ្នំពេញវិញ ។ នៅតាមវាលស្រែយើងពុំបាន ជួបទាហានខ្មែរក្រហមទេ គឺជួបតែកសិករ៤-៥ផ្ទះតែប៉ុណ្ណោះ ដែលម្នាក់ៗមានទឹកមុខក្រៀមក្រំ ឈរសំឡឹងមើលរទេះគោដែលពួកគាត់បានចងឥវ៉ាន់សំពីងសំពោងប្រហែលជាត្រៀមចេញដំណើរ ។ យើងទាំងពីរបានចូលសុំទឹកកសិករនោះផឹក និងសួរនាំគាត់រកផ្លូវចូលមកទីក្រុងភ្នំពេញវិញ ។ ក្រោយពេលដែលយើងសុំទឹកគាត់ផឹករួចម៉ោងប្រហែល១១ យើងសម្លឹងមើលទៅទិសខាងកើតគឺឃើញផ្ទះថ្មជាយ ក្រុងភ្នំពេញដូចដែលពួកគាត់ប្រាប់យើងមែន ។ រីករាយណាស់យើងមានកម្លាំងជាងមុន ធ្វើដំណើរលឿនទៅ រយៈពេលតែមួយម៉ោងទេ យើងក៏បានចូលមកដល់ជាយក្រុងភ្នំពេញនេះតែម្តង ។ មកដល់ភ្លាម គឺមានសភាពស្ងប់ស្ងាត់ជ្រងំផ្ទះស្ទើរតែទាំងអស់ត្រូវបានបិទទ្វារ ។ សូម្បីតែចូលកៀកមកដល់ជិតផ្សារថ្មីហើយក៏ដោយ ។ យើងជិះឆ្លៀលផ្សារថ្មីកន្លះជុំឃើញតែផ្ទះពីរល្វែងទេ បើកទ្វារតូចៗម្ចាស់ឈរនៅ មុខផ្ទះសម្លឹងមកកាន់យើងដោយយកចិត្តទុកដាក់ ។ ក្រៅពីនេះ យើងបានជួបទាហានអាវខ្មៅ៤-៥នាក់ ស្ពាយកាំភ្លើងដើរទៅកន្លែងផ្សេងៗពីគ្នា ជាសំណាង ទាហានទាំងនោះ គ្រាន់តែសម្លឹងមើលយើងតែប៉ុណ្ណោះហើយក៏គ្មានសួរនាំអ្វីដែរ ។

យើងបានចាកចេញពីផ្សារថ្មីឆ្ពោះទៅកាន់ផ្សារអូឡាំពិកដោយមិនរួញរាឡើយ ។ នៅតាមផ្លូវ យើងឃើញទាហានអាវខ្មៅជិះចេញលើឡាន ជី.អ៊ឹម.សេ ចំនួនពីរគ្រឿង ស្រែកហ៊ោកញ្ជៀវកងរំពង អបអរនឹងជ័យជម្នះរបស់ខ្លួនដែលទើបដណ្តើមបានថ្មីៗ ។ លុះមកដល់អាងទឹកស្តាតអូឡាំពិក យើងឃើញ រថក្រោះអ៊ឹម១៣ ចំនួន៤ទៅ៥គ្រឿង ទាហានអាវខ្មៅជិះពីលើពេញ មានលើកទង់ជ័យក្រហម ស្រែកហ៊ោដូចគ្នា ផ្សេងខ្មៅងងឹត សំឡេងរថក្រោះឮកក្រើកដី ធ្វើឲ្យយើងភ័យខ្លាចជាខ្លាំង ។ តាមផ្លូវធ្វើដំណើរពីផ្សារថ្មីទៅផ្សារអូឡាំពិក គឺនៅតាមផ្ទះទាំងអស់បិទទ្វារ ក្រៅពីទាហានអាវខ្មៅទាំងនោះ គ្មាននរណាម្នាក់នៅ ឬអ្នកដំណើរណាម្នាក់នោះទេក្រៅពីខ្ញុំពីរនាក់នេះ ។ ទីបំផុតយើងបានមក ដល់ផ្ទះ តែមើលទៅគឺស្ងាត់ជ្រងំដូចគ្នាទៀត បន្តិចក្រោយមកទើបឃើញទ្វារបើកហើយឮសំឡេងមនុស្សស្រែកពីក្នុងផ្ទះមកថា "ពួកគេមកដល់វិញហើយ" ក្នុងចំណោមមនុស្សបីនាក់ដែលចេញពីក្នុងផ្ទះមកទទួលយើង ក៏មានឪពុករបស់ខ្ញុំម្នាក់ដែរ ម្នាក់ៗមានទឹកមុខរីករាយសាទរ ចំពោះការវិលមកវិញរបស់យើង ។ បន្ទាប់ពីមកដល់ផ្ទះវិញទាំងក្តីភ័យខ្លាច ក៏មានរឿងដ៏គួរឲ្យអស់សំណើចមួយដែរ គឺ បង ឈន់ ថុង មិនដឹងថា លើកសារុងស្លៀកខើចឡើងលើពាក់កណ្តាលភ្លៅពីថ្ងៃណាមកទេ ប្រហែលជាគាត់ភ័យខ្លាំងពេកហើយមើលទៅ ។

ប្រហែលជាម៉ោងបីរសៀល ពេលគឺក្រោយយើងហូបបាយសំណេះសំណាលគ្នារួច មិនបានប៉ុន្មានផង មានទាហានអាវខ្មៅចំនួនបីនាក់មកឈរវេរាទៅចំមុខផ្ទះយើង ហើយស្រែកប្រាប់យើងទាំងអស់គ្នាក្នុងសំឡេងម៉ាត់ៗថា "ចូររៀបឥវ៉ាន់ចេញពីផ្ទះទាំងអស់គ្នា ក្នុងពេលឥឡូវនេះ ចាំបីថ្ងៃទៀត សឹមចូលមកវិញ" និយាយហើយទាហានទាំងនោះក៏ដើរចេញទៅ ។ មានតែខ្ញុំ និងឪពុកទេ ដែលចង់ចេញតាមបញ្ជា ព្រោះចង់ទៅស្រុកភូមិជួបជុំគ្រួសារបងប្អូនវិញ ព្រោះយើងបែកគ្នាចំនួន៥ឆ្នាំ (១៩៧០-១៩៧៥) មកហើយ ។

ខ្ញុំ និងឪពុក ក៏ចាប់ផ្តើមរៀបចំខោអាវដាក់ក្នុងវ៉ាលិសម្នាក់មួយមានដូចជា ម៉ាញ៉េ ម៉ាក នីវីកូ, វិទ្យុ ម៉ាក សាន់យ៉ូ ប្រើថ្មពាជុំមួយគ្រឿង, វិញ្ញាបនបត្របញ្ជាក់ការសិក្សា, នាឡិកា ម៉ាក រ៉ាដូ ពីរគ្រឿង និងខ្សែកមាសបន្តោងព្រះមួយខ្សែ ទម្ងន់៨ជី ដោយរៀបចំរួចជាស្រេចរង់ចាំចេញដំណើរ ។

## ៣) ការចាកចេញពីទីក្រុងភ្នំពេញ

អង្គុយសំណេះសំណាលគ្នាបានបន្តិចម៉ោងជិត៤ទៅហើយ ក៏មានទាហាអាវខ្មៅចំនួន៣នាក់ផ្សេង ទៀតមកដល់ប្រាប់យើងម្តង

ទៀត ក្នុងប្រយោគដដែលដូចក្រុមមុន ហើយខ្ញុំពីរនាក់ ឪពុកខ្ញុំក៏ចាកចេញមកជាមួយទាហានបីនាក់នោះ មិនបង្អង់ឬប្រកែកអ្វីឡើយ ។ យើងចេញមកបានបន្តិច លុះក្រឡេកមើលទៅក្រោយក៏មិនឃើញទាហានទាំងបីនាក់នោះតាមពីក្រោយទៀតដែរ ។ ការធ្វើដំណើរនេះ គឺស្ថិតនៅតាមផ្លូវដែលខ្ញុំជិះកង់កាលពីព្រឹកនោះឯង ខុសប្លែកតែចេញមកដល់ផ្លូវម៉ៅសេទុង ខ្មែរក្រហមឲ្យបត់មកខាងឆ្វេងដៃវិញម្តង ។ មកដល់ផ្លូវនេះយើងជួបមនុស្សកាន់តែច្រើន ហើយយើងដើរមិនបានលឿនដូចមុនដែរ ។ ដើរបានឆ្ងាយបន្តិច ខ្ញុំឃើញពំនូកខោអាវ ទាហាន លន់ នល់ ដែលគេប្រមូលគរជាពំនូកៗ ប្របតាមចញ្ចើមផ្លូវ ។

លុះមកដល់រោងកុនបូកគោ ខ្មែរក្រហមឲ្យបត់ស្តាំដើរតាមផ្លូវព្រះមុនីវង្សឆ្ពោះទៅកាន់ក្បាលថ្នល់ ។ នៅកណ្តាលហ្វូងមនុស្សដ៏ច្រើន នេះខ្ញុំបានឮសំឡេងមនុស្សប្រុសហៅខ្ញុំឈ្មោះចំៗ ខ្ញុំងាករកម្ចាស់សំឡេងនោះ គឺមិត្តរួមថ្នាក់ខ្ញុំម្នាក់ឈ្មោះ វ៉ា ដែលជាអ្នករស់នៅភ្នំពេញនេះ ។ យើងគ្រាន់តែបានសើចដាក់គ្នាតែប៉ុណ្ណោះ ព្រោះយើងនៅឃ្លាតពីគ្នាប្រហែល១០ម៉ែត្រ ដោយមនុស្សច្រើន រុញគ្នាចុះឡើងៗ យើងក៏បែកគ្នាទៅ ។ លុះមកដល់គល់ស្ពានព្រះមុនីវង្សជាចំណុចប្រសព្វ ខ្ញុំឃើញមនុស្សកាន់តែច្រើន មិនខុសពីហ្វូងស្រមោចប៉ុន្មានឡើយ ។ ឪពុកខ្ញុំ ចាប់ដៃស្តាំខ្ញុំយ៉ាងណែន ហើយប្រាប់ថា បើសិនជាវង្វេងគ្នាមិនដឹងជាទៅរកកន្លែងណាទេ គឺច្បាស់ជាព្រាត់ស្លាប់មិនខាន ។ មនុស្សកាន់ច្រើនឡើងៗ ដល់មែនទែនទៅយើងដើរបានចមាយតែ៧-៨ម៉ែត្រប៉ុណ្ណោះ ក្នុងមួយម៉ោង ។ យើងចុកជើងខ្លាំងណាស់ ទោះចង់អង្គុយក៏គ្មានកន្លែងអង្គុយដែរ ហើយម្យ៉ាងទៀត កាបូបដែលខ្ញុំស្ពាយ ក៏កាន់តែធ្ងន់ទៅៗ តាមការពិត កាបូបដែលឪពុកខ្ញុំស្ពាយ គឺធ្ងន់ជាងកាបូមដែលខ្ញុំស្ពាយឆ្ងាយណាស់ ។

យប់កាន់តែជ្រៅបន្តិចហើយ យើងទើបតែមកដល់មុខផ្សារច្បារអំពៅ ហើយពេលនោះខ្ញុំមានអារម្មណ៍មួយហាក់ដូចជាមានពន្លឺភ្លើងចាំងមករកយើង លុះក្រឡេកមើលទៅខាងស្តាំដៃប្រមាណ ៣០០ម៉ែត្រ ឃើញផ្ទះឈើមួយឆេះរន្ទាលឡើង ធ្វើឲ្យយើងអាចមើលមុខមនុស្សច្បាស់គ្រាន់ជាងមុន ។ ដោយសារពន្លឺភ្លើងនេះ ឪពុកខ្ញុំគាត់បានជួបគ្រួសារមួយមានសមាជិក៥នាក់ ជាអ្នកកំពង់ឃ្លាំងដូចគ្នា ។ បន្ទាប់មក អ្នកដំណើរទាំងអស់ បានរកកន្លែងចូលសម្រាករៀងខ្លួន ហើយក៏មិនអនុញ្ញាតឲ្យចេញទៅណាឆ្ងាយពីផ្លូវនេះដែរ ។ យើងទាំងអស់គ្នាសម្រាកឆ្ងាយពីផ្លូវនេះប្រហែល១០ម៉ែត្រ ។ ខ្ញុំឈរជួយទប់កង់មួយគ្រឿងរបស់គ្រួសារនេះ ដែលមានការុងឥវ៉ាន់ព្យួរសំយុងសងខាងរានកង់ ភ្នែកខ្ញុំសម្លឹងមើល ទៅភ្លើងឆេះផ្ទះ ដែលកំពុងឆេះបន្តគ្នាពីផ្ទះមួយឆ្លងទៅផ្ទះមួយទៀត ។ ដោយខ្ញុំហេវហត់ អស់កម្លាំង រយៈពេលមួយថ្ងៃ ហើយថែមមួយកំណាត់យប់ទៀតនោះក៏បណ្តាលឲ្យខ្ញុំឈរ ហើយដេកលក់មួយភាំង កង់ដួលដល់ដី ។

## ៤) មិត្តនារីអាវខ្មៅ សំពត់ខ្មៅ ដឹកអង់អាចក្លាហាន

ស្អែកឡើងយើងធ្វើដំណើរទីទៃពីគ្រួសារដែលយើងបានជួបពីម្សិលមិញ ឪពុកខ្ញុំគាត់ចេញដំណើរមកមុនរួមជាមួយមនុស្សរាប់ពាន់នាក់ ដែលមានទាហានអាវខ្មៅជាអ្នកដឹកនាំនូវការធ្វើដំណើរទៅលើផ្លូវជាតិលេខ១ ។ ការធ្វើដំណើរនៅព្រឹកនេះមិនយឺតប៉ុន្មានទេ ដូចជាបានលឿនគ្រាន់បើបន្តិច តែមនុស្សមានច្រើនពេញផ្លូវដដែល ។ តាមផ្លូវធ្វើដំណើរ ខ្ញុំបានឃើញក្មេងស្រីជំទង់ម្នាក់រុញរទេះតូចមួយ ដែលផលិតពីដែកអីណុកដោយយឺតៗ និងថ្នមៗ ចែកអាហារដល់អ្នកជំងឺនៅមន្ទីរពេទ្យ ។ កំពុងតែភ្ញាក់នឹងមើលក្មេងស្រីនោះ ទិដ្ឋភាពមួយទៀតដែលគួរឲ្យអាណោចអាធ័មមួយទៀត ដែលនៅជ្រុងម្ខាងក្បែរជញ្ជាំងនោះ គឺ ខ្ញុំបានឃើញកូនង៉ែតក្រហមរងាលមួយ ប្រហែលជាទើបនឹងកើតផង ក៏មិនដឹងកំពុងដេកយំយ៉ាងខ្លាំង នៅជុំវិញខ្លួនមានឥវ៉ាន់បន្តិចបន្តួចផងក្រោមកំដៅថ្ងៃចែងចាំង ។ នៅក្រោមផ្ទាល់ដី គឺជាម្តាយដែលស្ថិតក្នុងវ័យជាង៤០ឆ្នាំ ប្រកបដោយទឹកមុខស្លេកស្លាំង អង្គុយអង្គុញក្បាលជង្គង់អោនក្បាលបន្តិចពីក្រោមកូនង៉ែតថ្ងូចថ្ងូរមិនដាច់មាត់ ដៃជើងញីញ័រ ក្រសែភ្នែកក្រឡាប់ចុះ ក្រឡាប់ឡើង គ្មានអ្នកណាមើលថែម្នាក់ឡើយ ។ ស្ត្រីជាម្តាយនោះ គ្មានអាវពាក់ទេ គឺមានតែសំពត់ ខ្មៅកញ្ឆាស់មួយតែប៉ុណ្ណោះ មើលទៅពិតជាគួរឲ្យខ្លោចផ្សាក្នុងចិត្តខ្លាំងណាស់ ។ កំពុងតែស្ទុងអារម្មណ៍ នឹងភាពសោកសង្រេងទាំងនេះ ឪពុកខ្ញុំ ហៅខ្ញុំឲ្យស្រូតដំណើរទៅមុខទៀត ។ ថ្ងៃរាងជ្រេបន្តិច យើងបានចូលមកដល់ទីជនបទ ទិដ្ឋភាពទាំងឡាយមិនដូចពីមុនទៀតទេ ផ្ទះមួយចំនួនត្រូវរុះរើ ។ លុះដល់ម៉ោងប្រហែលជា៣

រសៀល ខ្ញុំឃើញមិត្តនារីដែលឯកសណ្ឋានអាវខ្មៅ សំពត់ខ្មៅ ជួតក្បាលក្រមា មួយក្រុម៨នាក់ ដើរប្រសេចប្រសាចប្រជ្រៀតចូលហ្វូងមនុស្សដ៏ច្រើននោះដែរ ។ ខ្ញុំឃើញច្បាស់ជាង គេគឺមិត្តនារីម្នាក់ដែលដើរជិតខ្ញុំមានទឹកមុខយ៉ាងមាំ ហើយនៅក្នុងដៃស្តាំរបស់នាងមានគ្រាប់បែកដែលផលិតនៅសហរដ្ឋអាមេរិកក្តាប់យ៉ាងណែនប្រកបដោយអង់អាចក្លាហាន ។ មានយុវជនម្នាក់ដើរខាងស្តាំដៃខ្ញុំសម្បុរខ្មៅស្រអែម រាងមាំបន្តិចមានស្លាយតវ៉ាន់ខ្លះដែរ ត្រូវបាននារីនោះយកគ្រាប់បែកបុកចំពោះ ខ្សាំងគួរសមជាមួយនឹងសំនួរថា “ទាហាន?” ។ រំពេចនោះយុវជននេះប្រែទឹកមុខជាស្លេកស្លាំងភ្លាម ហើយមិត្តនារីក៏មិនបង្អង់យូរគឺចាប់ចងស្លាបសេកយុវជននោះភ្លាមៗយ៉ាងស្ទាត់ជំនាញ ហើយបណ្តើរចុះពីលើថ្នល់ជាតិខាងស្តាំដៃឆ្ពោះទៅកាន់រោងចំការមួយឃ្លាតឆ្ងាយពីថ្នល់ជាតិប្រមាណ៥០ម៉ែត្រ ។ លុះខ្ញុំសំឡឹងទៅ ឃើញនៅក្នុងរោងចំការនោះមានមនុស្សមួយចំនួនមិនមានពាក់អាវទេ ត្រូវជាប់ចំណង ក្រពាត់ស្លាបសេកមកក្រោយ អង្គុយសំយុងជើងតម្រៀបគ្នាប្រមាណ៦នាក់រួចទៅហើយ ប្រកបដោយទឹកមុខភិតភ័យតក្កមា ។ ខ្ញុំងាកមកវិញយ៉ាងរហ័ស លែងហ៊ានមើលទៅកាន់កន្លែងនោះទៀត វាពិតជាគួរឲ្យរន្ធត់ណាស់សម្រាប់ខ្ញុំ ។ ល្ងាចបន្តិច យើងក៏បានមកដល់ព្រែកឯង យើងបានឈប់សម្រាកទៅគល់ស្ពានឈើទ្រុឌទ្រោមមួយដោយអាស្រ័យ បាយរស់នៅបណ្តោះអាសន្នជាមួយគ្រួសារដែលមានកូនតូចៗចំនួនពីរនាក់ ប្តីសម្បុរស្រអែមខ្ពស់ អាយុប្រមាណ៣០ឆ្នាំ ។ ពួកគាត់មានអង្ករ នឹង សត្វទាកាប៉ា ពីរក្បាល យើងបានសម្រាកហូបបាយជុំគ្នា ។ យើងបន្តដំណើរទៅមុខបាន ៣-៤ គីឡូម៉ែត្រ ទៀតក៏ឈប់សម្រាកនៅក្នុងរោងចក្ការល្ហុត ដ៏ធំល្វឹងល្វើយស្ថិតនៅតាមដងទន្លេមេគង្គដូចអ្នក ដំណើរដទៃទៀតដែរ ។ មកដល់ទីនេះ ពុំមានទាហានអាវខ្មៅដើរដេញពួកយើងទៀតទេ គឺមនុស្សរាប់ម៉ឺននាក់ស្នាក់នៅសងខាងផ្លូវ ដូចគេធ្វើពិធីបុណ្យអ្វីមួយយ៉ាងដូច្នោះដែរ ។ ចាប់ពីថ្ងៃបាក់រសៀល មកដល់ពេលព្រលប់នៅត្រើយខាងកើតដៃដងទន្លេមានមនុស្សមីរដេរដាសដើរចុះទៅងូតទឹក ។ យូរៗយើង ឃើញមានសាកសពអណ្តែតតាមខ្សែទឹកទន្លេ ជួនឃើញម្នាក់ ជួនឃើញពីរនាក់អណ្តែតបន្តគ្នា ។ ដោយ មនុស្សច្រើននាំឲ្យសម្បូរសត្វរុយ ឪពុកខ្ញុំសម្រាកលេងពេលថ្ងៃដោយចងមុង ហើយគាត់បើកវិទ្យុដែលមាននៅជាប់នឹងម៉ាញ៉េ នីវីកូ ស្តាប់ព័ត៌មានផ្សេងបញ្ចៀសការអផ្សុក ។ ពេលនោះ ខ្ញុំនៅចាំកន្លែង ស្រាប់តែឃើញឪពុកខ្ញុំគាត់ត្រឡប់មកវិញ មានយួរកំសៀវទឹកចំណុះ៥លីត្រ ត្រាក្រពើមួយនៅដៃ ហើយបង់ក អាវយឺតមួយពណ៌សូកូឡា ដើរមកជិតដល់ខ្ញុំក៏លាន់មាត់ថា យី! ចឹក គឺជារបស់យើងទេតើ? ឪពុកខ្ញុំតបមកវិញថា គាត់បានជួបលោក កាំង បួយ ពួកគេចេញពីភ្នំពេញ ក្រោយយើង មួយថ្ងៃដោយជិះឡានក្រុងជាមួយនឹងគេឯងមក ហើយគាត់ឃើញ គេយកមកជាមួយនូវកំសៀវទឹកនឹងអាវរបស់ខ្ញុំមក គាត់ក៏សុំគេយកមកវិញអាវនេះ គឺជាអាវដែលខ្ញុំ ទើបនឹង ទិញនៅផ្សារអូរឡាំពិក ពណ៌សូកូឡា ដៃខ្លី ហើយគ្មានកទេ នៅពេលចេញមក ភ្លេចយកមកតាមខ្លួន ។ ថ្ងៃស្អែកឡើងខ្ញុំបានដើរទៅលេងសួរសុខទុក្ខ លោក កាំង បួយ ហើយគេមានគម្រោងចូលទៅក្រុងភ្នំពេញ តាមសេចក្តីអំពាវនាវរបស់អង្គការ បានជួបមនុស្សប្រុសស្រី៤នាក់ ទៀតផ្ទះជិតគ្នានៅភ្នំពេញ ព្រមទាំងបានជួប លោក បូក គីម ស៊ីត់ កូនអ៊ឹ បូក ក្រាម ធ្លាប់រៀននៅសាលាបឋមសិក្សាវត្តល្វាឃុំកំពង់ឃ្លាំង ជាមួយគ្នា កាលនៅពីកុមារ ។ ខ្ញុំបានយកដំណឹងនេះមកជម្រាបឪពុកខ្ញុំវិញ ហើយគាត់បានចាប់អារម្មណ៍លើបំណងលោក កាំង បួយ ដែលប្រុងចូលទៅកាន់ទីក្រុងភ្នំពេញ វិញ ថែមទាំងប្រាប់ខ្ញុំថា ចាំឪពុកនាំឯងឲ្យបានជួបម្តាយឯងសិន ហើយសឹមឯងចង់ទៅណាក៏ទៅចុះ ។ តាមការពិតខ្ញុំគ្មានអារម្មណ៍បន្តិចណាចង់ទៅកាន់ទីក្រុងភ្នំពេញវិញទេ គឺខ្ញុំមានការនឹករឭកបងប្អូន កូនក្មួយជីដូនជីតា នឹងអ្នកម្តាយរបស់ខ្ញុំខ្លាំងណាស់ ។

### ៥) តម្រូវការស្បៀងបានចូលមកដល់

ការហូបចុកចេះតែអូសបន្លាយ គ្រួសារភាគច្រើនត្រូវខើចស្បៀង ទីផ្សារគ្មានប្រាក់រៀល បានឈប់ចាយស្ទើរទាំងស្រុង ខ្ញុំក៏សម្រេចចិត្តចូលទៅរកស្បៀងនៅក្នុងទីក្រុងភ្នំពេញវិញ ។ យើងរួមដំណើរជាមួយមនុស្ស៩៣នាក់ផ្សេងទៀត ដែលមានផ្ទះជាប់គ្នានៅភ្នំពេញក្នុងនោះ បងវេង អ្នកលេង ភ្លេង កាន់ហ្គីតា សូឡូ ក្នុងវង់តន្ត្រីមួយនៅភ្នំពេញ លោក សេ ដា កោរសក់ មានសាក់រូបនៅលើដើមដៃខាងស្តាំ , ប្អូនប្រុស លោក សេ ដា មិនចាំឈ្មោះ ។ ក្រោកពីព្រលឹមមក យើង៤នាក់ដើរជុំគ្នា ហើយបានសន្យាកុំបែកគ្នាឲ្យសោះពេលមើលឃើញព្រះបរមរាជវាំងច្បាស់ហើយ យើងបាន

ដូលទូក ធំមួយ ទូកនេះចាស់ គ្មានក្តារ ប្តរនាបទេ រួមជាមួយមនុស្សប្រមាណ១០នាក់ទៀត ឆ្លងទៅត្រើយខាងលិច ម្តុំគីឡូម៉ែត្រលេខ ៦ ។ ម៉ោងប្រហែល៩ព្រឹកហើយ យើងដើរលើផ្លូវនៅគីឡូម៉ែត្រលេខ៦ បានឃើញមនុស្សជាច្រើនមិនតិចជាង១.០០០នាក់ទេ ដែលជាអ្នកមករកស្បៀងដូចយើងដែរ ។ តាមការពិតគឺមានមនុស្សចូលមករកស្បៀងនៅក្រុងភ្នំពេញនេះពីរបីថ្ងៃ មកហើយ តែយើងមិនបានដឹង ។ យើងដើរមិនបានប៉ុន្មាននាទីផង ស្រាប់តែព្យួស្នូរគ្រាប់កាំភ្លើងអាកា៤៧ បាញ់រះឡើងលើចំនួនមួយបង់ រំពេចនោះ ឃើញមនុស្សជាច្រើន ផ្អើលឈូ រត់ចេញពីឃ្លាំងស្បៀង ទៅខាងស្តាំដៃ យើងរុលដំណើរបន្តិច ក៏នាំគ្នាទៅមុខទៀត ស្រាប់តែនៅខាងឆ្វេងដៃយើងមានខ្មោច តាចិនម្នាក់ សម្លៀកបំពាក់ដេកយប់ ដេកនៅបណ្តោយអែបចិញ្ចើមផ្លូវ ។ យើងបានចូលមើលតាមបណ្តាឃ្លាំងខ្លះដែរ មានតែសំបកការុង សំបកបាវ និង ហ្វុយសាំង ។ល ។ យើងគ្មានសង្ឃឹមថា នឹងបានស្បៀងឡើយ ពេលយើងដើរទៅមុខបានបន្តិច ឃើញផ្ទះឈើជាប់ដី ក្បែរមាត់ទន្លេទៀត ។ ផ្ទះនេះទ្វារចំហ ហើយមានឥវ៉ាន់រាយប៉ាយពេញក្នុងផ្ទះ រីឯនៅក្នុងបន្ទប់មួយ មានទូដែកមួយ យើងរកបានញញួរទម្ងន់៥គីឡូមួយ ប្តូរវេនគ្នាសំពង ។ ប្រហែលកន្លះម៉ោងក្រោយមក ទើបទូដែកនេះ ធ្លាយ បាក់បែកទាំងថតលើ និងថតក្រោម តែពុំមានឃើញអ្វីសូម្បីតែបន្តិចសោះឡើយ ។ យើងទាំង អស់គ្នា ហេវហត់ បានត្រឹមតែសំឡឹងមើលមុខគ្នាទៅវិញទៅមកប៉ុណ្ណោះ ហើយក៏នាំគ្នាទៅឃ្លាំងមួយទៀត ។ នៅទីនោះ ក៏គ្មានស្បៀងដែរ គឺមានតែកាម៉ែលសំប៉ែតៗរាងពងក្រពើ ប្រកក្នុងថង់ក្រដាស ពណ៌លឿង ប្រមាណ១០កេះធំ យើងក៏នាំគ្នាយក ៤-៥ កាម៉ែលក្នុងម្នាក់ៗរួចដើរចេញពីក្នុងឃ្លាំង បែកក្រុមគ្នាទៅ ។

ដោយស្ថិតនៅក្នុងខែចេត្រ មេឃក្តៅណាស់ ខ្ញុំស្រេកទឹកយ៉ាងខ្លាំង ក្រឡេកទៅទឹកនៅមាត់ ច្រាំងទន្លេ ឃើញខ្មោចពាក់អាវប៉ារ៉ា អណ្តែតមួយកំណាត់ខាងលើ ផ្ងារពោះ ហើយឆ្ងាយពីនោះប្រហែល៧ម៉ែត្រ ទៅកណ្តាលទន្លេ ឃើញសាកសពអណ្តែតមួយទៀត ។ ខ្ញុំគ្មានជំរើសទេ ដោយមាន ការបន្ទំ ពីសំណាក់អ្នកទាំងបីនាក់ ឈរចាំលើមាត់ច្រាំងនោះផងទៅ ខ្ញុំក៏ដាច់ចិត្តក្បង់ទឹកចម្ងាយប្រមាណ៥ម៉ែត្រ ពីសាកសពដឹកមួយផ្អែត ។ ពេលនោះខ្ញុំទើបបានដឹងថា លោក សេ ដា ជាទាហាន ព្រោះពេលនោះក្តៅពេក គាត់ដោះអាវ ហើយយកភក់លាបលើសាក់នៅដើមដៃស្តាំរបស់គាត់ ដែលជាលេខរបស់អង្គភាពទាហាន ។ ម៉ោងប្រហែលជា២សៀលទៅហើយ ពួកយើងគ្មានបានស្បៀងមួយ គ្រាប់សោះ ទោះបីជាយ៉ាងនេះក៏ដោយ ក៏យើងមិនបោះបង់គម្រោងការរបស់យើងចោលដែរ ។ ចូល មកដល់ក្នុងឃ្លាំងចុងក្រោយនេះគឺមានសុទ្ធតែម្សៅសាគូ យើងប្រញាប់លើកដាក់លើស្មាម្នាក់មួយការុងៗ ដើរចេញមក ពីព្រោះព្យួសូរកាំភ្លើងបាញ់រះអស់មួយបង់ទៀត ជាលើកចុងក្រោយ ដែលសញ្ញាប្រាប់ថា ឲ្យចេញឲ្យលឿន ។ យើងត្រូវជួបប្រទះនូវបញ្ហាគ្មានមធ្យោបាយឆ្លងទៅកាន់ត្រើយខាងកើតវិញទេ មានទូកជាច្រើនដែរ តែបាត់ម្ចាស់អស់ ។ ទទួលទីនោះ មានហ្វុយសាំងផង យើងក៏យកហ្វុយសាំងពីរ ចងភ្ជាប់គ្នា លើកម្សៅសាគូទាំង៤ការុង ដាក់ពីលើ ហើយថែមទាំងមានខ្យល់បក់ទៀត ។ យើងទាំងបួននាក់ហែលតោងហ្វុយសាំង រុញទៅមុខសំដៅត្រើយខាងកើតដៃទន្លេ ។, កូនកាបូបក្នុង ហោប៉ៅក្រោយខ្ញុំត្រូវទឹកអស់ ដែលនៅក្នុងនោះមានកាតកូនសិស្ស ប្រាក់កាសបន្តិចបន្តួច ហើយចំណែកឯស្បែកជើងផ្ទាត់ក្រាសពណ៌បៃតងក្រវាត់ជាប់នៅចង្កេះ ។ លុះក្បូនហ្វុយសាំងដល់កណ្តាលទន្លេ ភ្លៀងផ្តើមធ្លាក់ជាខ្លាំង ថែមទាំងមានខ្យល់បក់មកប៉ើងស័ង្កសី សន្ទឹកខាងលើនោះព្យួសូប្រាវ ហោះទៅប្រមាណជា២០ម៉ែត្រ លិចនៅកណ្តាលទន្លេបាត់ទៅ ។ ពួកយើងស្រឡាំងកាំងភ័យស្ទន់ស្មោសំឡឹង មើលមុខគ្នានឹកស្មានតែរន្ទះបាញ់ ហែលទៅមុខទៀតលែងចង់រួច ក៏ស្រែកប្រាប់គ្នីគ្នា ឲ្យស្រាតខោអាវក្រៅចេញ យកដាក់លើក្បូន បើមិនដូច្នោះទេ ប្រយ័ត្នគ្រោះថ្នាក់ ។ ក្រោយមកយើង នៅសល់ តែខោខ្លី ថ្វីបើគ្មានបាយមួយគ្រាប់នៅក្នុងពោះយ៉ាងនេះ ក៏ដោយ ហាក់ដូចជាមានកម្លាំងដោយ អនុភាពនៃទឹក ។ នៅខាងស្តាំដៃឃើញមាន ទូកជាច្រើនកំពុងឆ្លងកាត់ទន្លេដូចយើងដែរ ហើយក៏គ្មាន នរណាគេឆ្លងកាត់ដោយហ្វុយសាំងដូចយើងដែរ ។ ភ្លៀងចាប់ផ្តើមអន់បន្តិចម្តងៗ យើងក៏បានរុញហ្វុយសាំងបានដល់ត្រើយដែរ ហើយចុះផ្ទួតទឹកជំរះកាយរួមជាមួយមនុស្សផ្សេងទៀតជាច្រើន ។ ម៉ោងប្រមាណជាងប្រាំល្ងាចទៅហើយ យើងម្នាក់ៗលីម្សៅសាគូមួយការុង និងកាម៉ែល៥ម្នាក់ដើរចេញក្នុង ទឹកមុខរីករាយសំដៅទៅចម្ការល្ហុត ។

ដើរបានចម្ងាយមួយគីឡូម៉ែត្រមានមនុស្សស្គាល់គ្នាហៅហូបបាយតាមផ្លូវ យើងហូបបានតែកន្លះចាន ម្នាក់ៗចាប់ផ្តើមធុញបន្តិចម្តងៗ ហើយចេះតែបន្តធ្វើដំណើរទៅៗ យើងបរិច្ចាកការម៉ែលចេញពីខ្លួនម្តងមួយ ជាមួយនឹងមេក្រវាសារគូ ជាហូរហែ បន្តបន្ទាប់គ្នា ។ នៅតាមផ្លូវយើងតែងតែជួប មនុស្សបន្តបន្ទាប់ ចំឡែកអី តែនៅកន្លែងមួយនោះ គ្មានជួបមនុស្សម្នាក់សោះ រំពេចនោះ ខ្ញុំលោតរំលងផ្លូវដែលមានរបងតឿ តាមពីក្រោយពួកយើង ស្រាប់តែខ្ញុំភ្ញាក់ប្រញាងឡើង ព្រោះនៅជាប់នឹងរបងនោះ មានខ្មោចមនុស្សស្រីម្នាក់ដេកផ្ងារដៃម្ខាងនឹងក្បាលសំយុងធ្លាក់ពីលើគ្រែ ឡេវអាវប្រេះ ព្រោះដោះម្ខាងៗ ហើមប៉ុនក្បាលមនុស្ស ។ ពួកយើងដែលដើរមុន គេឈប់ចាំនៅរោងសណ្តែកទ្រើងមួយ ដោយធុំក្លិន កាន់តែខ្លាំងឡើងៗ ខ្ញុំដាក់ភ្នែកមកវិញ សំឡឹងមើលក្រោយផ្ទះ និងចំហៀងផ្ទះ បានឃើញខ្មោចមនុស្ស ប្រុសពាក់ខ្ញុំរន្ធត់ស្មារតីខ្លាំងណាស់ ។ កាលបើមកជុំគ្នានៅរោងសណ្តែកទ្រើងនោះ ឃើញមានផ្លែច្រើន នឹកឃ្លានដែរ តែចំហាយសាកសពនៅធុំក្លិនដល់នៅឡើយ ។ ដើរបន្ត បានប្រមាណ២០០ម៉ែត្រ មកទៀត ជួបផ្ទះតូចមួយដែលជាអ្នកស្រុកនៅទីនោះ គេសួរថា តើយើងមានជួបហេតុការណ៍អ្វីកើតឡើងទេ អម្បាញ់មិញនេះ? គាប់ជួនពេលនោះ យើងឮសំឡេងឡានយ៉ាងខ្លាំង ដល់ក្រឡេកមើលទៅឃើញឡានហ្ស៊ីបមួយគ្រឿងមានទាហានអាវខ្មៅជិះពេញហៀរ កាន់អាវុធគ្រប់ដៃ ប្រុងប្រាងលើកឡើងលើ យើងមើលឃើញច្បាស់បើកយ៉ាងលឿនចូលក្នុងចំការ ដែលយើងឆ្លងកាត់រួច ។ ស្ងាត់មួយ ស្របក់ពួកយើងឆ្លើយប្រាប់ថា មានឃើញខ្មោចនៅទីនោះចំនួន៥នាក់ ហើយម្ចាស់ ផ្ទះប្រុសស្រីទាំងពីរនាក់នោះ ប្រាប់យើងថា ពួកអ្នកឯងរាល់គ្នាសំណាងល្អហើយ បើសិនពួកកងទ័ពនេះ មកទាន់ កំពុងតែនៅក្នុងចម្ការម៉្លេះសមនឹងចោទថា លួចបេះដំណាំអង្គការ ហើយបាញ់សម្លាប់ចោលដូចខ្មោចទាំងនោះមិនខានទេ ។ យើងទាំងអស់គ្នាភ័យស្ទើរលោះព្រលឹង ថ្ងៃជិតលិចទៅហើយ យើងក៏លាម្ចាស់ផ្ទះបន្តដំណើរទៅទៀតទាំងព្រលឹងនៅចុងសក់ ។ **(នៅមានត)**

**សៀវ សុផុន**

# ដំណឹងប្រកាសរកញាតិ



ខ្ញុំបាទឈ្មោះ សាំង សុធា មានស្រុកកំណើតនៅឃុំប្រសូត្រ ស្រុកស្វាយទាប ខេត្តស្វាយរៀង សព្វថ្ងៃរស់នៅសង្កាត់ទំនប់ទឹក ខណ្ឌចំការមន ក្រុងភ្នំពេញ សូមប្រកាសរកញាតិឈ្មោះ ប៊ុន អាង (បច្ចុប្បន្នមានអាយុជាង៧០ឆ្នាំ) ។ ប៊ុន អាង ជាគ្រូបង្រៀន មានស្រុកកំណើតនៅឃុំព្រែកពោធិ៍ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ។ គាត់បានចេញទៅបង្រៀននៅខេត្តស្វាយរៀង ក្នុងទសវត្សរ៍ឆ្នាំ១៩៥០ ។ នៅក្នុងខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានចាប់គាត់ឃុំឃាំង នៅវត្តឫស្សី ក្នុងស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ។ ក្រោយមក ខ្មែរក្រហមបានដោះលែងគាត់ ហើយឲ្យមករស់នៅជាមួយ គ្រួសារខ្ញុំនៅភូមិព្រះទន្លេ ស្រុកស្វាយជ្រំ ។

មកដល់ចុងឆ្នាំ១៩៧៦ ខ្មែរក្រហមបានជម្លៀស គ្រួសារខ្ញុំទៅរស់នៅខេត្តពោធិ៍សាត់ ហើយចាប់តាំងពីពេលនោះមកខ្ញុំបានបែកពីគាត់រហូត ។ នៅពេលថ្មីៗនេះ ខ្ញុំទើបឮដំណឹងថា គាត់រស់នៅសហរដ្ឋអាមេរិក និងបានមកសាកសួររកប្អូនរបស់គាត់នៅព្រែកពោធិ៍ ។

ប្រសិនបើឮបានឃើញការ ប្រកាសនេះ សូមទាក់ទងមកខ្ញុំតាមរយៈលេខទូរស័ព្ទ ០១២ ២៨២ ២២២ ឬមជ្ឈមណ្ឌលឯកសារកម្ពុជា ផ្ទះលេខ៦៦ ផ្លូវព្រះសីហនុ រាជធានីភ្នំពេញ ឬលេខទូរស័ព្ទ ០២៣ ២១១ ៨៧៥ ។

***សូមអរគុណ!***

# សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់
# នៅក្នុងរបបខ្មែរក្រហម

មជ្ឈមណ្ឌលឯកសារកម្ពុជា គ្រោងនឹងបោះពុម្ពផ្សាយនូវសៀវភៅមានកត់ត្រាឈ្មោះរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាង១លាននាក់រួចមកហើយ ។ ប្រសិនបើលោកយាយ លោកតា អ៊ំ ពូ មីង ប្រាថ្នាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតមាននៅក្នុងសៀវភៅនេះ សូមទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ អេង កុកថាយ ទូរស័ព្ទលេខ ០១២ ៧៩៧ ៣៩៤ ឬ អ៊ីម៉ែល ៖ truthkokthay@dccam.org ឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។

***សូមផ្តល់ព័ត៌មានដូចខាងក្រោមៈ***

១) ឈ្មោះអ្នកប្រកាសប្រាប់, ២) តើមានបងប្អូនបង្កើតរួមទាំងឪពុកម្តាយស្លាប់ប៉ុន្មាននាក់នៅក្នុងសម័យខ្មែរក្រហម? ៣) ឈ្មោះអ្នកស្លាប់, ៤) ភេទអ្នកស្លាប់, ៥) អាយុអ្នកស្លាប់ (បើអាចចាំបាន), ៦) ត្រូវជាអ្វីនឹងអ្នកប្រកាស (ឧទាហរណ៍ៈ ឪពុក ម្តាយ បងប្រុស ប្អូនប្រុស បងស្រី ឬប្អូនស្រី), ៧) សាច់រឿងទាក់ទងនឹងការស្លាប់ (ឧទាហរណ៍ ៖ ស្លាប់នៅទីណា? មូលហេតុអ្វី?), ៨) វត្ថុតាងទាក់ទងនឹងអ្នកស្លាប់ (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ), ៩) ព័ត៌មានសម្រាប់មជ្ឈមណ្ឌលទាក់ទង (ឧទាហរណ៍ៈ លេខទូរស័ព្ទ អាស័យដ្ឋាន) ។

***ប្រសិនបើចង់ស្វែងរកអ្នកដែលបាត់ខ្លួនសូមផ្តល់ព័ត៌មានខាងក្រោមៈ***

១) ឈ្មោះអ្នកបាត់ខ្លួន, ២) ភេទ, ៣) អាយុ, ៤) ត្រូវជាអ្វី, ៥) សាច់រឿងទាក់ទងនឹងការបែកគ្នា, ៦) វត្ថុតាងទាក់ទងនឹងអ្នកបាត់ខ្លួន (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ។










ដើម្បីយុត្តិធម៌និងការចងចាំ
ដែលជាមូលដ្ឋានដ៏សំខាន់ក្នុងការផ្សះផ្សាជាតិ

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយ ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ សហរដ្ឋអាមេរិក (USAID)
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម.៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ ៖ (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ⬩ Preah Sihanouk Blvd ⬩ Phnom Penh ⬩ Cambodia ⬩ Tel: (855) 23 211 875 ⬩ Fax: (855) 23 210 358 ⬩ dccam@online.com.kh ⬩ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ⬩ Number 174, 2014 ⬩ Funded by USAID.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.